ការប្រែប្រួលដ៏សំខាន់បំផុតរបស់ច្បាប់ស្តីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្មពីច្បាប់មជ្ឈត្តការ UNCITRAL នោះគឺការបង្កើតឡើងនូវមជ្ឈមណ្ឌលមជ្ឈត្តកម្មពាណិជ្ជកម្មជាតិ ("ម.ជ.ម.") នៅស្ថិតនៅក្រោមក្រសួងពាណិជ្ជកម្ម។ ម.ជ.ម ត្រូវបានបង្កើតឡើងដោយច្បាប់ស្តីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្ម ដែលត្រូវបានប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៥០៦/០១០ ចុះថ្ងៃទី០៥ ខែឧសភា ឆ្នាំ២០០៦។[25] យោងទៅតាមច្បាប់នេះ រាជរដ្ឋាភិបាលកម្ពុជាបានចេញអនុក្រឹត្យលេខ ១២៤ អនក្រ.បក ចុះថ្ងៃទី១២ ខែសីហា ឆ្នាំ២០០៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់មជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការផ្នែកពាណិជ្ជកម្ម និងអនុក្រឹត្យលេខ ១៨២ អនក្រ.បក ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១០ ស្តីពីការធ្វើវិសោធនកម្មអនុក្រឹត្យលេខ ១២៤ អនក្រ.បក។[26] គណៈកម្មការរៀបចំ និងជ្រើសរើសមជ្ឈត្តករដំបូង ត្រូវបានបង្កើតឡើងដោយប្រកាសរបស់ក្រសួងពាណិជ្ជកម្មលេខ ២២៣ MOC/SM២០០៩ ចុះថ្ងៃទី ១២ ខែតុលា ឆ្នាំ២០០៩។ ម.ជ.ម. មានទំនួលខុសត្រូវដ៏ស្មុគស្មាញក្នុងនាមជាវេទិកាមជ្ឈត្តកម្ម និងជាអាជ្ញាប

[24] គេហទំព័រ https://uk.practicallaw.thomsonreuters.com/

[25] ព្រះរាជក្រមលេខ នស/រកម/០៥០៦/០១០ ចុះថ្ងៃទី០៥ ខែឧសភា ឆ្នាំ២០០៦

[26] អនុក្រឹត្យលេខ ១២៤ អនក្រ.បក ថ្ងៃទី១២ ខែសីហា ឆ្នាំ២០០៩

ណ្ណ និងជាអាជ្ញាធរត្រួតពិនិត្យសម្រាប់ មជ្ឈត្តករទាំងអស់នៅក្នុងប្រទេសកម្ពុជា សូម្បីតែអ្នកដែលអាចបម្រើក្នុងវេទិកាផ្សេងទៀតក៏ដោយ។ ម.ជ.ម. ត្រូវយកចិត្តទុកដាក់យ៉ាងប្រុងប្រយ័ត្នចំពោះតួនាទីពីរនេះ ដើម្បីរក្សានូវទំនុកចិត្តរបស់សហគមន៍អាជីវកម្ម និងផ្នែកច្បាប់។

នៅចុងឆ្នាំ ២០០៩ មជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការផ្នែកពាណិជ្ជកម្មបានចាប់ផ្តើមជ្រើសរើសមជ្ឈត្តករ ហើយគេរំពឹងថាស្ថាប័ននេះនឹងទទួលបានជោគជ័យ និងក្លាយជាជម្រើសដ៏សំខាន់សម្រាប់ការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ និងការគោរពពីសហគមន៍ធុរកិច្ច វានឹងជួយលើកទឹកចិត្តដល់ការវិនិយោគបរទេស និងជួយនាំយកមជ្ឈត្តកម្មនៃជម្លោះអន្តរជាតិមកកម្ពុជា។

មជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការផ្នែកពាណិជ្ជកម្មមានសក្តានុពលក្នុងការធ្វើឱ្យមានភាពប្រសើរឡើងគួរឱ្យកត់សម្គាល់ចំពោះបរិយាកាសអាជីវកម្មដោយផ្តល់ឱ្យអាជីវកម្មនូវជម្រើសដែលត្រូវការច្រើនចំពោះយន្តការដោះស្រាយវិវាទដែលមានស្រាប់។ ម.ជ.ម. ក៏អាចធ្វើឱ្យប្រសើរឡើងនូវបរិយាកាសធុរកិច្ចរបស់កម្ពុជាដោយការកែលម្អទំនុកចិត្តអាជីវកម្ម បង្កើនភាពប្រាកដប្រជា និងបង្ហាញពីឆន្ទៈរបស់រដ្ឋាភិបាលក្នុងការជំរុញបរិយាកាសច្បាប់ និងបទប្បញ្ញត្តិកាន់តែប្រសើរឡើង។[27]

## ២.៤.រចនាសម្ព័ន្ធ

### ២.៤.១. មហាសន្និបាត

សិទ្ធិអំណាចកំពូលរបស់ ម.ជ.ម. គឺមហាសន្និបាត។ មហាសន្និបាតប្រចាំឆ្នាំត្រូវធ្វើឡើងតាមកាលបរិច្ឆេទ ដែលកំណត់ដោយក្រុមប្រឹក្សាប្រតិបត្តិ ។ ក្នុងករណីចាំបាច់ប្រធានក្រុមប្រឹក្សាប្រតិបត្តិ ឬសមាជិកភាគច្រើននៃក្រុមប្រឹក្សាប្រតិបត្តិ អាចស្នើសុំបើកមហាសន្និបាតវិសាមញ្ញបានដោយមានភ្ជាប់មកជាមួយ នូវរបៀបវារៈក្នុងរយៈពេលយ៉ាងតិច១៥ (ដប់ប្រាំ) ថ្ងៃ មុនថ្ងៃប្រជុំ ។ មហាសន្និបាតវិសាមញ្ញនេះត្រូវពិចារណាតែបញ្ហាណាដែលមិនបានលើកឡើង ឬដោះស្រាយនៅក្នុងមហាសន្និបាតប្រចាំឆ្នាំ ដែលបានធ្វើឡើងរួចហើយតែប៉ុណ្ណោះ ។ ការជូនដំណឹងពីមហាសន្និបាតប្រចាំឆ្នាំ ត្រូវធ្វើឡើងយ៉ាងតិច ៣០ (សាមសិប) ថ្ងៃ មុនដំណឹងនេះត្រូវបញ្ជាក់ពីកាលបរិច្ឆេទ ទីកន្លែងប្រជុំ និងរបៀបវារៈ ។

មហាសន្និបាតប្រចាំឆ្នាំពិនិត្យនិងអនុម័តលើបញ្ហាជាអាទិ៍៖

- ✓ របាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំនិងរបាយការណ៍ប្រចាំឆ្នាំរបស់ក្រុមប្រឹក្សាប្រតិបត្តិ
- ✓ គម្រោងថវិកាប្រចាំឆ្នាំរបស់ ម.ជ.ម.
- ✓ ការបោះឆ្នោតជ្រើសតាំងនិងដកហូតសមាជិកក្រុមប្រឹក្សាប្រតិបត្តិ

[27] Rajh & Tann Asia, National Commercial Arbitration Center: Development and Challenges, ២០២១

- ✓ បទបញ្ជាផ្ទៃក្នុងនិងវិធាន ដែលទាក់ទងនឹងការដោះស្រាយវិវាទផ្នែកពាណិជ្ជកម្ម
- ✓ ការកែប្រែនូវបទប្បញ្ញត្តិនានា ដែលទាក់ទងដល់ដំណើរការរបស់ ម.ជ.ម.
- ✓ បែបបទហិរញ្ញវត្ថុនិងរដ្ឋបាល សម្រាប់ការគ្រប់គ្រងដំណើរការរបស់ ម.ជ.ម.
- ✓ នីតិវិធីសម្រាប់ការចុះបញ្ជីមជ្ឍត្តករ
- ✓ លក្ខណសម្បត្តិបន្ថែមសម្រាប់ឱ្យធ្វើជាមជ្ឈត្តករនៅ ម.ជ.ម.
- ✓ ក្រមសីលធម៌សម្រាប់មជ្ឈត្តករ។

មហាសន្និបាតអាចប្រព្រឹត្តទៅបានលុះត្រាតែមានវត្តមាន២/៣ (ពីរភាគបី) នៃសមាជិកទាំងអស់គិតទាំងសមាជិកផ្ទេរសិទ្ធិ ហើយបញ្ហានានាដែលលើកមកពិភាក្សា ត្រូវសម្រេចដោយសំឡេងភាគច្រើនដាច់ខាត ។

- ✓ ក្នុងករណីមិនមានកូរ៉ុមដើម្បីដំណើរការមហាសន្និបាត កិច្ចប្រជុំនេះ ត្រូវពន្យាររយៈពេលចំនួន១៤ (ដប់បួន) ថ្ងៃហើយកូរ៉ុមសម្រាប់កិច្ចប្រជុំលើកទីពីរនេះគឺ ១/២ (មួយភាគពីរ) នៃសមាជិកទាំងអស់ គិតទាំងសមាជិកផ្ទេរសិទ្ធិ ។
- ✓ ក្នុងករណីដែលកិច្ចប្រជុំលើកទីពីរពុំមានកូរ៉ុម មហាសន្និបាតនេះត្រូវពន្យាររយៈពេលចំនួន១៤ (ដប់បួន) ថ្ងៃទៀតហើយប្រសិនបើនៅតែគ្មានកូរ៉ុមនៅក្នុងកិច្ចប្រជុំនេះទៀត ចំនួនអ្នកចូលរួមក្នុងកិច្ចប្រជុំដែលត្រូវពន្យាពេលជាលើកទីពីរនោះត្រូវចាត់ទុកថាជាកូរ៉ុមដើម្បីចាប់ផ្តើមមហាសន្និបាត ។

ការបោះឆ្នោតតាមរយៈសិទ្ធិប្រទានត្រូវបានអនុញ្ញាតប៉ុន្តែសមាជិកម្នាក់អាចទទួលបានសិទ្ធិប្រទានតែមួយប៉ុណ្ណោះ សិទ្ធិប្រទានត្រូវធ្វើជាលាយលក្ខណ៍អក្សរ ហើយត្រូវចុះក្នុងកំណត់ហេតុប្រជុំ។

មហាសន្និបាតវិសាមញ្ញ ត្រូវបានកោះប្រជុំដោយប្រធានក្រុមប្រឹក្សាប្រតិបត្តិ និងតាមពេលកំណត់ដោយក្រុមប្រឹក្សាប្រតិបត្តិ ។ប្រសិនបើប្រធានក្រុមប្រឹក្សាប្រតិបត្តិ មិនបានកោះប្រជុំមហាសន្និបាតវិសាមញ្ញក្នុងរយៈពេល៣ (បី) ខែ បន្ទាប់ពីបានទទួលសំណើជាលាយលក្ខណ៍អក្សរទេនោះ សមាជិកដែលស្នើសុំឱ្យមានមហាសន្និបាតវិសាមញ្ញ អាចបើកមហាសន្និបាតវិសាមញ្ញតាមរយៈការជូនដំណឹងទៅសមាជិកទាំងអស់ ក្នុងរយៈពេល៣០ (សាមសិប) ថ្ងៃជាមុន ដោយរៀបរាប់អំពីបញ្ហាដែលត្រូវពិភាក្សា ហើយត្រូវបិទផ្សាយរបៀបវារៈរបស់ខ្លួន នៅលើក្តារព័ត៌មានក្នុងបរិវេណ ម.ជ.ម.។[28]

### ២.៤.២. ក្រុមប្រឹក្សាប្រតិបត្តិ

ម.ជ.ម. គ្រប់គ្រងដោយក្រុមប្រឹក្សាប្រតិបត្តិ ដែលត្រូវជួបប្រជុំរៀងរាល់ខែ ដែលក្រុមប្រឹក្សាប្រតិបត្តិត្រូវមានសមាជិកមិនលើសពី ៧ ( ប្រាំពីរ) រូបឡើយ ។

សមាសភាពក្រុមប្រឹក្សាប្រតិបត្តិរួមមាន៖

[28] អនុក្រឹត្យលេខ ១២៤ អនក្រ.បក ថ្ងៃទី១២ ខែសីហា ឆ្នាំ២០០៩

- ✓ ប្រធានមួយរូប
- ✓ អនុប្រធានមួយរូប
- ✓ ហេរញ្ញិកមួយរូប
- ✓ សមាជិកមួយចំនួន ។

ក្រុមប្រឹក្សាប្រតិបត្តិគ្រប់គ្រងនិងសម្រេចការងារប្រចាំថ្ងៃ ។ សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាប្រតិបត្តិមានអានុភាពអនុវត្ត លើកលែងតែសេចក្តីសម្រេចនោះ ត្រូវបានបដិសេធដោយមហាសន្និបាត ។
ក្រុមប្រឹក្សាប្រតិបត្តិបំពេញតួនាទីផ្សេងៗទៀតមានជាអាទិ៍៖

- ✓ ជ្រើសរើសបុគ្គលិកឱ្យបម្រើការងារជាអគ្គលេខាធិការរបស់ ម.ជ.ម.
- ✓ កំណត់ចំនួនបុគ្គលិក និយោជិត លក្ខខណ្ឌការងារ ប្រាក់បៀវត្ស កម្រៃសេវា ឬលក្ខខណ្ឌដទៃទៀត
- ✓ បញ្ឈប់ការងារនិងដាក់វិន័យលើបុគ្គលិក ដោយផ្អែកតាមកិច្ចសន្យាការងារ ។
- ✓ ក្រុមប្រឹក្សាប្រតិបត្តិត្រូវធ្វើរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំ គម្រោងថវិកាប្រចាំឆ្នាំ និងរបាយការណ៍ស្តីពីសកម្មភាពការងាររបស់ ម.ជ.ម. ជូ០ជនមហាសន្និបាតប្រចាំឆ្នាំ ។

សមាជិករបស់ក្រុមប្រឹក្សាប្រតិបត្តិ ត្រូវបានបោះឆ្នោតជ្រើសតាំងនៅក្នុងមហាសន្និបាតន ម.ជ.ម. ។សមាជិកក្រុមប្រឹក្សាប្រតិបត្តិមានអាណត្តិ ៣ (បី)ឆ្នាំ ហើយសមាជិកទាំងអស់អាចធ្វើជាសមាជិកនៃក្រុមប្រឹក្សាប្រតិបត្តិមិនលើសពី ២(ពីរ) អាណត្តិឡើយ។ សមាជិកក្រុមប្រឹក្សាប្រតិបត្តិទាំងអស់អាចត្រូវបានបោះឆ្នោតសម្រាប់ ២ (ពីរ) អាណត្តិជាប់គ្នា លើកលែងតមុខតំណែងជាហេរញ្ញិកដែលមិនអាចត្រូវបានជ្រើសរើស ២(ពីរ) អាណត្តិជាប់គ្នា។

ប្រធាន អនុប្រធាន និងហេរញ្ញិក ត្រូវបានជ្រើសរើសតាមរយៈការបោះឆ្នោតដោយឡែកពីគ្នាក្នុងចំណោមសមាជិកក្រុមប្រឹក្សាប្រតិបត្តិដោយក្រុមប្រឹក្សាប្រតិបត្តិ។ប្រធានក្រុមប្រឹក្សាប្រតិបត្តិ ត្រូវបានបោះឆ្នោតជ្រើសរើសនៅក្នុងកិច្ចប្រជុំលើកដំបូងរបស់ខ្លួន។ការបោះឆ្នោតជ្រើសរើសប្រធានត្រូវធ្វើជា ២ (ពីរ) ប្រសិនបើជុំទី១ គ្មានបេក្ខជនណាទទួលសំឡេងគាំទ្រភាគច្រើនដាច់ខាតទេ ។ ការបោះឆ្នោតនៃជុំទីពីរ គឺយកតែបេក្ខជនពីររូបដែលមានសំឡេងឆ្នោតច្រើនជាតកទ័យណ្ណោះមកឱ្យឈរឈ្មោះ ។ោយឡែកអនុប្រធាននិងហេរញ្ញិក ត្រូវបោះឆ្នោតជ្រើសរើសដោយយកតាមសំឡេងភាគច្រើនធម្មតា ក្នុងករណីមានសំឡេងស្មើគ្នា ត្រូវយកអ្នកមានអាយុច្រើនជាងគេ ។សមាជិកភាគច្រើននៃក្រុមប្រឹក្សាប្រតិបត្តិ ត្រូវមានសញ្ជាតិខ្មែរ ។ ដោយឡែក ប្រធាន និង ហេរញ្ញិក ត្រូវមានសញ្ជាតិខ្មែរ ។

ប្រធានរបស់ក្រុមប្រឹក្សាប្រតិបត្តិ គឺជាប្រធានរបស់ ប.ជ.ម. ។ អនុប្រធាន ត្រូវជួយការងាររបស់ប្រធាន ហើយជំនួសប្រធាននៅពេលដែលប្រធានអវត្តមាន ។ ហេរញ្ញិក ត្រូវគ្រប់គ្រងមូលនិធិ ប្រមូលចំណូលនិងចាត់ចែង

ចំណាយក្នុងនាម ម.ជ.ម. ហើយត្រូវមានគណនីចរន្តនិងត្រូវទទួលខុសត្រូវពីភាពត្រឹមត្រូវនៃគណនីទាំងនោះ ។ សមាជិករបស់ក្រុមប្រឹក្សាប្រតិបត្តិ ត្រូវជួយការងារ ម.ជ.ម.និងបំពេញភារកិច្ច ដែលក្រុមប្រឹក្សាប្រតិបត្តិប្រគល់ជូន ។

ក្នុងករណីតំណែងប្រធាន អនុប្រធាន ឬហេរញ្ញិក របស់ក្រុមប្រឹក្សាប្រតិបត្តិនៃ ម.ជ.ម.នៅទំនេរដោយសារការលាលែងពីមុខតំណែង ក្រុមប្រឹក្សាប្រតិបត្តិត្រូវបោះឆ្នោតជ្រើសរើសសមាជិករបស់ខ្លួនម្នាក់ទៀតឱ្យចូលកាន់មុខតំណែងដែលនៅទំនេរនោះនៅក្នុងកិច្ចប្រជុំបន្ទាប់ ឬនៅឯកិច្ចប្រជុំណាមួយដ៏ខ្លី បន្ទាប់ពីការលាលែងនោះ ។សមាជិកគ្រប់រូបរបស់ ម.ជ.ម. ទោះរូបវន្តបុគ្គលក្តី អ្នកតំណាងផ្ទេរសិទ្ធិដែលទទួលបានការចាត់តាំងពីសភាពាណិជ្ជកម្មរាជធានី ខេត្តនៃព្រះរាជាណាចក្រកម្ពុជា សភាមុខរបរនិងមីក្រូសហគ្រាស គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា និងសមាគមដែលប្រមូលផ្តុំពាណិជ្ជករ ឧស្សាហក អាជីវករ និងសេវាករក្តី មានសិទ្ធិឈរឈ្មោះឱ្យមហាសន្និបាតបោះឆ្នោតជាសមាជិកក្រុមប្រឹក្សាប្រតិបត្តិ លុះត្រាតែបានចុះឈ្មោះ ជាមជ្ឈត្តករក្នុងបញ្ជីន ម.ជ.ម. ។ ក្នុងរយៈពេល៦០ (ហុកសិប) ថ្ងៃ មុនកាលបរិច្ឆេទដែលត្រូវបានកំណត់ សម្រាប់មហាសន្និបាតប្រចាំឆ្នាំ ក្រុមប្រឹក្សាប្រតិបត្តិត្រូវធ្វើការកំណត់ និងផ្សព្វផ្សាយនូវកាលបរិច្ឆេទនៃការជ្រើសរើសបេក្ខជន ដែលមិនត្រូវតិចជាង៣ (បី) សប្តាហ៍ បន្ទាប់ពីកាលបរិច្ឆេទនៃការជ្រើសរើសបេក្ខជនទីកន្លែងដែលមានភាពងាយស្រួលក្នុងបរិវេណម.ជ.ម. ឬកន្លែងផ្សេងទៀតសម្រាប់រៀបចំការបោះឆ្នោតជាសម្ងាត់ ។

ការបោះឆ្នោតជ្រើសរើសសមាជិកទាំងអស់ ឬសមាជិកណាម្នាក់របស់ក្រុមប្រឹក្សាប្រតិបត្តិ ត្រូវធ្វើឡើងតាមរយៈ៖

- ✓ ជាសម្ងាត់
- ✓ សមាជិកមួយរូបមានសំឡេងឆ្នោតមួយសំឡេង ក្នុងមហាសន្និបាតប្រចាំឆ្នាំ ឬមហាសន្និបាតវិសាមញ្ញ ដោយអនុលោមតាមវិធានកំណត់ដោយមហាសន្និបាត ។

ក្រុមប្រឹក្សាប្រតិបត្តិថ្មីដែលទើបកើតឡើងក្រោយពីមានការបោះឆ្នោតត្រូវចូលកាន់មុខតំណែងនៅក្រោយពេលមហាសន្និបាតប្រចាំឆ្នាំ ។ មជ្ឈត្តករដែលឈរឈ្មោះបោះឆ្នោត ជាសមាជិកក្រុមប្រឹក្សាប្រតិបត្តិ ត្រូវមានលក្ខខណ្ឌដូចខាងក្រោម៖

- ✓ សមាជិក ម.ជ.ម. ពីររូបអាចស្នើតែងតាំងសមាជិក ប.ជ.ប. បានតម្នាក់ប៉ុណ្ណោះធ្វើជាបេក្ខជន
- ✓ សំណើតែងតាំងបេក្ខជនត្រូវមានការយល់ព្រមពីសាមីខ្លួនផ្ទាល់
- ✓ សំណើតែងតាំងត្រូវធ្វើជាលាយលក្ខណ៍អក្សរ និងមានចុះហត្ថលេខា។

បើសិនបេក្ខជនឈរឈ្មោះមានចំនួនតិចជាង ឬស្មើនឹងតំណែងដែលត្រូវបោះឆ្នោតរើស សម្រាប់ធ្វើជាសមាជិកក្រុមប្រឹក្សាប្រតិបត្តិ ការជ្រើសរើសត្រូវពន្យាររយៈពេល១៥(ដប់ប្រាំ) ថ្ងៃទៀត។ ក្រោយរយៈពេលពន្យា១៥(ដប់ប្រាំ) ថ្ងៃ ប្រសិនបើបេក្ខជននៅតមានចំនួនតិចជាង ឬស្មើនឹងតំណែងដែលត្រូវបោះឆ្នោតជ្រើសរើស

បេក្ខជនទាំងនោះត្រូវចាត់ទុកថាជាប់ឆ្នោតដោយស្វ័យប្រវត្តិ។ ក្នុងករណីដែលបេក្ខជនឈរឈ្មោះមិនគ្រប់ចំនួនមហាសន្និបាតអាចតែងតាំងបេក្ខជនបន្ថែមតាមនីតិវិធីដដែល។ ក្នុងករណីដែលបេក្ខជនមានចំនួនលើសពីចំនួនតំណែង ដែលត្រូវជ្រើសរើស មហាសន្និបាតត្រូវធ្វើការបោះឆ្នោត ។

សមាជិកក្រុមប្រឹក្សាប្រតិបត្តិត្រូវបាត់បង់មុខតំណែងក្នុងករណីដូចខាងក្រោម៖

- ✓ ក្លាយជាអសមត្ថជនផ្នែករូបរាងកាយ និងសតិស្មារតី មិនអាចបំពេញមុខងាររបស់ខ្លួនបាន
- ✓ ត្រូវបានផ្តន្ទាទោសពីបទល្មើសមជ្ឈិម ឬឧក្រិដ្ឋណាមួយ
- ✓ អវត្តមានពីកិច្ចប្រជុំ ៣ (បី)ដង ជាប់ៗគ្នាដោយគ្មានមូលហេតុ
- ✓ ត្រូវបានវិនិច្ឆ័យថា ក្ស័យធនដោយតុលាការ
- ✓ សុំលាលែងជាលាយលក្ខណ៍អក្សរពីក្រុមប្រឹក្សាប្រតិបត្តិ
- ✓ លែងជាសមាជិករបស់ ម.ជ.ម.
- ✓ លែងជាតំណាងចាត់តាំងរបស់អង្គការសមាជិក
- ✓ ទទួលមរណភាព។

ក្រៅពីការប្រជុំប្រចាំខែ ប្រធានក្រុមប្រឹក្សាប្រតិបត្តិ អាចកោះប្រជុំក្រុមប្រឹក្សាប្រតិបត្តិពេលណាក៏បាន ដោយជូនដំណឹងទៅកាន់សមាជិកក្រុមប្រឹក្សាប្រតិបត្តិ រយៈពេល ៧ (ប្រាំពីរ) ថ្ងៃជាមុន។ យ៉ាងហោចណាស់ត្រូវមានសមាជិក២/៣ (ពីរភាគបី) វត្តមាន ដើម្បីឱ្យដំណើរការប្រជុំមានសុពលភាព។ បញ្ហានានាដែលត្រូវបានលើកឡើងមកពិភាក្សា នៅក្នុងកិច្ចប្រជុំក្រុមប្រឹក្សាប្រតិបត្តិ ត្រូវសម្រេចដោយសំឡេងភាគច្រើន ហើយក្នុងករណីមានសំឡេងស្មើគ្នា សំឡេងប្រធានមានឧត្តមានុភាព។

ក្នុងករណីមានសមាជិកក្រុមប្រឹក្សាប្រតិបត្តិបាត់បង់សមាជិកភាពរបស់ខ្លួន ប្រធាន ម.ជ.ម. ត្រូវការប្រជុំសន្និបាតវិសាមញ្ញ ដើម្បីធ្វើការជ្រើសរើសសមាជិកបង្គ្រប់។ អាណត្តិរបស់សមាជិកជំនួសនេះជាអាណត្តិរបស់សមាជិក ដែលបានបាត់បង់សមាជិកភាព។ក្រុមប្រឹក្សាប្រតិបត្តិ អាចបង្កើតគណៈកម្មាធិការ ឬអនុគណៈកម្មាធិការនានា ដែលមានសមាសភាពសមាជិក ក្រុមប្រឹក្សាប្រតិបត្តិមួយរូប ឬច្រើនរូបដឹកនាំការងារ ការរៀបចំគណៈកម្មាធិការ ឬអនុគណៈកម្មាធិការនានាត្រូវកំណត់ដោយបទបញ្ជាផ្ទៃក្នុងរបស់ ម.ជ.ម. ។[29]

### ២.៤.៣. អគ្គលេខាធិការដ្ឋាន

អគ្គលេខាធិការដ្ឋាន ម.ជ.ម. ត្រូវដឹកនាំដោយអគ្គលេខាធិការមួយរូប អមដោយអគ្គលេខាធិការរងមួយចំនួនជាជំនួយការ ដែលត្រូវជ្រើសរើសដោយក្រុមប្រឹក្សាប្រតិបត្តិ។ ការរៀបចំនិងការប្រព្រឹត្តទៅរបស់អគ្គលេខាធិការដ្ឋាននៃ ម.ជ.ម. ត្រូវកំណត់ដោយបទបញ្ជាផ្ទៃក្នុង។

[29] អនុក្រឹត្យលេខ ១២៤ អនក្រ.បក ថ្ងៃទី១២ ខែសីហា ឆ្នាំ២០០៩

អគ្គលេខាធិការដ្ឋាន ប.ជ.ស. មានតួនាទីជាសេនាធិការឱ្យក្រុមប្រឹក្សាប្រតិបត្តិ និងមានភារកិច្ចដូចខាងក្រោម៖

- ✓ គ្រប់គ្រងលើការងារនិងសកម្មភាពប្រចាំថ្ងៃរបស់ ម.ជ.ម.
- ✓ អនុវត្តគោលនយោបាយដែលក្រុមប្រឹក្សាប្រតិបត្តិដាក់ចេញ
- ✓ រៀបចំកិច្ចប្រជុំរបស់ក្រុមប្រឹក្សាប្រតិបត្តិ មហាសន្និបាត និងកិច្ចប្រជុំផ្សេងទៀត
- ✓ រក្សាឯកសារ
- ✓ ប្រមូលព័ត៌មានដែលពាក់ព័ន្ធនិងសកម្មភាពមជ្ឈត្តការផ្នែកពាណិជ្ជកម្មដែលអាចមានប្រយោជន៍ដល់សមាជិករបស់ ម.ជ.ម.
- ✓ ផ្តួចផ្តើមគំនិតលើកិច្ចការថ្មី១ និងរៀបចំសកម្មភាព និងគម្រោងនានាដែលជួយទ្រទ្រង់តួនាទីរបស់ ម.ជ.ម.
- ✓ ផ្តល់សេវាផ្នែកលេខាធិការដល់សមាជិក ដោយយកកម្រៃសេវាស្របតាមលក្ខខណ្ឌ ដែលអនុម័តដោយក្រុមប្រឹក្សាប្រតិបត្តិ
- ✓ ទ្រទ្រង់ផ្នែកបោះពុម្ពនានារបស់ ម.ជ.ម. រួមទាំងកាន់កាប់គេហទំព័ររបស់ ម.ជ.ម.
- ✓ រៀបចំការបណ្តុះបណ្តាល
- ✓ បំពេញភារកិច្ចផ្សេងៗដែលក្រុមប្រឹក្សាប្រតិបត្តិប្រគល់ជូន ។[30]

## ២.៥ តួនាទីនិងភារកិច្ច

ម.ជ.ម. ជាអង្គភាពមិនស្វែងរកប្រាក់ចំណេញនិងមានទីស្នាក់ការនៅរាជធានីភ្នំពេញ ដែល ម.ជ.ម. មានតួនាទីនិងភារកិច្ចដូចខាងក្រោម៖

- ✓ ជំរុញវិស័យមជ្ឈត្តការផ្នែកពាណិជ្ជកម្មនៅក្នុងព្រះរាជាណាចក្រកម្ពុជា
- ✓ ផ្តល់ការបណ្តុះបណ្តាលនិងហ្វឹកហ្វឺនបុគ្គលដែលកំពុងអនុវត្តនិងបុគ្គលដែលមានបំណងអនុវត្តវិជ្ជាជីវៈជាមជ្ឈត្តករ ដើម្បីធានាឱ្យមជ្ឈត្តការផ្នែកពាណិជ្ជកម្មនៅក្នុងព្រះរាជាណាចក្រកម្ពុជាមានគុណភាពខ្ពស់
- ✓ កំណត់ពីលក្ខណសម្បត្តិនៃបុគ្គល ដែលមានបំណងចូលជាសមាជិក ម.ជ.ម.
- ✓ រៀបចំសន្និសីទថ្នាក់ជាតិនិងអន្តរជាតិ ក្នុងគោលដៅជំរុញវិស័យមជ្ឈត្តការផ្នែកពាណិជ្ជកម្ម
- ✓ រៀបចំ ចូលរួមសិក្ខាសាលានិងវគ្គសិក្សា លើប្រធានបទទាក់ទងនឹងមជ្ឈត្តការផ្នែកពាណិជ្ជកម្ម
- ✓ ប្រមូល បោះពុម្ព និងផ្សព្វផ្សាយព័ត៌មាន អត្ថបទនិពន្ធសៀវភៅនិងឯកសា សោតទស្សន៍ឬហ្វូណូក្រាម ដែលទាក់ទងនឹងមជ្ឈត្តការផ្នែកពាណិជ្ជកម្ម

[30] អនុក្រឹត្យលេខ ១២៤ អនក្រ.បក ថ្ងៃទី១២ ខែសីហា ឆ្នាំ២០០៩

- ✓ គ្រប់គ្រងនិងចាត់ចែងទ្រព្យសម្បត្តិ ម.ជ.ម.
- ✓ រៀបចំបណ្ណាល័យនិងបន្ទប់ផ្សេងៗ សម្រាប់បម្រើសេវាទាក់ទងនឹងមជ្ឈត្តការផ្នែកពាណិជ្ជកម្ម
- ✓ ចុះកិច្ចព្រមព្រៀងនានាដែលចាំបាច់ក្នុងការបំពេញមុខងាររបស់ខ្លួន
- ✓ បំពេញភារកិច្ចផ្សេងៗទៀតតាមការកំណត់របស់មហាសន្និបាត ម.ជ.ម. ។
- ✓ ម.ជ.ម. មានសិទ្ធិប្រើត្រាដោយឡែករបស់ខ្លួន។[31]

[31] អនុក្រឹត្យលេខ ១២៤ អនក្រ.បក ថ្ងៃទី១២ ខែសីហា ឆ្នាំ២០០៩

# ជំពូកទី៣

# នីតិវិធីនៃមជ្ឈត្តការពាណិជ្ជកម្ម

# ជំពូកទី៣
# នីតិវិធីនៃមជ្ឈត្តការពាណិជ្ជកម្ម

នីតិវិធីនៃមជ្ឈត្តកម្មពាណិជ្ជកម្មធម្មតាជាទូទៅមាន ៦ (ប្រាំមួយ) ដំណាក់កាលគឺ:

១. ការចាប់ផ្តើមនៃមជ្ឈត្តកម្ម

២. ការជ្រើសរើសវេទិកាមជ្ឈត្តក

៣. នីតិវិធីមុនសវនាការ

៤. សវនាការមជ្ឈត្តការ

៥. ការសម្រេច

៦. បណ្តឹងឧបាស្រ័យ និងការអនុវត្តមជ្ឈត្តវិនិច្ឆ័យ

ដំណាក់កាលទាំងនេះសំដៅទៅលើបទប្បញ្ញត្តិនៃច្បាប់ថ្មីរបស់កម្ពុជាស្តីពីមជ្ឈត្តកម្មពាណិជ្ជកម្ម (ច្បាប់ស្តីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្ម)។ នៅក្នុងខែមិថុនា ឆ្នាំ ២០០៦ នៃច្បាប់ស្តីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្មរបស់ប្រទេសកម្ពុជាបានចូលជាធរមាន។ ប្រទេសកម្ពុជាមានកាតព្វកិច្ចក្នុងការអនុម័តច្បាប់នៅពេលដែលខ្លួនបានចូលរួមជាមួយអង្គការពាណិជ្ជកម្មពិភពលោក ("WTO") ក្នុងឆ្នាំ ២០០៤។

## ៣.១. ការចាប់ផ្តើមនៃមជ្ឈត្តកម្ម

នៅក្នុងដំណាក់កាលនេះមានវិធីបីយ៉ាងដែលមជ្ឈត្តកម្មអាចដំណើរការបាន៖

- ✓ ការស្នើឱ្យមានដំណើរការមជ្ឈត្តកម្មក្រោមកិច្ចព្រមព្រៀងមជ្ឈត្តការដែលមានស្រាប់
- ✓ ការចុះកិច្ចព្រមពៀងឱ្យមានមជ្ឈត្តការនៅពេលវិវាទកើតឡើង និង
- ✓ អនុលោមតាមមជ្ឈត្តកម្មដែលបញ្ជាដោយតុលាការ។

វិធីទីមួយនៃដំណាក់កាលនេះ ការស្នើឱ្យមានដំណើរការមជ្ឈត្តកម្មក្រោមកិច្ចព្រមព្រៀងមជ្ឈត្តការដែលមានស្រាប់ គឺជាវិធីដែលទូទៅ និងមានភាពពេញនិយមជាងគេ។

### ៣.១.១. ការដាក់ពាក្យបណ្តឹងរបស់ភាគីប្តឹងទាមទារ

ប្រសិនបើភាគីមានកិច្ចព្រមព្រៀងមជ្ឈត្តកម្មដែលមានពីមុនមក ដែលជាធម្មតាជាផ្នែកមួយនៃកិច្ចសន្យាដើមដែល ភាគីមួយត្រូវតែបង្ហាញឱ្យភាគីម្ខាងទៀតនូវសំណើជាលាយលក្ខណ៍អក្សរ ឬ "សេចក្តីជូនដំណឹងអំពីមជ្ឈត្តកម្ម" សម្រាប់មជ្ឈត្តការ។ [32] នៅក្រោមច្បាប់ស្តីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្មសំណើជាលាយលក្ខណ៍អក្សរនោះគួរតែត្រូវបានបញ្ជូនទៅភាគីម្ខាងទៀតដោយផ្ទាល់ ឬទីកន្លែងអាជីវកម្ម ទីលំនៅ ឬអាសយដ្ឋានផ្ញើសំបុត្រ។

[32] ច្បាប់ស្តីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្ម, មាត្រា ៣, ឆ្នាំ២០០៦

ភាគីដែលចាប់ ផ្ដើមមជ្ឈត្តកម្មត្រូវបានគេស្គាល់ថាជា "ភាគីប្ដឹងទាមទារ" ហើយភាគីដែលទទួលសំណើនេះត្រូវបានគេស្គាល់ថាជា "ភាគីឆ្លើយតប" ។[33] ដំណើរការមជ្ឈត្តកម្មចាប់ផ្ដើមនៅថ្ងៃដែលភាគីប្ដឹងទាមទារបានសេចក្ដីជូនដំណឹងអំពីមជ្ឈត្តកម្ម ឬពេលដែលភាគីឆ្លើយតបបានទទួលដំណឹងអំពីការជូនដំណឹងអំពីមជ្ឈត្តកម្ម។[34]

ឧបមាថាភាគីបានជ្រើសរើសច្បាប់មជ្ឈត្តកម្ម UNCITRAL ច្បាប់មជ្ឈត្តកម្មអន្តរជាតិ AAA ឬ ICC វិធានមជ្ឈត្តកម្មនៅក្នុងកិច្ចព្រមព្រៀងមជ្ឈត្តកម្មរបស់ពួកគេ។ ក្នុងករណីនោះ សំណើឬការជូនដំណឹងរបស់ពួកគេត្រូវតែត្រូវបានកំណត់ក្នុងចំណោមអ្វីផ្សេងទៀត:

- ✓ ឈ្មោះនិងព័ត៌មានលម្អិតរបស់ភាគី;
- ✓ ការពិពណ៌នាអំពីជម្លោះ;
- ✓ សេចក្ដីថ្លែងការណ៍នៃការសង្គ្រោះបានស្វែងរក; និង
- ✓ កិច្ចព្រមព្រៀងពាក់ព័ន្ធទាំងអស់ រួមទាំងកិច្ចព្រមព្រៀងមជ្ឈត្តកម្ម។

ប្រសិនបើភាគីបានជ្រើសរើសមជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការផ្នែកពាណិជ្ជកម្ម ("ម.ជ.ម.") ពួកគេនឹងត្រូវអនុវត្តតាមវិធានស្ដីពីមជ្ឈត្តការរបស់ម.ជ.ម. ទោះយ៉ាងណាក៏ដោយ បើសិនជាភាគីមិនបានជ្រើសរើសច្បាប់ណាមួយនៅក្នុងកិច្ចព្រមព្រៀងមជ្ឈត្តកម្មរបស់ពួកគេនោះទេ ក្នុងករណីនោះច្បាប់ស្ដីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្មត្រូវផ្ដល់នូវបទបញ្ញត្តិលំនាំដើម ដែលភាគីត្រូវដាក់សេចក្ដីថ្លែងការទាមទារដែលត្រូវតែមាន៖

- ✓ ការអង្គហេតុដែលគាំទ្រការទាមទារ
- ✓ ចំណុចនៃបញ្ហា និង
- ✓ ដំណោះស្រាយដែលខ្លួនចង់បាន។

### ៣.១.២. ការដាក់ពាក្យរបស់ភាគីឆ្លើយតប

នៅពេលដែលការដាក់ស្នើដំបូងនេះត្រូវបានធ្វើឡើង ភាគីឆ្លើយតបត្រូវតែដាក់សេចក្ដីថ្លែងការណ៍មួយនៅក្រោមច្បាប់ស្ដីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្មនិង ច្បាប់ UNCITRAL ហើយភាគីឆ្លើយត្រូវដាក់សេចក្ដីថ្លែងការណ៍ការពារ ដែលឆ្លើយតបទៅនឹងការទាមទារដាក់លាក់ និងរួមបញ្ចូលឯកសារពាល់ព័ន្ធ និងបណ្ដឹងឆ្លើយតបទៅនឹងបញ្ហាផងដែរ។ ក្នុងករណីនេះ ការកំណត់ពេលវេលាត្រូវបានកំណត់យោងទៅតាមច្បាប់គ្រប់គ្រងដែលភាគីបានព្រមព្រៀងគ្នា។ យោងតាមវិធានស្ដីពីមជ្ឈត្តការ ឆ្នាំ២០២១ បានចែងថា ក្នុងរយៈពេល ១៥ ថ្ងៃ ភាគីឆ្លើយតបត្រូវបញ្ជូនសេចក្ដីជូនដំណឹងអំពីការឆ្លើយតបទៅអគ្គលេខាធិការដ្ឋាន។[35] រីឯវិធានមជ្ឈត្តការ AAA[36] និងវិធាន

[33] ប្រការ ៧.១ នៃវិធានស្ដីពីមជ្ឈត្តការរបស់មជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការផ្នែកពាណិជ្ជកម្ម ឆ្នាំ២០២១

[34] ច្បាប់ស្ដីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្ម, មាត្រា ២៩, ឆ្នាំ២០០៦

[35] ប្រការ ៨.១ នៃវិធានស្ដីពីមជ្ឈត្តការរបស់មជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការផ្នែកពាណិជ្ជកម្ម ឆ្នាំ២០០៦

[36] មាត្រា៣ នៃវិធានមជ្ឈត្តការ AAA

មជ្ឈត្តការ ICC[37] ភាគីឆ្លើយតបមានពេល ៣០ ថ្ងៃចាប់ពីថ្ងៃបានទទួលសេចក្តីជូនដំណឹងដើមដើម្បីដាក់ឯកសារសេចក្តីថ្លែងការណ៍ដោះសារ (ICC ហៅវាថា "ការឆ្លើយតប") និងការទាមទារសំណង។

## ៣.២. ការជ្រើសរើស និងការជំទាស់ទៅនឹងវេទិកាមជ្ឈត្តកម្ម

### ៣.២.១ ការជ្រើសរើសមជ្ឈត្តករ

បន្ទាប់ពីដាក់ពាក្យបណ្តឹងទាមទារដំបូង ភាគីត្រូវជ្រើសរើសវេទិកាមជ្ឈត្តកម្ម។ នៅក្រោមច្បាប់ស្តីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្ម ភាគីមានសេរីភាពក្នុងការកំណត់ចំនួនមជ្ឈត្តករ ប៉ុន្តែចំនួននៃមជ្ឈត្តករត្រូវជាតែជាលេខសេស។ [38] អវត្តមាននៃការកំណត់បែបនេះ ចំនួននៃមជ្ឈត្តករមានបីរូបនឹងត្រូវបានតែងតាំងដោយតុលាការ ឬមជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការផ្នែកពាណិជ្ជកម្ម [39] ហើយភាគីមានសេរីភាពក្នុងការជ្រើសរើសវិធីសាស្រ្តណាមួយដើម្បីជ្រើសរើសមជ្ឈត្តករ។ ជាធម្មតា ពួកគេនឹងធ្វើតាមវិធីសាស្រ្តជ្រើសរើសនៃមជ្ឈមណ្ឌលមជ្ឈត្តកម្មដែលបានជ្រើសរើស ដូចជា AAA, ICC ឬ ម.ជ.ម.។ ប្រសិនបើពួកគេមិនជ្រើសរើសទម្រង់ណាមួយនោះទេ ច្បាប់ស្តីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្មត្រូវបានអនុវត្តឱ្យភាគីនីមួយៗ តែងតាំងមជ្ឈត្តករម្នាក់ ហើយមជ្ឈត្តករទាំងពីរតែងតាំងមជ្ឈត្តករ។ [40]បើមានមជ្ឈត្តករតែម្នាក់ និងភាគីមិនបានចាត់តាំងមជ្ឈមណ្ឌលមជ្ឈត្តកម្មជាអ្នកគ្រប់គ្រងទេ ហើយពួកគេមិនអាចយល់ព្រមលើមជ្ឈត្តករនោះទេ តុលាការកម្ពុជា ឬមជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការផ្នែកពាណិជ្ជកម្មនឹងធ្វើការណាត់ជួបតាមការស្នើសុំ។

### ៣.២.២. ការជំទាស់នឹងមជ្ឈត្តករដែលបានជ្រើសរើស

នៅក្រោមច្បាប់ស្តីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្ម មជ្ឈត្តករត្រូវតែបង្ហាញមុនពេលតែងតាំងនូវកាលៈទេសៈណាមួយ "ដែលអាចបង្កឱ្យមានការសង្ស័យដែលអាចសមហេតុផលអំពីភាពមិនលំអៀង ឬឯករាជ្យភាពរបស់គាត់" នេះអាចរាប់បញ្ចូលទាំងទំនាស់ផលប្រយោជន៍ជាមួយភាគីមួយ ឬច្រើន។[41] មជ្ឈត្តករអាចត្រូវបានជំទាស់ដោយហេតុផលពីរយ៉ាង៖ ១) "ប្រសិនបើមានកាលៈទេសៈដែលនាំឱ្យមានការសង្ស័យដែលអាចសមហេតុផលចំពោះភាពមិនលំអៀងឬឯករាជ្យរបស់គាត់" ឬ ២) "ប្រសិនបើគាត់មិនមានលក្ខណៈសម្បត្តិដែលយល់ព្រមដោយភាគី" ។ ក្នុងអំឡុងពេលចុះកិច្ចសន្យា ភាគីអាចយល់ព្រមចំពោះនីតិវិធីប្រឈមណាមួយ រួមទាំងអ្វីដែលមាននៅក្នុងច្បាប់ម.ជ.ម. ICC ឬ AAA ផងដែរ។ អវត្តមាននៃកិច្ចព្រមព្រៀងបែបនេះ ច្បាប់ស្តីពីមជ្ឈត្តការផ្នែក

[37] មាត្រា ៥ នៃវិធានមជ្ឈត្តការ ICC

[38] មាត្រា ១៨ នៃច្បាប់ស្តីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្ម ឆ្នាំ២០០៦

[39] មាត្រា ១៩ វាក្យខណ្ឌទី៣.ក នៃច្បាប់ស្តីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្ម ឆ្នាំ២០០៦

[40] ប្រការ ២៥.២ នៃវិធានស្តីពីមជ្ឈត្តការរបស់មជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការផ្នែកពាណិជ្ជកម្ម ឆ្នាំ២០០៦

[41] មាត្រា ២០ នៃច្បាប់ស្តីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្ម ឆ្នាំ២០០៦

ពាណិជ្ជកម្មផ្តល់នឹងត្រូវបានអនុវត្ត។ ទីមួយ ភាគីដែលជំទាស់ត្រូវធ្វើសេចក្តីថ្លែងការណ៍ជាលាយលក្ខណ៍អក្សរ ដោយផ្តល់ហេតុផលសម្រាប់ការជំទាស់នេះក្នុងរយៈពេល ១៥ ថ្ងៃបន្ទាប់ពីដឹងពីកាលៈទេសៈលំបាក ឬការតែងតាំងមានបញ្ហា។[42] បន្ទាប់មក វេទិកាមជ្ឈត្តកម្មនឹងពិចារណា និងសម្រេចថាតើត្រូវយល់ព្រមជាមួយបញ្ហាប្រឈមដែរឬទេ។ ប្រសិនបើយល់ព្រម មជ្ឈត្តករថ្មីត្រូវបានតែងតាំង ប្រសិនបើមានការមិនយល់ស្របទេ មជ្ឈត្តករដែលចោទសួរនៅតែមាននៅក្នុងវេទិកាមជ្ឈត្តកម្ម។ បន្ទាប់មក ភាគីដែលមានបញ្ហាអាចប្តឹងឧបាស្រ័យលើសេចក្តីសម្រេចរបស់វេទិកាមជ្ឈត្តកម្មក្នុងរយៈពេល 30 ថ្ងៃទៅកាន់តុលាការកម្ពុជា ឬ ម.ជ.ម. ។

### ៣.២.៣ ការជំទាស់នឹងយុត្តាធិការរបស់វេទិកាមជ្ឈត្តកម្ម

ច្បាប់ស្តីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្ម មាត្រា ៨ ចែងថា "តុលាការកម្ពុជាត្រូវបញ្ជូនសំណុំរឿងទៅមជ្ឈត្តកម្ម ប្រសិនបើមានកិច្ចព្រមព្រៀងត្រឹមត្រូវ" ។[43] ទោះជាយ៉ាងណាក៏ដោយ ភាគីទាំងពីរក៏អាចជំទាស់នឹងយុត្តាធិការរបស់វេទិកា មជ្ឈត្តកម្មដើម្បីស្តាប់រឿងក្តីមួយផ្នែក ឬទាំងអស់ផងដែរ។ ឧទាហរណ៍ ភាគីមួយអាចប្រកែកថាខ្លួនមិនដែលបានយល់ព្រមក្នុងមជ្ឈត្តកម្មវិវាទណាមួយឡើយ ហើយចង់យកការទាមទារនោះទៅដោះស្រាយតាមប្រព័ន្ធតុលាការ។ ភាគីត្រូវតែលើកការទាមទារជាមួយវេទិកាមជ្ឈត្តការជាមុនសិន។ វេទិកាមជ្ឈត្តកម្ម "អាចគ្រប់គ្រងលើដែនសមត្ថកិច្ចរបស់ខ្លួន រួមទាំងការជំទាស់ណាមួយទាក់ទងនឹងអត្ថិភាព ឬសុពលភាពនៃកិច្ចព្រមព្រៀងមជ្ឈត្តកម្ម"[44] ដែលមានភាពស្រដៀងគ្នាទៅនឹងច្បាប់មជ្ឈត្តកម្ម UNCITRAL, AAA, និង ICC ។

ភាគីដែលមានការជំទាស់ ឬមានបញ្ហាត្រូវលើកបញ្ហានេះនៅ ឬមុនពេលកំណត់សម្រាប់ការដាក់សេចក្តីថ្លែងការណ៍សម្រាប់ការដោះសារ ហើយសេចក្តីសម្រេចរបស់វេទិកាមជ្ឈត្តកម្មស្តីពីយុត្តាធិការអាចត្រូវបានប្តឹងឧទ្ធរណ៍ទៅតុលាការកម្ពុជាក្នុងរយៈពេល 30 ថ្ងៃបន្ទាប់ពីការសម្រេចរបស់វេទិកាមជ្ឈត្តកម្ម ។[45]

## ៣.៣. នីតិវិធីមុនសវនាការ

ដំណើរការមុនសវនាការបង្កើតជាដំណាក់កាលបន្ទាប់។ នៅពេលដែលមជ្ឈត្តករត្រូវបានជ្រើសរើស ហើយយុត្តាធិការត្រូវបានកំណត់ ភាគីវិវាទមានបញ្ហាសំខាន់ៗមួយចំនួនដែលត្រូវដោះស្រាយ ហើយជាធម្មតាវាត្រូវបានសម្រេចក្នុងអំឡុងពេលប្រជុំមុនសវនាការដែលនីតិវិធីទីតាំង និងភស្តុតាង និងបញ្ហាផ្សេងទៀតត្រូវបានសម្រេចក្នុងដំណើរការមជ្ឈត្តកម្មនេះផងដែរ។

---

[42] មាត្រា ២១ ច្បាប់ស្តីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្ម ឆ្នាំ២០០៦

[43] មាត្រា ៨ ច្បាប់ស្តីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្ម ឆ្នាំ២០០៦

[44] មាត្រា ២៤-១ ច្បាប់ស្តីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្ម ឆ្នាំ២០០៦

[45] មាត្រា ២៤ ច្បាប់ស្តីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្ម ឆ្នាំ២០០៦

### ៣.៣.១. វិធានស្តីពីនីតិវិធី

ច្បាប់ស្តីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្ម ភាគីវិវាទអាចធ្វើការកំណត់បាននូវច្បាប់នីតិវិធីផ្ទាល់ខ្លួនរបស់ពួកគេ។ មជ្ឈមណ្ឌលមជ្ឈត្តកម្មផ្សេងៗបានបង្កើតច្បាប់ជាច្រើន ហើយភាគីទាំងសងខាងជាទូទៅអនុម័តយកច្បាប់នៃមជ្ឈមណ្ឌលដែលពួកគេបានជ្រើសរើស។ ក្នុងករណីដែលគ្មានច្បាប់នីតិវិធីដែលបានព្រមព្រៀង ច្បាប់ស្តីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្មបានចែងថាវេទិកាមជ្ឈត្តកម្មនឹងដំណើរការនីតិវិធីក្នុងលក្ខណៈមួយ ឬរបៀបមួយដែលខ្លួនចាត់ទុកថាសមស្រប។[46]

### ៣.៣.២ ទីកន្លែងនៃមជ្ឈត្តកម្ម

ភាគីវិវាទមានសេរីភាពក្នុងការកំណត់ទីកន្លែងនៃមជ្ឈត្តកម្មនៅក្នុងកិច្ចព្រមព្រៀងរបស់ពួកគេ។ ប្រសិនបើពួកគេមិនយល់ស្រប ទីកន្លែងនៃមជ្ឈត្តកម្មនឹងត្រូវកំណត់ដោយវេទិកាមជ្ឈត្តកម្ម "ដោយពិចារណាអំពីកាលៈទេសៈនៃសំណុំរឿង..."[47] លុះត្រាតែមានការយល់ព្រមពីភាគីផ្សេងវេទិកាមជ្ឈត្តកម្មអាចជួបនៅកន្លែងណាមួយដែលវាចាត់ទុកថាសមរម្យសម្រាប់ការពិគ្រោះយោបល់ក្នុងចំណោមរបស់ខ្លួន។[48]

### ៣.៣.៣. ភាសា

ភាគីមានសេរីភាពក្នុងការយល់ព្រមលើភាសាណាមួយ ឬលើសពីមួយនៃដំណើរការនីតិវិធីមជ្ឈត្តការរបស់ពួកគេ។ ប្រសិនបើពួកគេមិនយល់ស្របនោះ វេទិកាមជ្ឈត្តកម្មនឹងធ្វើការសម្រេចទៅលើភាសាណាមួយ ឬលើសពីមួយសម្រាប់ដំណើរការមជ្ឈត្តការ។[49]

### ៣.៣.៤. ការសម្របសម្រួល ឬសន្ធានកម្ម

ដូចដែលបានកត់សម្គាល់ ច្បាប់ស្តីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្ម ចែងអំពីលទ្ធភាពនៃការសម្រុះសម្រួល ឬការធ្វើសន្ធានកម្ម។ ច្បាប់ស្តីពី មជ្ឈត្តការផ្នែកពាណិជ្ជកម្ម មាត្រា ៣៨ ចែងថា "មុនពេលចាប់ផ្តើមដំណើរការមជ្ឈត្តការផ្លូវការ វេទិកាមជ្ឈត្តកម្មត្រូវពិភាក្សាជាមួយភាគីវិវាទ ដើម្បីស្វែងរកមានលទ្ធភាពនៃដំណោះស្រាយវិវាទដោយស្ម័គ្រចិត្តរបស់ភាគី៖ ១. ប្រសិនបើភាគីវិវាទព្រមដោះស្រាយវិវាទដោយស្ម័គ្រចិត្ត វេទកាមជ្ឈត្តកម្មត្រូវជួយភាគីវិវាទទៅតាមលក្ខណៈដែលសមស្រប"។[50]

---

[46] មាត្រា ២៧ ច្បាប់ស្តីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្ម ឆ្នាំ២០០៦

[47] មាត្រា ២៨ នៃច្បាប់ស្តីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្ម ឆ្នាំ២០០៦

[48] មាត្រា ២៧ នៃច្បាប់ស្តីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្ម ឆ្នាំ២០០៦

[49] មាត្រា ៣០ នៃច្បាប់ស្តីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្ម ឆ្នាំ២០០៦

[50] មាត្រា ៣៨ នៃច្បាប់ស្តីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្ម ឆ្នាំ២០០៦

### ៣.៣.៥ វិធានការបណ្ដោះអាសន្ន

វិធានការបណ្ដោះអាសន្នគឺចាំបាច់សម្រាប់ស្ថានភាពខ្លះ ភស្តុតាងចាំបាច់អាចប្រឈមនឹងការថយចុះ ឬការបំផ្លិចបំផ្លាញ លុះត្រាតែភាគីទីបីធានាវាឱ្យបានត្រឹមត្រូវ។ ម៉្យាងទៀត ភាគីម្ខាងតម្រូវឱ្យភាគីម្ខាងទៀតបញ្ឈប់សកម្មភាពមួយចំនួនភ្លាមៗ។ ដូចច្បាប់មជ្ឈមណ្ឌលមជ្ឈត្តកម្មដទៃទៀតដែរ ច្បាប់ស្តីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្មផ្តល់អំណាចដល់វេទិកាមជ្ឈត្តកម្មក្នុងការផ្តល់វិធានការបណ្ដោះអាសន្នទាំងនេះ។ វេទិកាមជ្ឈត្តកម្មអាចតម្រូវឱ្យភាគីផ្តល់សន្តិសុខសមស្របជាមួយនឹងវិធានការបែបនេះ។

ភាគីមួយក៏អាចស្នើសុំវិធានបណ្ដោះអាសន្នពីតុលាការកម្ពុជាបានដែរ។ ច្បាប់ស្តីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្ម បាននិយាយថា "មិនមានវិសមិតភាពគ្នានឹងកិច្ចព្រមព្រៀងមជ្ឈត្តកម្មសម្រាប់ភាគីមួយដើម្បីស្នើសុំមុនពេល ឬក្នុងអំឡុងពេលដំណើរការមជ្ឈត្តកម្មពីតុលាការនូវវិធានការការពារបណ្ដោះអាសន្ន និងសម្រាប់តុលាការដើម្បីផ្តល់វិធានការបែបនេះ" [51] ឃ្លានេះអាចជាបញ្ហាដ៏មានសក្តានុពលសម្រាប់ភាគីបរទេសដែលចង់ជៀសវាងប្រព័ន្ធតុលាការក្នុងស្រុក។ វិធីមួយដើម្បីជៀសវាងការនេះគឺត្រូវបញ្ចូលសមស្របភាសាទៅក្នុងឃ្លាមជ្ឈត្តកម្ម ដែលរារាំងភាគីណាមួយពីការប្តឹងទៅតុលាការសម្រាប់វិធានការបណ្ដោះអាសន្ន។

### ៣.៣.៦. អ្នកជំនាញ

ច្បាប់ស្តីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្ម ផ្តល់អំណាចដល់វេទិកាមជ្ឈត្តកម្មក្នុងការតែងតាំងអ្នកជំនាញ លុះត្រាតែភាគីទាំងពីរព្រមព្រៀងផ្សេងពីនេះ។ ភាគីត្រូវផ្តល់ឱ្យអ្នកជំនាញនូវរាល់ព័ត៌មានដែលពាក់ព័ន្ធ និងមានសិទ្ធិពិនិត្យអ្នកជំនាញក្នុងសវនាការបន្ទាប់ពីការសន្និដ្ឋានរបស់អ្នកជំនាញត្រូវបានដាក់ជូនវេទិកាមជ្ឈត្តកម្ម។[52]

## ៣.៤. សវនាការមជ្ឈត្តការ

ជាធម្មតាដំណើរការមជ្ឈត្តកម្មពាក់ព័ន្ធនឹងសវនាការដែលស្រដៀងនឹងការកាត់ក្តីនៅក្នុងតុលាការច្បាប់ common law។ ភាគីវិវាទបង្ហាញសេចក្តីថ្លែងការណ៍ដោយបញ្ជាក់ពីអង្គហេតុ និងអង្គច្បាប់។ បន្ទាប់មក ភាគីប្តឹងទាមទារបង្ហាញសាក្សី ភស្តុតាង និងឯកសារពាក់ព័ន្ធរបស់ខ្លួន។ សាក្សីត្រូវធ្វើការស្បថចូលកាន់តំណែងដូចក្នុងដំណើរការរបស់តុលាការ។ នៅពេលនោះវេទិកាមជ្ឈត្តកម្មនឹងសម្រេចថាតើសាក្សីដែលមិនមែនជាភាគីអាចមានវត្តមាននៅក្នុងអំឡុងពេលមជ្ឈត្តកម្មដែរឬទេ។

ភាគីប្តឹងទាមទារ ឬមេធាវីរបស់ខ្លួននឹងធ្វើការចោទសួរនៅចំពោះមុខវេទិកាមជ្ឈត្តកម្ម។ ជួនកាលវេទិកាមជ្ឈត្តកម្មនឹងសួរសំណួរបន្ថែម ស្រដៀងនឹងចៅក្រមក្នុងតុលាការដែរ ហើយភាគីឆ្លើយតបក៏មានសិទ្ធិលើកសំណួរ

[51] មាត្រា ៩ នៃច្បាប់ស្តីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្ម ឆ្នាំ២០០៦

[52] មាត្រា ៣៤ នៃច្បាប់ស្តីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្ម ឆ្នាំ២០០៦

ទៅសាក្សីភាគីប្ដឹងទាមទារផងដែរ។[53] បន្ទាប់ពីដើមបណ្ដឹងបានបង្ហាញភស្តុតាងទាំងអស់របស់ខ្លួនហើយ ភាគីឆ្លើយតបមានឱកាសបង្ហាញសាក្សី ភស្តុតាង និងឯកសារពាក់ព័ន្ធវិញម្ដង ហើយជាថ្មីម្ដងទៀត វេទិកាមជ្ឈត្តកម្ម និងភាគីប្ដឹងទាមទារអាចសាកសួរសាក្សីទាំងនេះ។ បន្ទាប់មក ភាគីនឹងបង្ហាញសេចក្ដីថ្លែងការណ៍បិទបញ្ចប់ បន្ទាប់មកវេទិកាមជ្ឈត្តកម្មនឹងពិភាក្សា និងសម្រេចលើករណីនេះ។ សវនាការមជ្ឈត្តកម្មជាទូទៅមានលក្ខណៈផ្លូវការតិចជាងដំណើរការរបស់តុលាការ។ បញ្ហានីតិវិធី ឬ ភស្តុតាងមានភាពបត់បែនជាងនៅក្នុងតុលាការ ប្រសិនបើភាគីយល់ស្រប ពួកគេមិនត្រូវមានសវនាការផ្ទាល់មាត់ឡើយ។ ភាគីអាចជ្រើសរើសបង្ហាញតែភស្តុតាងជាឯកសារ និងឯកសារជាលាយលក្ខណ៍អក្សរសម្រាប់វេទិកាមជ្ឈត្តកម្មពិចារណា។ ទោះយ៉ាងណាក៏ដោយ ប្រសិនបើភាគីម្ខាងចង់ឲ្យមានសវនាការផ្ទាល់មាត់ ត្រូវតែមានសវនាការផ្ទាល់មាត់។ ច្បាប់ស្ដីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្មក៏តម្រូវឱ្យភាគីមានការជូនដំណឹងគ្រប់គ្រាន់អំពីសវនាការបែបនេះ។ មជ្ឈមណ្ឌលមជ្ឈត្តកម្មម.ជ.ម. ឬ AAA និង ICC មានសំណុំច្បាប់ផ្ទាល់ខ្លួន ដែលអាចកែប្រែបានដោយការព្រមព្រៀងរវាងភាគី។

## ៣.៥. ការសម្រេច

នៅពេលដែលសវនាការមជ្ឈត្តកម្មត្រូវបានបញ្ចប់ វេទិកាមជ្ឈត្តកម្មត្រូវពិចារណាលើសេចក្ដីសម្រេច។ ដូចដែលបានរៀបរាប់ខាងលើ នៅក្រោម ច្បាប់ស្ដីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្ម ភាគីអាចជ្រើសរើសអនុវត្តច្បាប់សំខាន់ៗនៃយុត្តាធិការណាមួយ។ នៅក្នុងករណីវេទិកាមជ្ឈត្តកម្មនៃមជ្ឈត្តច្រើនរូប មជ្ឈត្តវិនិច្ឆ័យ ឬសេចក្ដីសម្រេចផ្សេងៗ ត្រូវធ្វើឡើងដោយមតិភាគច្រើនដោយរបៀបនៃមជ្ឈត្តជាមសមាជិកនៃវេទិកាមជ្ឈត្តកម្មទាំងអស់។ [54] ជួនកាលនេះត្រូវបានគេហៅថាជាជម្រើសនៃបទប្បញ្ញត្តិច្បាប់នៅក្នុងកិច្ចព្រមព្រៀងរបស់ភាគី។ ក្នុងករណីដែលគ្មានជម្រើសនៃបទប្បញ្ញត្តិច្បាប់ វេទិកាមជ្ឈត្តកម្មមានសេរីភាពក្នុងការជ្រើសរើសច្បាប់សំខាន់ៗណាមួយដែលខ្លួនចាត់ទុកថាសមស្រប។

### ៣.៥.១. ទម្រង់នៃមជ្ឈត្តវិនិច្ឆ័យ

ដើម្បីចងកាតព្វកិច្ច និងអាចអនុវត្តបានតាមរយៈតុលាការ វេទិកាមជ្ឈត្តកម្មត្រូវ៖

- ✓ ធ្វើឡើងជាលាយលក្ខណ៍អក្សរ ហើយត្រូវចុះហត្ថលេខាដោយសម្លេងភាគច្រើនរបស់មជ្ឈត្តករ
- ✓ បញ្ជាក់ពីហេតុផលដែលមជ្ឈត្តវិនិច្ឆ័យយោងតាម ឬជាគោលបង្អែក

[53] "វិធីសាកសួរឆ្លង" នៅក្នុងប្រព័ន្ធតុលាការ common law

[54] ប្រការ ៤៧.១ នៃវិធានស្ដីពីមជ្ឈត្តការរបស់មជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការផ្នែកពាណិជ្ជកម្ម ឆ្នាំ២០២១

- ✓ បញ្ជាក់អំពីបែងចែកការចំណាយនៃមជ្ឈត្តកម្មនូវចំណែកដែលភាគីទាំងសងខាងត្រូវចេញ និងចំណាយផ្សេងៗដែលមាននៅក្នុងអំឡុងពេលដំណើរការនៃមជ្ឈត្តកម្មតាមដែលវេទិកាមជ្ឈត្តកម្មយល់ឃើញថា សមស្របលុះត្រាតែមានការយល់ព្រមផ្សេងទៀតពីភាគីវិវាទ
- ✓ បញ្ជាក់កាលបរិច្ឆេទ និងទីតាំងនៃមជ្ឈត្តកម្ម
- ✓ បន្ទាប់ពីធ្វើមជ្ឈត្តវិនិច្ឆ័យរួចហើយ អត្តបទចម្លងនៃមជ្ឈត្តវិនិច្ឆ័យនោះដែលចុះហត្ថលេខាពីមជ្ឈត្តករ ត្រូវបញ្ជូនទៅឱ្យភាគីវិវាទនីមួយៗ។[55]

រាល់ការទូទាត់ដែលបានឈានដល់ក្រោម ច្បាប់ស្តីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្មមាត្រា ៣៨ ត្រូវតែអនុវត្តតាមតម្រូវការទាំងនេះ ដើម្បីមានកម្លាំង និងប្រសិទ្ធភាពនៃការវិនិច្ឆ័យ។ ការទូទាត់ក៏ត្រូវបញ្ជាក់ផងដែរថាវាជាមជ្ឈត្តវិនិច្ឆ័យ។[56]

### ៣.៥.២. បណ្តឹងជំទាស់នឹងមជ្ឈត្តវិនិច្ឆ័យរបស់វេទិកាមជ្ឈត្តកម្ម

យោងតាមច្បាប់ស្តីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្ម និងច្បាប់មជ្ឈត្តការអន្តរជាតិភាគច្រើន មជ្ឈត្តវិនិច្ឆ័យមិនអាចប្តឹងជំទាស់បានទេ លើកលែងតែក្នុងកាលៈទេសៈតិចតួចប៉ុណ្ណោះ។ ការអនុញ្ញាតឱ្យភាគីមួយប្តឹងជំទាស់លើ មជ្ឈត្តវិនិច្ឆ័យដោយងាយស្រួល នោះវាអាចនាំឱ្យបាត់បង់អត្ថប្រយោជន៍សំខាន់របស់មជ្ឈត្តកម្ម ពោលគឺលទ្ធភាពនៃការដោះស្រាយវិវាទប្រកបដោយវិជ្ជាជីវៈ រហ័ស សន្សំសំចៃ និងដែលមានប្រសិទ្ធភាព។ ម្យ៉ាងវិញទៀត ភាគីនឹងរកមិនឃើញការលើកទឹកចិត្តពិតប្រាកដក្នុងការចាប់ផ្តើម និងចូលរួមក្នុងមជ្ឈត្តកម្មឡើយ ប្រសិនបើការសម្រេចចិត្តអាចត្រូវបានប្តឹងជំទាស់មិនទទួលស្គាល់យ៉ាងងាយស្រួលទៅកាន់តុលាការ។

ដូច្នេះ ច្បាប់ស្តីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្ម ផ្តល់ហេតុផលតិចតួចបំផុតសម្រាប់ការចាត់ទុកជាមោឃៈនៃ មជ្ឈត្តវិនិច្ឆ័យមជ្ឈត្តកម្មណាមួយ។ គ្មានហេតុផលទាំងនេះពាក់ព័ន្ធនឹងការពិនិត្យឡើងវិញនូវគុណសម្បត្តិនៃភស្តុតាង និងការសម្រេចចិត្តនោះទេ។ ទោះយ៉ាងណាក៏ដោយតុលាការកម្ពុជាអាចដាក់ចេញសាលក្រមមជ្ឈត្តកម្ម ប្រសិនបើ៖

- ✓ ភាគីនៃកិច្ចព្រមព្រៀងមជ្ឈត្តកម្មត្រូវបានអសមត្ថភាពនៅពេលនៃកិច្ចព្រមព្រៀង ឬកិច្ចព្រមព្រៀងមិនមានសុពលភាពក្រោមច្បាប់គ្រប់គ្រង ឬ
- ✓ ភាគីមិនត្រូវបានផ្តល់ការជូនដំណឹងត្រឹមត្រូវអំពីការតែងតាំងមជ្ឈត្តកម្ម ឬដំណើរការមជ្ឈត្តកម្ម ឬមិនអាចបង្ហាញករណីរបស់គាត់ប្រកបដោយប្រសិទ្ធភាព។ ឬ
- ✓ មជ្ឈត្តវិនិច្ឆ័យដោះស្រាយវិវាទដែលមិនធ្លាក់ក្នុងលក្ខខណ្ឌនៃកិច្ចព្រមព្រៀងមជ្ឈត្តកម្ម។ ឬ

[55] មាត្រា ៣៩ នៃច្បាប់ស្តីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្ម ឆ្នាំ២០០៦
[56] មាត្រា ៣៩ នៃច្បាប់ស្តីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្ម ឆ្នាំ២០០៦

- ✓ សមាសភាពនៃវេទិកាមជ្ឈត្តកម្ម ឬនីតិវិធីមិនអនុវត្តតាមកិច្ចព្រមព្រៀងមជ្ឈត្តកម្ម។ ឬ
- ✓ កម្មវត្ថុនៃវិវាទមិនអាចដោះស្រាយដោយមជ្ឈត្តកម្មក្រោមច្បាប់នៃព្រះរាជាណាចក្រកម្ពុជា។ ឬ
- ✓ ការទទួលស្គាល់មជ្ឈត្តវិនិច្ឆ័យនេះនឹងផ្ទុយទៅនឹងគោលនយោបាយសាធារណៈរបស់ព្រះរាជាណាចក្រកម្ពុជា។[57]

ច្បាប់ស្តីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្ម ចែងថា តុលាការកម្ពុជាអាចដាក់ចេញមជ្ឈត្តវិនិច្ឆ័យក្រោមហេតុផលទាំងនេះ ប៉ុន្តែពួកគេមិនតម្រូវឱ្យភាគីត្រូវតែធ្វើដូចនេះទេ។ ភាគីដែលចង់ដាក់ចេញមជ្ឈត្តវិនិច្ឆ័យត្រូវដាក់ពាក្យសុំទៅវេទិកាមជ្ឈត្តកម្មឧទ្ធរណ៍នៃព្រះរាជាណាចក្រកម្ពុជាក្នុងរយៈពេល ៣០ ថ្ងៃបន្ទាប់ពីការជូនដំណឹងអំពីការផ្តល់មជ្ឈត្តវិនិច្ឆ័យ។[58] បណ្តឹងឧទ្ធរណ៍ពីវេទិកាមជ្ឈត្តកម្មឧទ្ធរណ៍ទៅតុលាការកំពូលនៃព្រះរាជាណាចក្រកម្ពុជាត្រូវធ្វើឡើងក្នុងរយៈពេល ១៥ ថ្ងៃបន្ទាប់ពីការសម្រេចរបស់វេទិកាមជ្ឈត្តកម្មឧទ្ធរណ៍។ ក្នុងកាលៈទេសៈសមស្រប តុលាការកម្ពុជាអាចផ្អាកដំណើរការរបស់តុលាការ ដើម្បីអនុញ្ញាតឱ្យវេទិកាមជ្ឈត្តកម្មបន្តដំណើរការនីតិវិធី ឬបើមិនដូច្នេះទេ ចាត់វិធានការនេះដើម្បីលុបបំបាត់ហេតុផលសម្រាប់កំណត់ឡែក ទើបអាចបញ្ចប់ដំណើរការផ្លូវច្បាប់បាន។

## ៣.៦. ការទទួលស្គាល់ និងការអនុវត្តមជ្ឈត្តវិនិច្ឆ័យ

បន្ទាប់ពីមជ្ឈត្តវិនិច្ឆ័យត្រូវបានចេញ ភាគីដែលឈ្នះក្តីនឹងត្រូវអនុវត្តមជ្ឈត្តវិនិច្ឆ័យនមជ្ឈត្តវិនិច្ឆ័យតាមរយៈតុលាការ ប្រសិនបើភាគីចាញ់ក្តីខកខានក្នុងការគោរពតាមមជ្ឈត្តវិនិច្ឆ័យនោះ។ វេទិកាមជ្ឈត្តកម្មមិនមានអំណាចអនុវត្តរបស់ខ្លួនទេ អាស្រ័យហេតុនេះភាគីត្រូវពឹងផ្អែកលើប្រព័ន្ធតុលាការ ដើម្បីទទួលស្គាល់មជ្ឈត្តវិនិច្ឆ័យដែលបានចេញដោយមជ្ឈត្តករ។

ច្បាប់ស្តីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្មបានចែងថា៖ "ការសម្រេចចិត្តរបស់មជ្ឈត្តករទើជាបានធ្វើនៅប្រទេសណាក៏ដោយត្រូវបានគេទទួលស្គាល់ថាជាកាតព្វកិច្ច ហើយបន្ទាប់ពីបានដាក់ពាក្យសុំជាលាយលក្ខណ៍អក្សរទៅសាលាឧទ្ធរណ៍រួចមក ត្រូវបានអនុវត្តដោយយោងតាមបទប្បញ្ញត្តិក្នុងមាត្រានេះ និងមាត្រា៤៥"។[59]

ជាបញ្ហានៃនីតិវិធី ភាគីដែលស្វែងរកការទទួលស្គាល់ និងការអនុវត្តត្រូវតែផ្តល់ឱ្យតុលាការនូវច្បាប់ដើម ឬច្បាប់ចម្លងដែលមានការបញ្ជាក់អំពីការផ្តល់មជ្ឈត្តវិនិច្ឆ័យ និងកិច្ចព្រមព្រៀងមជ្ឈត្តកម្ម និងការបកប្រែភាសាខ្មែរដែលមានការបញ្ជាក់ និងមានការទទួលស្គាល់ត្រឹមត្រូវ ប្រសិនបើកិច្ចព្រមព្រៀងធ្វើឡើងដោយភាសាដែលមិន

---

[57] មាត្រា ៤៤ វាក្យខណ្ឌទី២ នៃច្បាប់ស្តីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្ម ឆ្នាំ២០០៦

[58] ដូចមុនមាត្រា ៤៤(២) (ក-ខ)នៃច្បាប់ស្តីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្ម ឆ្នាំ២០០៦

[59] មាត្រា ៤៥ នៃច្បាប់ស្តីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្ម ឆ្នាំ២០០៦

មែនជាភាសាខ្មែរដើម។ នេះគឺជាបញ្ហាសាមញ្ញ; នៅពេលដាក់ជូនត្រឹមត្រូវ តុលាការត្រូវតែទទួលស្គាល់ និងអនុវត្តការសម្រេចនេះ ដូចជាសាលក្រមចុងក្រោយ និងអាចអនុវត្តបាន ”។[60]

ទោះយ៉ាងណាក៏ដោយ តុលាការអាចបដិសេធមិនអនុវត្តការផ្តល់មជ្ឈត្តវិនិច្ឆ័យក្រោមកាលៈទេសៈមានកំណត់ដូចខាងក្រោម៖

- ✓ ភាគីនៃកិច្ចព្រមព្រៀងមជ្ឈត្តកម្មត្រូវបានអសមត្ថភាពនៅពេលនៃកិច្ចព្រមព្រៀង ឬកិច្ចព្រមព្រៀងមិនមានសុពលភាពក្រោមច្បាប់គ្រប់គ្រង ឬ
- ✓ ភាគីមិនត្រូវបានផ្តល់ការជូនដំណឹងត្រឹមត្រូវអំពីការតែងតាំងមជ្ឈត្តករ ឬដំណើរការមជ្ឈត្តកម្ម ឬមិនអាចបង្ហាញករណីរបស់គាត់ប្រកបដោយប្រសិទ្ធភាព ឬ
- ✓ មជ្ឈត្តវិនិច្ឆ័យដោះស្រាយវិវាទដែលមិនធ្លាក់ក្នុងលក្ខខណ្ឌនៃកិច្ចព្រមព្រៀងមជ្ឈត្តកម្ម ឬ
- ✓ សមាសភាពនៃវេទិកាមជ្ឈត្តកម្ម ឬនីតិវិធីមិនស្របតាមកិច្ចព្រមព្រៀងមជ្ឈត្តកម្ម ឬមជ្ឈត្តវិនិច្ឆ័យមិនទាន់មានកាតព្វកិច្ចលើភាគី ឬ
- ✓ កម្មវត្ថុនៃវិវាទមិនអាចដោះស្រាយដោយមជ្ឈត្តករក្រោមច្បាប់នៃព្រះរាជាណាចក្រកម្ពុជា ឬ
- ✓ ការទទួលស្គាល់ពានមជ្ឈត្តវិនិច្ឆ័យនេះនឹងផ្ទុយទៅនឹងគោលនយោបាយសាធារណៈរបស់ព្រះរាជាណាចក្រកម្ពុជា។[61]

### **៣.៦.១. ការអនុវត្តមជ្ឈត្តវិនិច្ឆ័យនៅក្នុងប្រទេស**

ភាគីនៅក្នុងមជ្ឈត្តកម្មអាចស្ម័គ្រចិត្តអនុវត្តសេចក្តីសម្រេចអាជ្ញាកណ្តាលរវាងខ្លួនគេដោយអនុវត្តតាមសាលក្រមនៃមជ្ឈត្តវិនិច្ឆ័យ។ ប្រសិនបើភាគីម្ខាងមិនគោរពតាមមជ្ឈត្តវិនិច្ឆ័យ ហើយបដិសេធមិនព្រមដោះស្រាយការទាមទារ ភាគីដែលឈ្នះ អាចដាក់ពាក្យសុំទៅតុលាការស្នើសុំឱ្យវាចេញ "ដីកាបង្គាប់ឱ្យអនុវត្តមជ្ឈត្តវិនិច្ឆ័យ”។[62] សម្រាប់មជ្ឈត្តវិនិច្ឆ័យក្នុងស្រុក តុលាការដែលចេញសាលដីកាគឺតុលាការដំបូង ដែលតុលាការនេះមានយុត្តាធិការភូមិសាស្ត្រលើភាគី ឬទ្រព្យសម្បត្តិរបស់ខ្លួន ដែលជាកម្មវត្ថុនៃការអនុវត្តមជ្ឈត្តវិនិច្ឆ័យ ដោយគេហៅថាការអនុវត្តដោយបង្ខំតាមក្រមរដ្ឋប្បវេណីកម្ពុជា។ ភាគីដែលឈ្នះត្រូវអនុវត្តតាមនីតិវិធីជាក់ហិតការអនុវត្តដើម្បីទទួលបានការដោះស្រាយរបស់ខ្លួនការទាមទារ។ ឯកសារដែលគួរអមជាមួយពាក្យសុំរួមមានដើម និងច្បាប់ចម្លងត្រឹមត្រូវនៃមជ្ឈត្តវិនិច្ឆ័យ,ច្បាប់ដើម និងច្បាប់ចម្លងនៃកិច្ចសន្យា។[63]

---

[60] មាត្រា ៤៥(២) នៃច្បាប់ស្តីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្ម ឆ្នាំ២០០៦

[61] មាត្រា ៤៦(១-២) ច្បាប់ស្តីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្ម ឆ្នាំ២០០៦

[62] មាត្រា ៣៥៣ នីតិវិធីក្រមដ្ឋប្បវេណី ២០០៦

[63] BNG Legal, Commercial Arbitration in Cambodia, 2017

សេចក្តីសម្រេចលើការប្តឹងជំទាស់ ការទទួលស្គាល់ និងការអនុវត្តមជ្ឈត្តវិនិច្ឆ័យជាសមត្ថកិច្ចរបស់សាលាឧទ្ធរណ៍នៃព្រះរាជាណាចក្រកម្ពុជា។[64]

ភាគីវិវាទអាចប្តឹងជំទាស់ទៅនឹងមជ្ឈត្តវិនិច្ឆ័យតាមទ្រង់ទ្រាយជាបណ្តឹងបដិសេធ និងតាមបែបបទដូចខាងក្រោម៖

- ✓ បណ្តឹងបដិសេធទៅនឹងមជ្ឈត្តវិនិច្ឆ័យតាមផ្លូវតុលាការតែស្របតាមល័ក្ខខ័ណ្ឌ ដូចមានចែងក្នុងវាក្យខណ្ឌទី ២.និងវាក្យខ័ណ្ឌទី ៣ នៃមាត្រានេះ ។
- ✓ សាលាឧទ្ធរណ៍ និង តុលាការកំពូលអាចបដិសេធមជ្ឈត្តវិនិច្ឆ័យរបស់មជ្ឈត្តករ បានក្នុងករណី :
  - ◦ ភាគីដែលដាក់ពាក្យសុំបដិសេធបានផ្តល់ភស្តុតាងគ្រប់គ្រាន់ថា :
    - ▪ ភាគីមួយនៃកិច្ចព្រមព្រៀងផ្សះផ្សាដូចមានយោងក្នុងមាត្រា ៧ នៃច្បាប់នេះ បានបាត់បង់សិទ្ធិមួយចំនួនខាងផ្លូវច្បាប់ ឬកិច្ចព្រមព្រៀងផ្សះផ្សានោះ ពុំអាចយកជាការបាន បើយោងតាមច្បាប់ដែលភាគីវិវាទបានសំអាង ឬកិច្ចព្រមព្រៀងផ្សះផ្សាពុំបានគោរពតាមប្បញ្ញត្តិណាមួយនៃច្បាប់របស់ព្រះរាជាណាចក្រ កម្ពុជា ។
    - ▪ ភាគីដែលដាក់ពាក្យសុំបដិសេធនោះ មិនបានទទួលដំណឹងត្រឹមត្រូវពីការតែងតាំងមជ្ឈត្តករ ឬ ពីដំណើរការមជ្ឈត្តការ ឬ ភាគីនេះពុំអាចបង្ហាញពីអង្គហេតុរបស់ខ្លួនបានដោយបសិទ្ធភាព ។
    - ▪ មជ្ឈត្តវិនិច្ឆ័យដែលទាក់ទិននឹងវិវាទនោះពុំឆ្លើយតប ឬពុំគោរពល័ក្ខខ័ណ្ឌនៃកិច្ចព្រមព្រៀងផ្សះផ្សា។ ប្រសិនបើបញ្ហាដែលដាក់ឱ្យធ្វើមជ្ឈត្តការនោះ អាចផ្តាច់ចេញពីបញ្ហាដែលមិនបានដាក់ឱ្យធ្វើមជ្ឈត្តការ ការបដិសេធអាចធ្វើទៅបានតែត្រង់ផ្នែកមួយនៃមជ្ឈត្តវិនិច្ឆ័យ លើបញ្ហាដែលបានដាក់ឱ្យធ្វើមជ្ឈត្តការពីមុនប៉ុណ្ណោះ ។
    - ▪ ការបង្កើតវេទិកាមជ្ឈត្តកម្ម ឬ ដំណើរការមជ្ឈត្តការ ពុំសបនឹងកិច្ចព្រមព្រៀងរបស់ភាគីវិវាទ ក្នុងករណីដែលកិច្ចព្រមព្រៀងនោះស្របតាមបទប្បញ្ញត្តិនច្បាប់នេះ ។ ក្នុងករណីដែលគ្មានកិច្ចព្រមព្រៀងផ្សះផ្សាទេ ការបង្កើតវេទិកាមជ្ឈត្តកម្ម ឬដំណើរការមជ្ឈត្តការខាងលើមិនសមស្របតាមច្បាប់នេះ ។
  - ◦ សាលាឧទ្ធរណ៍ និង តុលាការកំពូលរកឃើញថា :

[64] មាត្រា ៤២ ច្បាប់ស្តីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្ម ឆ្នាំ២០០៦

- កម្មវត្ថុនៃវិវាទនោះ ពុំអាចដោះស្រាយបានតាមរយៈការធ្វើមជ្ឈត្តការឡើយ បើយោងទៅតាមច្បាប់នៃព្រះរាជាណាចក្រកម្ពុជា ។
- មជ្ឈត្តវិនិច្ឆ័យនោះផ្ទុយនឹងនយោបាយសាធារណៈនៃព្រះរាជណាចក្រកម្ពុជា ។[65]

### ៣.៦.២. ការអនុវត្តមជ្ឈត្តវិនិច្ឆ័យនៅក្រៅប្រទេស

កម្ពុជាជាភាគីរបស់អង្គការសហប្រជាជាតិអនុសញ្ញានៃការទទួលស្គាល់ និងការអនុវត្តរបស់មជ្ឈត្តវិនិច្ឆ័យបរទេស("អនុសញ្ញាញូវយ៉ក")។ ភាគីទាំងអស់នៃអនុសញ្ញាញូវយ៉ក ដែលមានប្រទេសជាសមាជិកចំនួន ១៤៩ នៅពេលនេះទទួលស្គាល់និងអនុវត្តការសម្រេចចិត្តអាជ្ញាកណ្តាលចេញនៅក្នុងរដ្ឋសមាជិកផ្សេងទៀត ដូច្នេះមជ្ឈត្តវិនិច្ឆ័យអាចត្រូវបានអនុវត្តនៅក្នុងប្រទេសកម្ពុជា។ ថ្មីនេះផងដែរអនុសញ្ញាញូវយ៉ក កំណត់យករដ្ឋដែលចុះហត្ថលេខា បង្កើតយន្តការអនុវត្តច្បាប់របស់មជ្ឈត្តកម្មដោយអនុវត្តមជ្ឈត្តវិនិច្ឆ័យ។ នៅកម្ពុជា ចលនាស្វែងរកការអនុវត្តអាជ្ញាកណ្តាលបរទេសត្រូវមានបញ្ជូនទៅតុលាការឧទ្ធរណ៍។ ភាគីមានពេល ៦០ ថ្ងៃដើម្បីជំទាស់នឹងការទទួលស្គាល់និងការអនុវត្តមជ្ឈត្តវិនិច្ឆ័យដោយការប្តឹងឧទ្ធរណ៍ទៅតុលាការកំពូល។ សេចក្តីសម្រេចរបស់ឧត្តមតុលាការសម្រេចជាស្ថាពរ និងមានកាតព្វកិច្ច។ភាគីឈ្នះអាចស្នើសុំការទទួលស្គាល់ហើយទទឹមនឹងនោះ ការអនុវត្តអនុវត្តមជ្ឈត្តវិនិច្ឆ័យ។[66] ភាគីត្រូវស្នើសុំ "បញ្ជាដើម្បីអនុវត្តសាលក្រមអនុវត្តមជ្ឈត្តវិនិច្ឆ័យ" ពីតុលាការនៃបណ្តឹងឧទ្ធរណ៍ដោយអនុវត្តតាមនីតិវិធីដូចគ្នានឹងការអនុវត្តមជ្ឈត្តវិនិច្ឆ័យក្នុងស្រុក។[67]

## ៣.៧. គុណសម្បត្តិនិងគុណវិបត្តិនៃមជ្ឈត្តការ

### ៣.៧.១. គុណសម្បត្តិនៃមជ្ឈត្តការ

បើប្រៀបធៀបនឹងវិធីសាស្ត្រទូទៅផ្សេងទៀតនៃការដោះស្រាយវិវាទ មជ្ឈត្តការមានគុណសម្បត្តិសំខាន់ៗមួយចំនួន៖

- ✓ **ការរក្សាការសម្ងាត់៖** មជ្ឈត្តការមានតម្លៃថោកជាងបណ្តឹងតុលាការ ពីព្រោះដំណើរការជាធម្មតាត្រូវបានសម្រួលបើប្រៀបធៀបទៅនឹងច្បាប់របស់តុលាការ។ វាក៏ដោយសារតែមជ្ឈត្តកម្មបិទផ្លូវតវ៉ាដែលមិនមានការបណ្តឹងជំទាស់ទៅតុលាការ។

[65] មាត្រា ៤៤ ច្បាប់ស្តីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្ម ឆ្នាំ២០០៦

[66] BNG Legal, Commercial Arbitration in Cambodia, 2017

[67] មាត្រា ៣៥៣(៦) នីតិវិធីក្រមរដ្ឋប្បវេណី ២០០៦

- ✓ **ភាពឆាប់រហ័ស៖** មជ្ឈត្តការមានភាពឆាប់រហ័សជាងបណ្តឹងតុលាការដូចដែលបានរៀបរាប់ មជ្ឈត្តកម្មជាទូទៅមិនអនុញ្ញាតឱ្យមានភាគីដាក់បណ្តឹងឧទ្ធរណ៍ទេ លើសពីនេះប្រព័ន្ធតុលាការជាធម្មតាមានកំណត់ហេតុសំណុំរឿងដ៏ធំ និងច្រើនដែលបង្ខំឱ្យភាគីរង់ចាំរយៈពេលយូរសម្រាប់សវនាការ។
- ✓ **ចងកាតព្វកិច្ច / លក្ខណៈស្ថាពរ៖** ដោយសារមជ្ឈត្តការមិនអនុញ្ញាតឱ្យមានបណ្តឹងឧទ្ធរណ៍ នោះការសម្រេចចិត្តរបស់មជ្ឈត្តករគឺមានលក្ខណៈស្ថាពរ និងចងកាតព្វកិច្ចភាគីទាំងសងខាង។
- ✓ **ការដាក់ឱ្យអនុវត្តថ្នាក់ជាតិ៖** ឥឡូវនេះកម្ពុជាបានអនុម័តច្បាប់ស្តីពីមជ្ឈត្តកម្មពាណិជ្ជកម្មរបស់ខ្លួន តុលាការកម្ពុជាអាចអនុវត្តដោយផ្ទាល់នូវមជ្ឈត្តវិនិច្ឆ័យដែលបានសម្រេចដោយមជ្ឈត្តករ។ ការចរចាឬការដោះស្រាយដោយសម្រុះសម្រួលមិនអាចអនុវត្តបានដោយងាយនោះទេ។[68]
- ✓ **ការដាក់ឱ្យអនុវត្តថ្នាក់អន្តរជាតិ៖** នៅក្រោមអនុសញ្ញាញូវយ៉ក (New York Convention) ស្តីពីការទទួលស្គាល់ និងការអនុវត្តនៃមជ្ឈត្ត វិនិច្ឆ័យបរទេស ("អនុសញ្ញាញូវយ៉ក") ដែលកម្ពុជាបានចុះហត្ថលេខាមជ្ឈត្តវិនិច្ឆ័យណាមួយដែលបានធ្វើឡើងនៅក្នុងប្រទេសហត្ថលេខីគឺអនុវត្តដោយស្វ័យប្រវត្តិនៅក្នុងប្រទេសហត្ថលេខីផ្សេងទៀតទាំងអស់។ នេះគឺជាអត្ថប្រយោជន៍ដ៏សំខាន់សម្រាប់ជម្លោះអន្តរជាតិ ដោយសារមិនមានរបបអនុវត្តអន្តរជាតិស្រដៀងគ្នាសម្រាប់ការសម្រេចចិត្តរបស់តុលាការ។
- ✓ **ការរក្សាទំនាក់ទំនង៖** ខណៈពេលដែលមជ្ឈត្តកម្មមានទិដ្ឋភាពអវិជ្ជមាន ជាទូទៅវាមានលក្ខណៈផ្ទុយគ្នាតិចជាងការកាត់ក្តីរបស់តុលាការការដោះស្រាយវិវាទតាមរយៈមជ្ឈត្តកម្មអាចជួយរក្សាទំនាក់ទំនងរវាងភាគីវិវាទបាន។
- ✓ **ភាពជាឯកជនរបស់ភាគី៖** មិនដូចការជំនុំជម្រះក្តីរបស់តុលាការទេ មជ្ឈត្តកម្មជាធម្មតាជាដំណើរការមានលក្ខណៈឯកជន ដែលអាចជាអត្ថប្រយោជន៍ដ៏សំខាន់សម្រាប់ភាគីទាំងសងខាង ប្រសិនបើពួកគេមិនចង់ឱ្យសាធារណជនសិក្សាលម្អិតអំពីជម្លោះរបស់ពួកគេ។
- ✓ **ដំណោះស្រាយដែលមានភាពបត់បែន៖** មជ្ឈត្តកម្មតែងតែមានភាពបត់បែនក្នុងការផ្តល់សំណងប្រកបដោយភាពច្នៃប្រឌិតដែលតុលាការមិនអាចធ្វើបាន ដូចជាការផ្តល់ថ្លៃសេវាមេធាវីដល់ការទទួលបន្ទុក។
- ✓ **ជំនាញរបស់មជ្ឈត្តករ៖** ភាគីអាចជ្រើសរើសមជ្ឈត្តករដែលមានជំនាញក្នុងផ្នែកអាជីវកម្មរបស់ពួកគេ ម៉្យាងវិញទៀត ប្រព័ន្ធតុលាការភាគច្រើនមិនមានចៅក្រមជំនាញសម្រាប់ផ្នែកជាក់លាក់នៃច្បាប់ ដូច្នេះ

[68] ដំណោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ៖ ប្រទេសកម្ពុជា, សៀវភៅសិក្សាអំពីទស្សនាទានសំខាន់ៗ, ស្ទីវិន អ៊ែម អូស្ទើរមីឡឺរ៍, ឆ្នាំ ២០១០, ទំព័រ១៦១

ភាគីអាចមានចៅក្រមជាប្រធានដែលមិនមានចំណេះដឹងជាក់លាក់អំពីអាជីវកម្មរបស់ពួកគេ។ ដូច្នេះ ក្នុងករណីដែលចំណេះដឹងជាក់លាក់អំពីអាជីវកម្ម ឬច្បាប់មានសារៈសំខាន់ ដំណើរការមជ្ឈត្តកម្មអាចផ្តល់លទ្ធផលត្រឹមត្រូវ និងច្បាស់លាស់សម្រាប់ភាគីវិវាទ។

- ✓ **ភាពអព្យាក្រឹត្យរបស់មជ្ឈត្តករ៖** ភាគីជម្លោះអន្តរជាតិតែងតែបារម្ភថា ចៅក្រមនៅក្នុងប្រទេសកំណើតនៃភាគីណាមួយអាចមានភាពលំអៀង និងអនុគ្រោះដល់ភាគីនោះ ដែលជួនកាលគេហៅថា "អត្ថប្រយោជន៍តុលាការនៅផ្ទះ"។ ទោះជាយ៉ាងណាក៏ដោយ ជាមួយនឹងមជ្ឈត្តកម្ម ភាគីអាចជ្រើសរើសមជ្ឈត្តករ ហើយអាចលុបបំបាត់ភាពលំអៀងជាតិដែលមានសក្តានុពល។[69]
- ✓ **នីតិវិធីដែលអាចបត់បែនបាន៖** ជារឿយៗភាគីនអាចជ្រើសរើសថាតើពួកគេចង់បាននីតិវិធីដោយខ្លួនឯងសម្រាប់ការដោះស្រាយវិវាទរបស់ពួកគេ។ ចំណែកឯការដោះស្រាយតាមប្រព័ន្ធតុលាការ វិវាទភាគីត្រូវអនុវត្តតាមនីតិវិធីច្បាប់ និងស្របទៅតាមប្រធានចៅក្រមដែលទទួលបន្ទុកសំណុំរឿងនោះ ទោះបីមិនពេញចិត្តក៏ដោយ។ នៅក្នុងការស្ទង់មតិឆ្នាំ ២០០៤ អត្ថប្រយោជន៍នេះត្រូវបានលើកឡើងថាជាហេតុផលកំពូលដែលភាគីនៃជម្លោះផ្នែកពាណិជ្ជកម្មអន្តរជាតិជ្រើសរើសមជ្ឈត្តកម្ម។[70]

### ៣.៧.២. គុណវិបត្តិនៃមជ្ឈត្តការ

បើប្រៀបធៀបនឹងវិធីសាស្ត្រទូទៅផ្សេងទៀតនៃការដោះស្រាយវិវាទ មជ្ឈត្តការមានគុណវិបត្តិមួយចំនួនដូចជា៖

- ✓ **ការចំណាយ / តម្លៃសេវា៖** ទោះបីជាមជ្ឈត្តកម្មជាទូទៅមានតម្លៃទាបជាងវិវាទក៏ដោយ ក៏វានៅតែមានចំណាយទៅលើមជ្ឈត្តករ និងសេវាផ្សេងៗផងដែរ។ ភាគីត្រូវបង់ថ្លៃពេលវេលារបស់មជ្ឈត្តករ ថ្លៃវេទិកាមជ្ឈត្តកម្ម ក៏ដូចជាថ្លៃវិវាទធម្មតាទាំងអស់ ក៏ដូចជាថ្លៃមេធាវី ។ មជ្ឈត្តកម្មជាធម្មតាមានតម្លៃថ្លៃជាងការចរចា និងការសម្រុះសម្រួល។
- ✓ **ភាពរហ័ស / រយៈពេលនៃនីតិវិធី៖** ទោះបីជាមជ្ឈត្តកម្មជាទូទៅលឿនជាងបណ្ដឹងតុលាការក៏ដោយ វាអាចយឺតជាងការដោះស្រាយតាមរយៈការចរចា និងការសម្របសម្រួល។ ភាគីទាំងសងខាងត្រូវការពេលវេលាបន្ថែមទៀតដើម្បីរៀបចំសំណុំរឿងរបស់ពួកគេសម្រាប់មជ្ឈត្តកម្មជាជាងប្រសិនបើពួកគេកំពុងបន្តការសម្របសម្រួលឬការចរចា។

[69] ដំណោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ៖ ប្រទេសកម្ពុជា, សៀវភៅសិក្សាអំពីទស្សនាទានសំខាន់ៗ, ស្ទីវិន អ៊ែម អូស្ទើរមីឡឺរ៍, ឆ្នាំ ២០១០, ទំព័រ១៦១

[70] មាត្រា ១០៦៨ ក្រមរដ្ឋប្បវេណី ២០០៦

- ✓ **អនុលោមភាពមានកម្រិតទាប៖** ដោយសារមជ្ឈត្តវិនិច្ឆ័យដែលសម្រេចដោយមជ្ឈត្តករមិនមែនមកពីការការចរចា និងការសម្រុះសម្រួលគ្នា មានលទ្ធភាពកាន់តែច្រើននៃការមិនអនុលោមតាមមជ្ឈត្តវិនិច្ឆ័យ។ ដូច្នេះ ភាគីអាចត្រូវចំណាយបន្ថែមលើថ្លៃមេធាវីបន្ថែម ដើម្បីបន្តការអនុវត្តន៍មជ្ឈត្តវិនិច្ឆ័យនោះតាមនីតិវិធីតុលាការ។
- ✓ **សវនាការជាអសាធារណៈ៖** ក្នុងស្ថានភាពខ្លះ ភាគីមួយអាចចូលចិត្តសវនាការជាសាធារណៈ ឧទាហរណ៍ ដើម្បីការពារខ្លួនជាសាធារណៈប្រឆាំងនឹងការទាមទារ ឬដាក់ទណ្ឌកម្មភាគីម្ខាងទៀតដោយការអាម៉ាស់ជាសាធារណៈ ដោយសារមជ្ឈត្តកម្មមិនអនុញ្ញាត វាជាគុណវិបត្តិដែលអាចកើតមានចំពោះភាគីក្នុងស្ថានភាពជាក់លាក់។
- ✓ **ការរក្សាទំនាក់ទំនង៖** ខណៈពេលដែលមជ្ឈត្តកម្មអាចរក្សាទំនាក់ទំនងរបស់ភាគីបានល្អប្រសើរជាងវិវាទ ទម្រង់ពីរផ្សេងទៀតនៃការដោះស្រាយវិវាទ ការចរចា និងការសម្រុះសម្រួលគឺមានប្រសិទ្ធភាពជាងក្នុងបញ្ហានេះ។[71]

## ៣.៨ .បញ្ហាប្រឈម

បន្ទាប់ពីបានសិក្សាស្រាវជ្រាវពីការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការនិងស្ថាប័ន ម.ជ.ម. រួចមក យើងបានសង្កេតឃើញថា ទោះបីជា វិធីសាស្ត្រនៃការដោះស្រាយបញ្ហាពាណិជ្ជកម្មតាមរយៈមជ្ឈត្តកម្មមានប្រសិទ្ធភាព ប៉ុន្តែក៏មានបញ្ហាមួយចំនួនដែលយើងគួរយកមកពិចារណាផងដែរ។

ទោះបីជាវាអាចត្រូវបានគេមើលឃើញថា ការដោះស្រាយវិវាទតាមប្រព័ន្ធមជ្ឈត្តកម្ម អាចដោះស្រាយវិវាទពាណិជ្ជកម្មបានប្រសើរជាងប្រព័ន្ធតុលាការ ប៉ុន្តែស្ថាប័នដោះស្រាយវិវាទពាណិជ្ជកម្មនៅប្រទេសកម្ពុជាគឺនៅមានលក្ខណៈថ្មីនៅឡើយ ដែលពាណិជ្ជករនៅមានការខ្វះទំនុកចិត្តនិងតាមដានបន្ថែមពីស្ថាប័ននេះ។[72] ការដោះស្រាយវិវាទតាមរយៈម.ជ.ម. ពិតជាមានភាពឆាប់រហ័សនិងរក្សាទុកភាពសម្ងាត់ដល់ភាគីវិវាទ តែដោយសារតែការរីកលូតលាស់និងរយៈពេលនៃការបង្កើតឡើងនូវមានកម្រិត ទើបធ្វើឲ្យអាជីវករឬពាណិជ្ជករនៅតែមានភាពមិនទាន់ទុកចិត្តនៅឡើយទៅលើស្ថាប័នដោះស្រាយវិវាទមួយនេះ។

[71] ដំណោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ៖ ប្រទេសកម្ពុជា, សៀវភៅសិក្សាអំពីទស្សនាទានសំខាន់ៗ, ស៊ីវិន អ៊ែម អូស្ទើរមីឡឺរ៍, ឆ្នាំ ២០១០, ទំព័រ១៦១

[72] Rajh & Tann Asia, National Commercial Arbitration Center: Development and Challenges, ២០២១

ហើយមួយទៀតវិញ នៅប្រទេសកម្ពុជាមិនទាន់មាន តុលាការពាណិជ្ជកម្មនៅឡើយទេ ដែលធ្វើឲ្យការអនុវត្តមជ្ឈត្តវិនិច្ឆ័យមានភាពពិបាកបើសិនជាភាគីដែលចាញ់មិនព្រមអនុវត្ត ដែលនាំឲ្យភាគីដែលឈ្នះត្រូវចំណាយពេលនិង ថវិការទៅតុលាការដើម្បីទាមទារការអនុវត្តដោយចាប់បង្ខំទៅភាគីដែលចាញ់។

# សេចក្តីសន្និដ្ឋាន

# សេចក្តីសន្និដ្ឋាន

ក្រោយពីបានបញ្ចប់ការសិក្សាស្រាវជ្រាវលើប្រធានបទស្តីពី ស្ថាប័នដោះស្រាយវិវាទពាណិជ្ជកម្មក្រៅប្រពន្ធ័តុលាការរួចហើយ យើងខ្ញុំយល់ឃើញថាមជ្ឈត្តកម្ម គឺជាវិធីដោះស្រាយជម្លោះមួយយ៉ាងសំខាន់ ដោយផ្តល់ជម្រើសទៅដល់ពាណិជ្ជករទាំងក្នុងនិងក្រៅប្រទេស នូវវិធីនៃការដោះស្រាយវិវាទពាណិជ្ជកម្មដែលមានភាពងាយស្រួលនិងឆាប់រហ័ស។ ហើយយើងក៏គួរកត់សម្គាល់ដែរថា របបមជ្ឈត្តកម្មពាណិជ្ជកម្មនៅប្រទេសកម្ពុជា ពិតជាមានសារៈសំខាន់ណាស់ ក្នុងការពង្រឹងទំនាក់ទំនងពាណិជ្ជកម្ម និងបង្កើនការវិនិយោគនៅក្នុងប្រទេសកម្ពុជា ដោយសារតែនីតិវិធីក្នុងការដោះស្រាយជម្លោះនេះផងដែរ ត្រូវបានអនុវត្តជាច្រើនទៅហើយនៅប្រទេសផ្សេងៗ ហើយនៅពេលដែលប្រទេសកម្ពុជាអនុវត្តវាផងដែរនោះ វាក៏បានទាញយកទំនុកចិត្តអ្នកវិនិយោគដើម្បីចូលមកធ្វើការរកស៊ីនៅក្នុងប្រទេសកម្ពុជានិងជួយលើកតំកើនសេដ្ឋកិច្ចជាតិផងដែរ។ ដូច្នេះបើសិនគ្មាននីតិវិធីក្នុងការដោះស្រាយជម្លោះបែបនេះទេ វានឹងបង្កឱ្យមានអស្ថេរភាពគតិយុត្ត ទៅលើការដោះស្រាយវិវាទពាណិជ្ជកម្ម ដោយសារតែវាអាចធ្វើឲ្យអ្នកវិនិយោគបរទេសគ្មានទំនុកចិត្ត និងមិនហ៊ានចូលមកវិនិយោគនៅក្នុងប្រទេសកម្ពុជា។

តាមរយៈលទ្ធផលនៃការស្រាវជ្រាវប្រធានបទនេះ រួចមកបានបង្ហាញឱ្យឃើញថា ការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការជាយន្តការមួយដ៏ល្អសម្រាប់ពាណិជ្ជករ។ ការដោះស្រាយវិវាទតាមរយៈមជ្ឈត្តការ មានរយៈពេលខ្លី ឆាប់រហ័ស មានការចំណាយតិច មានការរក្សាការសម្ងាត់ នីតិវិធីមានលក្ខណៈបត់បែន ជាងនីតិវិធីតាមប្រព័ន្ធតុលាការ ដូច្នេះក្នុងការដោះស្រាយវិវាទពាណិជ្ជកម្ម ភាគីវិវាទគួរតែធ្វើការជ្រើសរើសមជ្ឈត្តការមកធ្វើការដោះស្រាយវិវាទរបស់ខ្លួន ហើយទោះបីជានៅក្រោយពេលដែលចេញសេចក្តីសម្រេចមជ្ឈត្តវិនិច្ឆ័យ ភាគីវិវាទចង់យកសេចក្តីសម្រេចនេះទៅអនុវត្តជាអន្តរជាតិ ក៏មជ្ឈត្តវិនិច្ឆ័យនៅតែអាចអនុវត្តបានទាំងក្នុងនិងក្រៅប្រទេសផងដែរ។ ការដោះស្រាយវិវាទតាមរយៈមជ្ឈត្តការនឹងផ្តល់ទំនុកចិត្តដល់ពាណិជ្ជករ និងវិនិយោគិនក្នុងការទទួលបានសេចក្តីសម្រេចដែលមានអនុភាពអនុវត្តជាអន្តរជាតិ ជាពិសេសការគោរពគោលការណ៍សេរីភាពឆ្លុះបញ្ចាំងពីសុចរិតភាព និងតម្លាភាពនៃនីតិវិធីតាំងពីពេលចាប់ផ្តើមដំណាក់កាលដំបូង ដោយផ្សារភ្ជាប់នឹងគុណភាព និងប្រសិទ្ធភាពនៃការដោះស្រាយទំនាស់។

អ្វីដែលគួរឲ្យកត់សម្គាល់នៅពេលដែលសិក្សាស្រាវជ្រាវពីប្រធានបទមួយនេះ យើងអាចសង្កេតឃើញថាស្ថាប័នម.ជ.ម. ពិតជាបានរួមចំណែកយ៉ាងខ្លាំងក្នុងការជួយលើកតំកើងវិស័យមជ្ឈត្តកម្មនៅប្រទេសកម្ពុជា ហើយជាពិសេសនោះ ស្ថាប័នមួយនេះផងដែរបានផ្តល់ឧកាសឲ្យពាណិជ្ជករក្នុងការជ្រើសរើសការដោះស្រាយវិវាទតាមរយៈប្រព័ន្ធក្រៅតុលាការ ដែលមានលក្ខណៈជាអន្តរជាតិនិងជាតិដែលជួយសម្រួលដល់ភាគីវិវាទ និងផ្តល់ជាមូលដ្ឋានដល់ពាណិជ្ជករនៅប្រទេសកម្ពុជាឲ្យកាន់តែមានភាពទុកចិត្តមួយកម្រិតទៀតនៅពេលដែលពាណិជ្ជករទាំងអស់នោះធ្វើការសហការជាមួយនិងពាណិជ្ជករក្រៅស្រុក។

ការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការពិតជាផ្តល់នូវភាព ឆាប់រហ័ស រក្សាការសម្ងាត់និងការចំណាយតិចជាងនីតិវិធីតាមប្រព័ន្ធតុលាការ ហើយនៅក្រោយពេលដែលចេញនូវសេចក្តីសម្រេចមជ្ឈត្តវិនិច្ឆ័យ ភាគីវិវាទអាចយកសេចក្តីសម្រេចនេះទៅអនុវត្តជាអន្តរជាតិនៅប្រទេសជាច្រើនដែលធ្វើឲ្យការដោះស្រាយវិវាទតាមរបៀបនេះមានភាពរីកចម្រើននិងលូតលាស់កាន់តែខ្លាំងឡើង។ ដូច្នេះក្នុងការដោះស្រាយវិវាទពាណិជ្ជកម្មភាគីវិវាទគួរតែជ្រើសយកមជ្ឈត្តការមកដោះស្រាយវិវាទរបស់ខ្លួន។

ជារួមមក ស្ថាប័នម.ជ.ម. ពិតជាមានសារសំខាន់និងជាជំនួយក្នុងការដោះស្រាយវិវាទពាណិជ្ជកម្មនៅប្រទេសកម្ពុជា ដោយការដោះស្រាយវិវាទតាមរយៈមជ្ឈត្តកម្មមានគុណសម្បត្តិយ៉ាងច្រើនដែលសម្រួលដល់ពាណិជ្ជករ និងវិស័យពាណិជ្ជកម្មនៅប្រទេសកម្ពុជាផងដែរ។

# អនុសាសន៍

# អនុសាសន៍

តាមរយៈការសិក្សាស្រាវជ្រាវលម្អិតស្តីពីប្រធានបទ រួចមកយើងខ្ញុំយល់ឃើញថាក៏មានចំណុចគួរឲ្យកត់សម្គាល់មួយចំនួនដែរ។ ទោះបីជាប្រទេសកម្ពុជា កំពុងតែមានសន្ទុះក្នុងវិស័យពាណិជ្ជកម្មនិងការរីកដុះដាលនៃវិស័យមជ្ឈត្តកម្ម ប៉ុន្តែបើសិនជាមានការរៀបចំឲ្យប្រព័ន្ធច្បាប់កាន់តែល្អប្រសើរជាងនេះ នោះនឹងធ្វើឱ្យប្រទេសកម្ពុជាមានកំណើនវិនិយោគពីបរទេសច្រើនជាងនេះផងដែរ ហើយវាកាន់តែជួយឲ្យសេដ្ឋកិច្ចប្រទេសកម្ពុជាមានសន្ទុះនិងរីកចម្រើនកាន់តែខ្លាំងឡើងផងដែរ។

ការសិក្សានិងស្វែងយល់ពីប្រព័ន្ធដោះស្រាយវិវាទពាណិជ្ជកម្មនៅកម្ពុជាពិតជាមានសារៈសំខាន់ណាស់សម្រាប់អនាគតវិស័យមជ្ឈត្តការពាណិជ្ជកម្មប្រទេសកម្ពុជា ក៏ដូចជាការរួមចំណែកមួយក្នុងការថែរក្សាកំណើននៃការវិនិយោគឲ្យកាន់តែមានសន្ទុះយូរអង្វែងដូចគ្នាដែរ។ ក្រោយពេលដែលបានធ្វើការសិក្សាពីស្ថាប័ននេះរួចហើយ យើងខ្ញុំសង្កេតឃើញថាស្ថាប័ននេះមានសន្ទុះនិងការវិវត្តយ៉ាងលឿន គួរឲ្យកត់សម្គាល់ ហើយសង្ឃឹមថាស្ថាប័ននេះនឹងអាចនៅតែបន្តសកម្មភាពនិងការរីកចម្រើនល្អបែបនេះទៅពេលអនាគត។

ដើម្បីចូលរួមចំណែកក្នុងការជួយវិស័យមជ្ឈត្តកម្មនៅប្រទេសកម្ពុជានិងស្ថាប័នម.ជ.ម. យើងខ្ញុំសូមជូនជាមតិយោបល់ខ្លះៗ ទៅដល់ស្ថាប័នម.ជ.ម. ដោយសំណូមពរស្ថាប័នម.ជ.ម. ឲ្យ៖

- ✓ ជម្រុញឲ្យមានការបង្កើនវគ្គបណ្តុះបណ្តាលបន្ថែមពាណិជ្ជកម្ម ទៅដល់សិស្សនិស្សិតដែលកំពុងសិក្សាផ្នែកច្បាប់ឬមជ្ឈត្តករឲ្យកាន់តែច្រើនមួយកម្រិតទៀតដោយសារតែជំនាញនេះអាចនិយាយបានថា ពត៌មាននិងឯកសាររបស់វានៅមានកម្រិត ដូច្នេះហើយធ្វើឲ្យការយល់ដឹងពីនីតិវិធីនិងប្រព័ន្ធនេះមានការលំបាក
- ✓ សិក្សាបទពិសោធន៍ និងគំរូរបស់បណ្តាប្រទេសដើម្បីឲ្យមានភាពអភិវឌ្ឍន៍ និងជឿនលឿនលើវិស័យមជ្ឈត្តកម្មពាណិជ្ជកម្មមួយកម្រិតទៀត ដោយសារតែនៅប្រទេសកម្ពុជាមានតែស្ថាប័ននេះមួយប៉ុណ្ណោះដែលផ្តល់ការដោះស្រាយវិវាទតាមមជ្ឈត្តកម្ម ដូច្នេះការសង្កេតទៅលើប្រទេសដ៏ទៃនឹងផ្តល់ជាគំនិតយ៉ាងច្រើនដល់ស្ថាប័នម.ជ.ម.
- ✓ រក្សារឬគ្រប់គ្រងសេវានៃដំណើរការមជ្ឈត្តកម្មឲ្យមានតម្លៃសមរម្យ ដើម្បីឱ្យពាណិជ្ជករមានលទ្ធភាពទទួលបានការដោះស្រាយវិវាទតាមរយៈមជ្ឈត្តកម្ម
- ✓ បន្តរក្សានូវភាពនូវយុត្តិធម៌ ឯករាជ្យ និងរក្សាការសម្ងាត់ទៅដល់ភាគីដែលមានវិវាទ
- ✓ បង្កើតឲ្យមានទស្សនកិច្ចនៅស្ថាប័នម.ជ.ម. ដើម្បីឲ្យសិស្សឬនិស្សិតច្បាប់អាចយល់ដឹងនឹងស្គាល់ពីប្រវត្តនិងការអនុវត្តរបស់ស្ថាប័ននេះ

- ✓ បន្ថែមឲ្យមានការបោះពុម្ពទូលំទូលាយទៅលើស្នាដៃនិងឯកសារពីមជ្ឈត្តកម្មពាណិជ្ជកម្ម ដែលពត៌មានទាំងនោះ អាចបន្ថែមនូវទំនុកចិត្តរបស់ពាណិជ្ជករទៅលើស្ថាប័នម.ជ.ម.
- ✓ ចូលរួមសហការជាមួយសាលាច្បាប់នូវប្រទេសកម្ពុជា ដើម្បីបង្កើតនូវការសិក្សាអំពីមជ្ឈត្តកម្មពាណិជ្ជកម្មឲ្យកាន់តែច្បាស់ថែមមួយកម្រិតទៀតនិងជួយឲ្យនិស្សិតច្បាប់យល់ដឹងពីស្ថាប័នម.ជ.ម.និងមជ្ឈត្តកម្មពាណិជ្ជកម្មផងដែរ

# ឯកសារយោង

# ឯកសារយោង

## លិខិតបទដ្ឋានគតិយុត្ត


- ✓ ក្រមរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ១៩៩៣
- ✓ សន្ធិសញ្ញាទីក្រុងញូវយកស្ដីពី ការទទួលស្គាល់ និងការអនុវត្តសេចក្ដីសម្រេចមជ្ឈត្តការបរទេស ឆ្នាំ១៩៥៨
- ✓ ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦
- ✓ ក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧
- ✓ ច្បាប់ស្ដីពី មជ្ឈត្តការផ្នែកពាណិជ្ជកម្ម ចុះថ្ងៃទី០៦ ខែមីនា ឆ្នាំ២០០៩
- ✓ ច្បាប់ស្ដី ពីវិធានពាណិជ្ជកម្ម និងបញ្ជីពាណិជ្ជកម្ម ចុះថ្ងៃទី២៤ ខែមីនា ឆ្នាំ២០០៣
- ✓ គណៈកម្មការអង្គការសហប្រជាជាតិស្ដីពីច្បាប់ពាណិជ្ជកម្មអន្តរជាតិ ច្បាប់គំរូស្ដីពីមជ្ឈត្តកម្មពាណិជ្ជកម្មអន្តរជាតិ ១៩៨៥ (UNCITRAL Model Law on International Commercial Arbitration)
- ✓ អនុក្រឹត្យស្ដី ពីការរៀបចំនិងការប្រព្រឹត្តទៅរបស់មជ្ឈមណ្ឌលមជ្ឈត្តការពាណិជ្ជកម្មកម្ពុជា ឆ្នាំ២០០៩
- ✓ វិធានមជ្ឈត្តការពាណិជ្ជកម្មរបស់មជ្ឈមណ្ឌលមជ្ឈត្តការពាណិជ្ជកម្មកម្ពុជា ចុះថ្ងៃទី១១ ខែកក្កដា ឆ្នាំ២០១៤
- ✓ វិធានស្ដីពីមជ្ឈត្តការរបស់មជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការផ្នែកពាណិជ្ជកម្ម ឆ្នាំ២០២១
- ✓ វិធានស្ដីពីមជ្ឈត្តការរបស់ ICC
- ✓ វិធានស្ដីពីមជ្ឈត្តការរបស់ AAA


## សៀវភៅនិងអត្ថបទពាក់ព័ន្ធ


- ✓ លោក ម៉ាស្កាវ៉េត ម៉ូសេស សៀវភៅស្ដីពី មជ្ឈត្តការពាណិជ្ជកម្មអន្តរជាតិ ២០០៨។
- ✓ លោក ស៊្វីន អ៊ែម អូរស្ទើរមីឡឺរ៍ សៀវភៅស្ដីពី ដំណោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ ប្រទេសកម្ពុជា រៀបរៀងដោយ ឆ្នាំ២០១៩
- ✓ Hor Peng, *Introduction to Cambodian Law*, Konrad-Adenauer-Stiftung, ឆ្នាំ ២០១២
- ✓ Rajh & Tann Asia, National Commercial Arbitration Center: Development and Challenges, ២០២១


## ឯកសារនិងគេហទំព័រផ្សេងៗ


- ✓ https://ovtlaw.com/, អ្វីជាវិវាទពាណិជ្ជកម្ម WHAT IS THE COMMERCIAL DISPUTE២០១៨
- ✓ https://bnglegal.com/cn/wp-content/uploads/2017/02/170206-Commercial-arbitration-in-Cambodia.pdf-February.pdf, BNGLegalNewsPaper2017
- ✓ https://uk.practicallaw.thomsonreuters.com/6-602-0046?transitionType=Default&contextData=(sc.Default)&firstPage=true, Arbitration Procedures and Practice in Japan: Overview

# ឧបសម្ព័ន្ធ

# បញ្ជីនៃឧបសម្ព័ន្ធ

- ឧបសម្ព័ន្ធទី១ ៖ រចនាសម្ព័ន្ធ ម.ជ.ម
- ឧបសម្ព័ន្ធទី២ ៖ អនុក្រឹត្យស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់មជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការផ្នែកពាណិជ្ជកម្ម
- ឧបសម្ព័ន្ធទី៣ ៖ វិធានស្តីពីមជ្ឈត្តការរបស់មជ្ឈត្តការផ្នែកពាណិជ្ជកម្ម
- ឧបសម្ព័ន្ធទី៤ ៖ ដំណោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ ប្រទេសកម្ពុជា ដោយលោក ស្ទីវិន អ៊ែម អូរស្តើរមីឡឺរ៍ ឆ្នាំ២០១៩

# ឧបសម្ព័ន្ធទី១

# រចនាសម្ព័ន្ធម.ជ.ម

# រចនាសម្ព័ន្ធម.ជ.ម



# ឧបសម្ព័ន្ធទី២
# អនុក្រឹត្យស្តីពីការរៀបចំនិងការប្រព្រឹត្ត
# ទៅរបស់ម.ជ.ម

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ១២៤ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការរៀបចំនិងការប្រព្រឹត្តទៅរបស់មជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការផ្ដែកពាណិជ្ជកម្ម

ថតចម្លង

នាយកដ្ឋាន.រដ្ឋបាល.

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៦ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងពាណិជ្ជកម្ម
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៦/០១០ ចុះថ្ងៃទី០៥ ខែឧសភា ឆ្នាំ២០០៦ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីមជ្ឈត្តការផ្ទៃកពាណិជ្ជកម្ម
- បានឃើញអនុក្រឹត្យលេខ ៩១ អនក្រ.បក ចុះថ្ងៃទី ០១ ខែសីហា ឆ្នាំ២០០៧ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងពាណិជ្ជកម្ម
- បានទទួលការឯកភាពពីគណៈរដ្ឋមន្ត្រីក្នុងសម័យប្រជុំពេញអង្គ នាថ្ងៃទី២៤ ខែកក្កដា ឆ្នាំ២០០៩

## សម្រេច

### ជំពូកទី១

### បទប្បញ្ញត្តិទូទៅ

**មាត្រា១.-**

អនុក្រឹត្យនេះកំណត់ពីការរៀបចំ និងការប្រព្រឹត្តទៅរបស់មជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការផ្នែកពាណិជ្ជកម្ម ។

មជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការផ្នែកពាណិជ្ជកម្ម ដែលសរសេរកាត់ថា **ម.ជ.ម.** ជាអង្គភាពមិនស្វែងរកប្រាក់ចំណេញ និងមានទីស្នាក់ការនៅរាជធានីភ្នំពេញ ។

### ជំពូកទី២

### តួនាទីនិងភារកិច្ច

**មាត្រា២.-**

**ម.ជ.ម.** មានតួនាទីនិងភារកិច្ចដូចខាងក្រោម ÷

- ជំរុញវិស័យមជ្ឈត្តការផ្នែកពាណិជ្ជកម្មនៅក្នុងព្រះរាជាណាចក្រកម្ពុជា
- ផ្តល់ការបណ្តុះបណ្តាលនិងហ្វឹកហ្វឺនបុគ្គលដែលកំពុងអនុវត្តនិងបុគ្គលដែលមានបំណងអនុវត្តវិជ្ជាជីវៈ ជាមជ្ឈត្តករ ដើម្បីធានាឱ្យមជ្ឈត្តការផ្នែកពាណិជ្ជកម្មនៅក្នុងព្រះរាជាណាចក្រកម្ពុជាមានគុណភាពខ្ពស់
- កំណត់ពីលក្ខណសម្បត្តិនៃបុគ្គល ដែលមានបំណងចូលជាសមាជិក **ម.ជ.ម.**
- ផ្តល់សេវាដោះស្រាយវិវាទផ្នែកពាណិជ្ជកម្មក្រៅប្រព័ន្ធតុលាការ
- រៀបចំសន្និសីទថ្នាក់ជាតិនិងអន្តរជាតិ ក្នុងគោលដៅជំរុញវិស័យមជ្ឈត្តការផ្នែកពាណិជ្ជកម្ម
- រៀបចំ ចូលរួមសិក្ខាសាលានិងវគ្គសិក្សា លើប្រធានបទទាក់ទងនឹងមជ្ឈត្តការផ្នែកពាណិជ្ជកម្ម
- ប្រមូល បោះពុម្ព និងផ្សព្វផ្សាយព័ត៌មាន អត្ថបទនិពន្ធ សៀវភៅនិងឯកសារ សោតទស្សន៍ឬហ្វូណូក្រាម ដែលទាក់ទងនឹងមជ្ឈត្តការផ្នែកពាណិជ្ជកម្ម
- គ្រប់គ្រងនិងចាត់ចែងទ្រព្យសម្បត្តិ **ម.ជ.ម.**
- រៀបចំបណ្ណាល័យនិងបន្ទប់ផ្សេងៗ សម្រាប់បម្រើសេវាទាក់ទងនឹងមជ្ឈត្តការផ្នែកពាណិជ្ជកម្ម
- ចុះកិច្ចព្រមព្រៀងនានាដែលចាំបាច់ក្នុងការបំពេញមុខងាររបស់ខ្លួន
- បំពេញភារកិច្ចផ្សេងៗទៀតតាមការកំណត់របស់មហាសន្និបាត **ម.ជ.ម.** ។



## ជំពូកទី៣

## រចនាសម្ព័ន្ធ

## ផ្នែកទី១

## មហាសន្និបាត

**មាត្រា៣.–**

សិទ្ធិអំណាចកំពូលរបស់ **ម.ជ.ម.** គឺមហាសន្និបាត។

មហាសន្និបាតប្រចាំឆ្នាំត្រូវធ្វើឡើងតាមកាលបរិច្ឆេទ ដែលកំណត់ដោយក្រុមប្រឹក្សាប្រតិបត្តិ។ ក្នុងករណីចាំបាច់ ប្រធានក្រុមប្រឹក្សាប្រតិបត្តិ ឬសមាជិកភាគច្រើននៃក្រុមប្រឹក្សាប្រតិបត្តិ អាចស្នើសុំបើកមហាសន្និបាតវិសាមញ្ញបានដោយមានភ្ជាប់មកជាមួយ នូវរបៀបវារៈក្នុងរយៈពេលយ៉ាងតិច១៥ (ដប់ប្រាំ)ថ្ងៃ មុនថ្ងៃប្រជុំ។ មហាសន្និបាតវិសាមញ្ញនេះត្រូវពិចារណាតែបញ្ហាណាដែលមិនបានលើកឡើង ឬដោះស្រាយនៅក្នុងមហាសន្និបាតប្រចាំឆ្នាំ ដែលបានធ្វើឡើងរួចហើយតែប៉ុណ្ណោះ។

**មាត្រា៤.–**

មហាសន្និបាតប្រចាំឆ្នាំពិនិត្យនិងអនុម័តលើបញ្ហាជាអាទិ៍ ÷

- របាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំនិងរបាយការណ៍ប្រចាំឆ្នាំរបស់ក្រុមប្រឹក្សាប្រតិបត្តិ
- គម្រោងថវិកាប្រចាំឆ្នាំរបស់ **ម.ជ.ម.**
- ការបោះឆ្នោតជ្រើសតាំងនិងដកហូតសមាជិកក្រុមប្រឹក្សាប្រតិបត្តិ
- បទបញ្ជាផ្ទៃក្នុងនិងវិធាន ដែលទាក់ទងនឹងការដោះស្រាយវិវាទផ្នែកពាណិជ្ជកម្ម
- ការកែប្រែនូវបទប្បញ្ញត្តិនានា ដែលទាក់ទងដល់ដំណើរការរបស់ **ម.ជ.ម.**
- បែបបទហិរញ្ញវត្ថុនិងរដ្ឋបាល សម្រាប់ការគ្រប់គ្រងដំណើរការរបស់ **ម.ជ.ម.**
- នីតិវិធីសម្រាប់ការចុះបញ្ជីមជ្ឈត្តករ
- លក្ខណសម្បត្តិបន្ថែមសម្រាប់ឱ្យធ្វើជាមជ្ឈត្តករនៅ **ម.ជ.ម.**
- ក្រមសីលធម៌សម្រាប់មជ្ឈត្តករ។

**មាត្រា៥.–**

ការជូនដំណឹងពីមហាសន្និបាតប្រចាំឆ្នាំ ត្រូវធ្វើឡើងយ៉ាងតិច ៣០ (សាមសិប)ថ្ងៃ មុនថ្ងៃប្រជុំ។ លិខិតជូនដំណឹងនេះត្រូវបញ្ជាក់ពីកាលបរិច្ឆេទ ទីកន្លែងប្រជុំ និងរបៀបវារៈ។



**មាត្រា៦.–**

មហាសន្និបាតអាចប្រព្រឹត្តទៅបានលុះត្រាតែមានវត្តមាន២/៣ (ពីរភាគបី) នៃសមាជិកទាំងអស់គិតទាំងសមាជិកផ្ទេរសិទ្ធិ ហើយបញ្ហានានាដែលលើកមកពិភាក្សា ត្រូវសម្រេចដោយសំឡេងភាគច្រើនដាច់ខាត ។

ក្នុងករណីមិនមានកូរ៉ុមដើម្បីដំណើរការមហាសន្និបាត កិច្ចប្រជុំនេះត្រូវពន្យាររយៈពេលចំនួន១៤ (ដប់បួន) ថ្ងៃ ហើយកូរ៉ុមសម្រាប់កិច្ចប្រជុំលើកទីពីរនេះគឺ ១/២ (មួយភាគពីរ) នៃសមាជិកទាំងអស់ គិតទាំងសមាជិកផ្ទេរសិទ្ធិ ។

ក្នុងករណីដែលកិច្ចប្រជុំលើកទីពីរពុំមានកូរ៉ុម មហាសន្និបាតនេះត្រូវពន្យាររយៈពេលចំនួន១៤ (ដប់បួន) ថ្ងៃទៀត ហើយប្រសិនបើនៅតែគ្មានកូរ៉ុមនៅក្នុងកិច្ចប្រជុំនេះទៀត ចំនួនអ្នកចូលរួមក្នុងកិច្ចប្រជុំដែលត្រូវពន្យាពេលជាលើកទីពីរ នោះត្រូវចាត់ទុកថាជាកូរ៉ុមដើម្បីចាប់ផ្តើមមហាសន្និបាត ។

ការបោះឆ្នោតតាមរយៈសិទ្ធិប្រទានត្រូវបានអនុញ្ញាតប៉ុន្តែសមាជិកម្នាក់អាចទទួលបានសិទ្ធិប្រទានតែមួយប៉ុណ្ណោះ ។ សិទ្ធិប្រទានត្រូវធ្វើជាលាយលក្ខណ៍អក្សរ ហើយត្រូវចុះក្នុងកំណត់ហេតុប្រជុំ ។

**មាត្រា៧.–**

មហាសន្និបាតវិសាមញ្ញ ត្រូវបានកោះប្រជុំដោយប្រធានក្រុមប្រឹក្សាប្រតិបត្តិ និងតាមពេលកំណត់ដោយក្រុមប្រឹក្សាប្រតិបត្តិ ។

ប្រសិនបើប្រធានក្រុមប្រឹក្សាប្រតិបត្តិ មិនបានកោះប្រជុំមហាសន្និបាតវិសាមញ្ញ ក្នុងរយៈពេល៣ (បី) ខែ បន្ទាប់ពីបានទទួលសំណើជាលាយលក្ខណ៍អក្សរទេនោះ សមាជិកដែលស្នើសុំឱ្យមានមហាសន្និបាតវិសាមញ្ញ អាចបើកមហាសន្និបាតវិសាមញ្ញតាមរយៈការជូនដំណឹងទៅសមាជិកទាំងអស់ ក្នុងរយៈពេល៣០ (សាមសិប) ថ្ងៃជាមុន ដោយរៀបរាប់អំពីបញ្ហាដែលត្រូវពិភាក្សា ហើយត្រូវបិទផ្សាយរបៀបវារៈរបស់ខ្លួន នៅលើក្តារព័ត៌មានក្នុងបរិវេណ **ម.ជ.ម.** ។

## ផ្នែកទី២
## ក្រុមប្រឹក្សាប្រតិបត្តិ

**មាត្រា៨.–**

**ម.ជ.ម.** គ្រប់គ្រងដោយក្រុមប្រឹក្សាប្រតិបត្តិ ដែលត្រូវជួបប្រជុំរៀងរាល់ខែ ។ ក្រុមប្រឹក្សាប្រតិបត្តិត្រូវមានសមាជិកមិនលើសពី ៧ (ប្រាំពីរ) រូបឡើយ ។

សមាសភាពក្រុមប្រឹក្សាប្រតិបត្តិរួមមាន ÷

- ប្រធានមួយរូប
- អនុប្រធានមួយរូប

- ហេរញ្ញិកមួយរូប
- សមាជិកមួយចំនួន ។

**មាត្រា៩.–**

ក្រុមប្រឹក្សាប្រតិបត្តិគ្រប់គ្រងនិងសម្រេចការងារប្រចាំថ្ងៃ ។ សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាប្រតិបត្តិមានអានុភាពអនុវត្ត លើកលែងតែសេចក្តីសម្រេចនោះ ត្រូវបានបដិសេធដោយមហាសន្និបាត ។

**មាត្រា១០.–**

ក្រុមប្រឹក្សាប្រតិបត្តិបំពេញតួនាទីផ្សេងៗទៀតមានជាអាទិ៍ ÷

- ជ្រើសរើសបុគ្គលិកឱ្យបម្រើការងារជាអគ្គលេខាធិការរបស់ **ម.ខ.ម.**
- កំណត់ចំនួនបុគ្គលិក និយោជិត លក្ខខណ្ឌការងារ ប្រាក់បៀវត្ស កម្រៃសេវា ឬលក្ខខណ្ឌដទៃទៀត
- បញ្ឈប់ការងារនិងដាក់វិន័យលើបុគ្គលិក ដោយផ្អែកតាមកិច្ចសន្យាការងារ ។

**មាត្រា១១.–**

ក្រុមប្រឹក្សាប្រតិបត្តិត្រូវធ្វើរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំ គម្រោងថវិកាប្រចាំឆ្នាំ និងរបាយការណ៍ស្តីពីសកម្មភាពការងាររបស់ **ម.ខ.ម.** ជូនមហាសន្និបាតប្រចាំឆ្នាំ ។

**មាត្រា១២.–**

សមាជិករបស់ក្រុមប្រឹក្សាប្រតិបត្តិ ត្រូវបានបោះឆ្នោតជ្រើសតាំងនៅក្នុងមហាសន្និបាតនៃ **ម.ខ.ម.** ។

សមាជិកក្រុមប្រឹក្សាប្រតិបត្តិមានអាណត្តិ ៣ (បី)ឆ្នាំ ហើយសមាជិកទាំងអស់អាចធ្វើជាសមាជិកនៃក្រុមប្រឹក្សាប្រតិបត្តិមិនលើសពី ២(ពីរ) អាណត្តិឡើយ ។ សមាជិកក្រុមប្រឹក្សាប្រតិបត្តិទាំងអស់អាចត្រូវបានបោះឆ្នោតសម្រាប់ ២ (ពីរ) អាណត្តិជាប់គ្នា លើកលែងតែមុខតំណែងជាហេរញ្ញិកដែលមិនអាចត្រូវបានជ្រើសរើស ២(ពីរ) អាណត្តិជាប់គ្នា ។

**មាត្រា១៣.–**

ប្រធាន អនុប្រធាន និងហេរញ្ញិក ត្រូវបានជ្រើសរើសតាមរយៈការបោះឆ្នោតដោយឡែកពីគ្នាក្នុងចំណោមសមាជិកក្រុមប្រឹក្សាប្រតិបត្តិដោយក្រុមប្រឹក្សាប្រតិបត្តិ ។

**មាត្រា១៤.–**

ប្រធានក្រុមប្រឹក្សាប្រតិបត្តិត្រូវបានបោះឆ្នោតជ្រើសរើសនៅក្នុងកិច្ចប្រជុំលើកដំបូងរបស់ខ្លួន ។ ការបោះឆ្នោតជ្រើសរើសប្រធានត្រូវធ្វើជា ២ (ពីរ)ជុំ ប្រសិនបើជុំទី១ គ្មានបេក្ខជនណាទទួលសំឡេងភាគច្រើនដាច់ខាតទេ ។ ការបោះឆ្នោតនៃជុំទីពីរ គឺយកតែបេក្ខជនពីររូបដែលមានសំឡេងឆ្នោតច្រើន[illegible]ឈ្មោះមកឱ្យឈរឈ្មោះ ។

ដោយឡែកអនុប្រធាននិងហេរញ្ញិក ត្រូវបោះឆ្នោតជ្រើសរើសដោយយកតាមសំឡេងភាគច្រើនធម្មតា ក្នុងករណីមានសំឡេងស្មើគ្នា ត្រូវយកអ្នកមានអាយុច្រើនជាងគេ។

សមាជិកភាគច្រើននៃក្រុមប្រឹក្សាប្រតិបត្តិ ត្រូវមានសញ្ជាតិខ្មែរ។ ដោយឡែក ប្រធាន និង ហេរញ្ញិក ត្រូវមានសញ្ជាតិខ្មែរ។

ប្រធានរបស់ក្រុមប្រឹក្សាប្រតិបត្តិ គឺជាប្រធានរបស់ **ម.ឌ.ម.**។

អនុប្រធាន ត្រូវជួយការងាររបស់ប្រធាន ហើយជំនួសប្រធាននៅពេលដែលប្រធានអវត្តមាន។

ហេរញ្ញិក ត្រូវគ្រប់គ្រងមូលនិធិ ប្រមូលចំណូលនិងចាត់ចែងចំណាយក្នុងនាម **ម.ឌ.ម.** ហើយត្រូវមានគណនីចរន្តនិងត្រូវទទួលខុសត្រូវពីភាពត្រឹមត្រូវនៃគណនីទាំងនោះ។

សមាជិករបស់ក្រុមប្រឹក្សាប្រតិបត្តិ ត្រូវជួយការងារ **ម.ឌ.ម.**និងបំពេញភារកិច្ច ដែលក្រុមប្រឹក្សាប្រតិបត្តិប្រគល់ជូន។

## មាត្រា១៥._

ក្នុងករណីតំណែងប្រធាន អនុប្រធាន ឬហេរញ្ញិក របស់ក្រុមប្រឹក្សាប្រតិបត្តិនៃ **ម.ឌ.ម.** នៅទំនេរដោយសារការលាលែងពីមុខតំណែង ក្រុមប្រឹក្សាប្រតិបត្តិត្រូវបោះឆ្នោតជ្រើសរើសសមាជិករបស់ខ្លួនម្នាក់ទៀតឱ្យចូលកាន់មុខតំណែងដែលនៅទំនេរនោះនៅក្នុងកិច្ចប្រជុំបន្ទាប់ ឬនៅឯកិច្ចប្រជុំណាមួយដ៏ខ្លី បន្ទាប់ពីការលាលែងនោះ។

## មាត្រា១៦._

សមាជិកគ្រប់រូបរបស់ **ម.ឌ.ម.** ទោះរូបវន្តបុគ្គលក្តី អ្នកតំណាងផ្ទេរសិទ្ធិដែលទទួលបានការចាត់តាំងពីសភាពាណិជ្ជកម្មរាជធានី ខេត្តនៃព្រះរាជាណាចក្រកម្ពុជា សភាមុខរបរនិងមីក្រូសហគ្រាស គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា និងសមាគមដែលប្រមូលផ្តុំពាណិជ្ជករ ឧស្សាហករ អាជីវករ និងសេវាករក្តី មានសិទ្ធិឈរឈ្មោះឱ្យមហាសន្និបាតបោះឆ្នោតជាសមាជិកក្រុមប្រឹក្សាប្រតិបត្តិ លុះត្រាតែបានចុះឈ្មោះ ជាមជ្ឈត្តករក្នុងបញ្ជីនៃ **ម.ឌ.ម.**។

## មាត្រា១៧._

ក្នុងរយៈពេល៦០ (ហុកសិប) ថ្ងៃ មុនកាលបរិច្ឆេទដែលត្រូវបានកំណត់ សម្រាប់មហាសន្និបាតប្រចាំឆ្នាំ ក្រុមប្រឹក្សាប្រតិបត្តិត្រូវធ្វើការកំណត់ និងផ្សព្វផ្សាយនូវ ÷

- កាលបរិច្ឆេទនៃការជ្រើសរើសបេក្ខជន
- កាលបរិច្ឆេទបោះឆ្នោត ដែលមិនត្រូវតិចជាង៣ (បី) សប្តាហ៍ បន្ទាប់ពីកាលបរិច្ឆេទនៃការជ្រើសរើសបេក្ខជន
- ទីកន្លែងដែលមានភាពងាយស្រួលក្នុងបរិវេណ **ម.ឌ.ម.** ឬកន្លែងផ្សេងទៀតសម្រាប់រៀបចំការបោះឆ្នោតជាសម្ងាត់។

**មាត្រា១៨.–**

ការបោះឆ្នោតជ្រើសរើសសមាជិកទាំងអស់ ឬសមាជិកណាម្នាក់របស់ក្រុមប្រឹក្សាប្រតិបត្តិ ត្រូវធ្វើឡើងតាមរយៈការបោះឆ្នោតជាសម្ងាត់ ដោយសមាជិកមួយរូបមានសំឡេងឆ្នោតមួយសំឡេង ក្នុងមហាសន្និបាតប្រចាំឆ្នាំ ឬមហាសន្និបាតវិសាមញ្ញ ដោយអនុលោមតាមវិធានកំណត់ដោយមហាសន្និបាត ។

ក្រុមប្រឹក្សាប្រតិបត្តិថ្មីដែលទើបកើតឡើងក្រោយពីមានការបោះឆ្នោតត្រូវចូលកាន់មុខតំណែងនៅក្រោយពេលមហាសន្និបាតប្រចាំឆ្នាំ ។

**មាត្រា១៩.–**

មជ្ឈត្តករដែលឈរឈ្មោះបោះឆ្នោត ជាសមាជិកក្រុមប្រឹក្សាប្រតិបត្តិ ត្រូវមានលក្ខខណ្ឌដូចខាងក្រោម ÷

- សមាជិក **ម.ជ.ម.** ពីររូបអាចស្នើតែងតាំងសមាជិក **ម.ជ.ម.** បានតែម្នាក់ប៉ុណ្ណោះធ្វើជាបេក្ខជន
- សំណើតែងតាំងបេក្ខជនត្រូវមានការយល់ព្រមពីសាមីខ្លួនផ្ទាល់
- សំណើតែងតាំងត្រូវធ្វើជាលាយលក្ខណ៍អក្សរ និងមានចុះហត្ថលេខា ។

**មាត្រា២០.–**

បើសិនបេក្ខជនឈរឈ្មោះមានចំនួនតិចជាង ឬស្មើនឹងតំណែងដែលត្រូវបោះឆ្នោតរើស សម្រាប់ធ្វើជាសមាជិកក្រុមប្រឹក្សាប្រតិបត្តិ ការជ្រើសរើសត្រូវពន្យាររយៈពេល១៥(ដប់ប្រាំ)ថ្ងៃទៀត ។ ក្រោយរយៈពេលពន្យារ ១៥ (ដប់ប្រាំ) ថ្ងៃ ប្រសិនបើបេក្ខជននៅតែមានចំនួនតិចជាង ឬស្មើនឹងតំណែងដែលត្រូវបោះឆ្នោតជ្រើសរើស បេក្ខជនទាំងនោះត្រូវចាត់ទុកថាជាប់ឆ្នោតដោយស្វ័យប្រវត្តិ ។ ក្នុងករណីដែលបេក្ខជនឈរឈ្មោះមិនគ្រប់ចំនួន មហាសន្និបាតអាចតែងតាំងបេក្ខជនបន្ថែមតាមនីតិវិធីដដែល ។ ក្នុងករណីដែលបេក្ខជនមានចំនួនលើសពីចំនួនតំណែង ដែលត្រូវជ្រើសរើស មហាសន្និបាតត្រូវធ្វើការបោះឆ្នោត ។

**មាត្រា២១.–**

សមាជិកក្រុមប្រឹក្សាប្រតិបត្តិត្រូវបាត់បង់មុខតំណែងក្នុងករណីដូចខាងក្រោម ÷

- ក្លាយជាអសមត្ថជនផ្នែករូបរាងកាយ និងសតិស្មារតី មិនអាចបំពេញមុខងាររបស់ខ្លួនបាន
- ត្រូវបានផ្តន្ទាទោសពីបទល្មើសមជ្ឈិម ឬឧក្រិដ្ឋណាមួយ
- អវត្តមានពីកិច្ចប្រជុំ ៣ (បី)ដង ជាប់ៗគ្នាដោយគ្មានមូលហេតុ
- ត្រូវបានវិនិច្ឆ័យថា ក្ស័យធនដោយតុលាការ
- សុំលាលែងជាលាយលក្ខណ៍អក្សរពីក្រុមប្រឹក្សាប្រតិបត្តិ
- លែងជាសមាជិករបស់ **ម.ជ.ម.**
- លែងជាតំណាងចាត់តាំងរបស់អង្គការសមាជិក

- ទទួលមរណភាព។

**មាត្រា២២.–**

ក្រៅពីការប្រជុំប្រចាំខែ ប្រធានក្រុមប្រឹក្សាប្រតិបត្តិ អាចកោះប្រជុំក្រុមប្រឹក្សាប្រតិបត្តិពេលណាក៏បាន ដោយជូនដំណឹងទៅកាន់សមាជិកក្រុមប្រឹក្សាប្រតិបត្តិ រយៈពេល ៧ ( ប្រាំពីរ) ថ្ងៃជាមុន។ យ៉ាងហោចណាស់ត្រូវមានសមាជិក ២/៣ ( ពីរភាគបី) វត្តមាន ដើម្បីឱ្យដំណើរការប្រជុំមានសុពលភាព។

បញ្ហានានាដែលត្រូវបានលើកឡើងមកពិភាក្សា នៅក្នុងកិច្ចប្រជុំក្រុមប្រឹក្សាប្រតិបត្តិ ត្រូវសម្រេចដោយសំឡេងភាគច្រើន ហើយក្នុងករណីមានសំឡេងស្មើគ្នា សំឡេងប្រធានមានឧត្តមានុភាព។

**មាត្រា២៣.–**

ក្នុងករណីមានសមាជិកក្រុមប្រឹក្សាប្រតិបត្តិបាត់បង់សមាជិកភាពរបស់ខ្លួន ប្រធាន **ម.ជ.ម.** ត្រូវកោះប្រជុំសន្និបាតវិសាមញ្ញ ដើម្បីធ្វើការជ្រើសរើសសមាជិកបង្គ្រប់។ អាណត្តិរបស់សមាជិកជំនួសនេះជាអាណត្តិរបស់សមាជិក ដែលបានបាត់បង់សមាជិកភាព។

**មាត្រា២៤.–**

ក្រុមប្រឹក្សាប្រតិបត្តិ អាចបង្កើតគណៈកម្មាធិការ ឬអនុគណៈកម្មាធិការនានា ដែលមានសមាសភាពសមាជិកក្រុមប្រឹក្សាប្រតិបត្តិមួយរូប ឬច្រើនរូបដឹកនាំការងារ។ ការរៀបចំគណៈកម្មាធិការ ឬអនុគណៈកម្មាធិការនានាត្រូវកំណត់ដោយបទបញ្ជាផ្ទៃក្នុងរបស់ **ម.ជ.ម.** ។

## ផ្នែកទី៣

## អគ្គលេខាធិការដ្ឋាន

**មាត្រា២៥.–**

អគ្គលេខាធិការដ្ឋាននៃ **ម.ជ.ម.** ត្រូវដឹកនាំដោយអគ្គលេខាធិការមួយរូប អមដោយអគ្គលេខាធិការរងមួយចំនួនជាជំនួយការ ដែលត្រូវជ្រើសរើសដោយក្រុមប្រឹក្សាប្រតិបត្តិ។

ការរៀបចំនិងការប្រព្រឹត្តទៅរបស់អគ្គលេខាធិការដ្ឋាននៃ **ម.ជ.ម.** ត្រូវកំណត់ដោយបទបញ្ជាផ្ទៃក្នុង។

**មាត្រា២៦.–**

អគ្គលេខាធិការដ្ឋាននៃ **ម.ជ.ម.** មានតួនាទីជាសេនាធិការឱ្យក្រុមប្រឹក្សាប្រតិបត្តិ និងមានភារកិច្ចដូចខាងក្រោម ÷

- គ្រប់គ្រងលើការងារនិងសកម្មភាពប្រចាំថ្ងៃរបស់ **ម.ជ.ម.**
- អនុវត្តគោលនយោបាយដែលក្រុមប្រឹក្សាប្រតិបត្តិដាក់ចេញ
- រៀបចំកិច្ចប្រជុំរបស់ក្រុមប្រឹក្សាប្រតិបត្តិ មហាសន្និបាត និងកិច្ចប្រជុំផ្សេងទៀត

- រក្សាឯកសារ
- ប្រមូលព័ត៌មានដែលពាក់ព័ន្ធនិងសកម្មភាពមជ្ឈត្តការផ្នែកពាណិជ្ជកម្មដែលអាចមានប្រយោជន៍ដល់សមាជិករបស់ **ម.ជ.ម.**
- ផ្តួចផ្តើមគំនិតលើកិច្ចការថ្មីៗ និងរៀបចំសកម្មភាព និងគម្រោងនានាដែលជួយទ្រទ្រង់តួនាទីរបស់ **ម.ជ.ម.**
- ផ្តល់សេវាផ្នែកលេខាធិការដល់សមាជិក ដោយយកកម្រៃសេវាស្របតាមលក្ខខណ្ឌ ដែលអនុម័តដោយក្រុមប្រឹក្សាប្រតិបត្តិ
- ទ្រទ្រង់ផ្នែកបោះពុម្ពនានារបស់ **ម.ជ.ម.** រួមទាំងកាន់កាប់គេហទំព័ររបស់ **ម.ជ.ម.**
- រៀបចំការបណ្តុះបណ្តាល
- បំពេញភារកិច្ចផ្សេងៗដែលក្រុមប្រឹក្សាប្រតិបត្តិប្រគល់ជូន។

**មាត្រា២៧.–**

**ម.ជ.ម.** មានសិទ្ធិប្រើត្រាដោយឡែករបស់ខ្លួន។

## ផ្នែកទី៤
## សមាជិកនៃ ម.ជ.ម.

**មាត្រា២៨.–**

បុគ្គលទាំងឡាយដែលចង់ក្លាយជាសមាជិកនៃ **ម.ជ.ម.** ត្រូវចុះបញ្ជីជាមជ្ឈត្តករនៅ **ម.ជ.ម.**។

រាល់ពាក្យសុំចុះឈ្មោះទាំងអស់ ត្រូវដាក់ជូនទៅក្រុមប្រឹក្សាប្រតិបត្តិរបស់ **ម.ជ.ម.** ព្រមទាំងភ្ជាប់មកជាមួយនូវឯកសារផ្សេងៗ តាមការតម្រូវរបស់ក្រុមប្រឹក្សាប្រតិបត្តិ និងបង់ភាគទានតាមការកំណត់របស់ **ម.ជ.ម.**។

**មាត្រា២៩.–**

រូបវន្តបុគ្គលដែលមានសញ្ជាតិខ្មែរ ឬបរទេស អាចដាក់ពាក្យសុំធ្វើជាមជ្ឈត្តករជាមួយ **ម.ជ.ម.** បាន បើសិនជារូបវន្តបុគ្គលនោះ មានលក្ខណសម្បត្តិដូចខាងក្រោម ÷

- មានអាយុចាប់ពី ៣០ (សាមសិប) ឆ្នាំឡើង
- មានសញ្ញាបត្របរិញ្ញាបត្រជំនាញណាមួយ ក្រោយពីបានបញ្ចប់ការសិក្សានៅតាមសកលវិទ្យាល័យក្នុងព្រះរាជាណាចក្រកម្ពុជា ឬនៅបរទេស និង
- បានឆ្លងកាត់វគ្គបណ្តុះបណ្តាលផ្នែកមជ្ឈត្តការផ្នែកពាណិជ្ជកម្មជាមួយ **ម.ជ.ម.** ឬ [illegible]

- មជ្ឈមណ្ឌលនៃមជ្ឈត្តការផ្នែកពាណិជ្ជកម្មអន្តរជាតិនានា ដែលទទួលស្គាល់ដោយ **ម.ជ.ម.** ។

ប្រសិនបើពុំមានលក្ខណសម្បត្តិដូចខាងលើទេ រូបវន្តបុគ្គលដែលមានសញ្ជាតិខ្មែរ ឬបរទេសនោះត្រូវជាបុគ្គលដែលធ្លាប់ធ្វើជា ÷

- សមាជិកនៃស្ថាប័នវិជ្ជាជីវៈផ្នែកមជ្ឈត្តការផ្នែកពាណិជ្ជកម្ម ដែលទទួលស្គាល់ដោយ **ម.ជ.ម.** ឬ
- មជ្ឈត្តករ ឬអ្នកតំណាងក្នុងដំណើរការមជ្ឈត្តការផ្នែកពាណិជ្ជកម្មចាប់ពី៣ (បី) ដង ឡើងទៅ ឬបានសរសេរសេចក្ដីបង្គាប់មជ្ឈត្តការផ្នែកពាណិជ្ជកម្ម ចំនួនយ៉ាងតិច៣ (បី) ក្នុងពេលដែលបុគ្គលនោះធ្វើជាមជ្ឈត្តករ ។

ទោះបីដូចមានចែងខាងលើក៏ដោយ និងក្រោយពីមានការយល់ព្រមពីមហាសន្និបាត ក្រុមប្រឹក្សាប្រតិបត្តិអាចកំណត់នូវលក្ខណវិនិច្ឆ័យបន្ថែមផ្សេងទៀត ដែលខ្លួនគិតថា សមស្រប និងមានប្រយោជន៍ដល់ **ម.ជ.ម.** ។

**មាត្រា៣០.-**

មជ្ឈត្តករ ÷

- មិនត្រូវស្ថិតនៅក្នុងឋានានុក្រមជាមន្ត្រីនៃស្ថាប័ននីតិប្រតិបត្តិ ស្ថាប័ននីតិប្បញ្ញត្តិ និងតុលាការ
- មិនធ្លាប់ត្រូវបានផ្ដន្ទាទោសពីបទមជ្ឈិម ឬឧក្រិដ្ឋណាមួយ ។

**មាត្រា៣១.-**

**ម.ជ.ម.** ត្រូវរៀបចំបញ្ជីឈ្មោះសមាជិករបស់ខ្លួន ដែលមានចុះព័ត៌មានដូចខាងក្រោម ÷

- ឈ្មោះនិងអាសយដ្ឋាន
- កាលបរិច្ឆេទនៃការចុះបញ្ជី
- លក្ខណសម្បត្តិនិង
- ព័ត៌មានចាំបាច់ដទៃទៀត ដែលកំណត់ដោយក្រុមប្រឹក្សាប្រតិបត្តិ ។

**មាត្រា៣២.-**

ក្រុមប្រឹក្សាប្រតិបត្តិត្រូវបដិសេធការចុះបញ្ជីឱ្យបេក្ខជនណាមួយ ដែលពុំមានលក្ខណសម្បត្តិគ្រប់គ្រាន់ តាមមាត្រា២៩ និង៣០ នៃអនុក្រឹត្យនេះ ។

**មាត្រា៣៣.-**

វិញ្ញាបនបត្រចុះបញ្ជី ត្រូវសុំបន្តជារៀងរាល់ឆ្នាំតាមរយៈការបង់ភាគទានប្រចាំឆ្នាំ ។

រៀងរាល់ឆ្នាំ **ម.ជ.ម.** ត្រូវប្រកាសជាសាធារណៈ នូវឈ្មោះរបស់មជ្ឈត្តករដែលបានចុះបញ្ជី

សមាជិក **ម.ជ.ម.** ត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរ នូវរាល់ការផ្លាស់ប្តូរអាសយដ្ឋានវិជ្ជាជីវៈ ឬ អាសយដ្ឋានផ្ទាល់ខ្លួន ក្នុងរយៈពេល ១ (មួយ) ខែ គិតចាប់ពីថ្ងៃផ្លាស់ប្តូរនោះ។

**មាត្រា៣៤.–**

សភាពាណិជ្ជកម្មរាជធានី ខេត្ត នៃព្រះរាជាណាចក្រកម្ពុជា សភាមុខរបរនិងមីក្រូសហគ្រាស គណៈមេធាវី នៃព្រះរាជាណាចក្រកម្ពុជា និងសមាគមដែលប្រមូលផ្តុំពាណិជ្ជករ ឧស្សាហករ អាជីវករ និងសេវាករ អាចតែងតាំងបុគ្គលមួយរូបធ្វើជាតំណាង និងបោះឆ្នោតក្នុងមហាសន្និបាតនានារបស់ **ម.ជ.ម.**។ ក្នុងករណីលាលែង ឬឈប់ធ្វើការជាមួយអង្គការដែលខ្លួនជាតំណាង បុគ្គលរូបនោះលែងមានសិទ្ធិជាអ្នកតំណាងរបស់អង្គការសមាជិកនោះដោយស្វ័យប្រវត្តិ។ ក្រុមប្រឹក្សាប្រតិបត្តិមានសិទ្ធិបដិសេធអ្នកតំណាង ដែលតែងតាំងដោយអង្គការសមាជិកណាមួយ ប្រសិនបើពុំមានលក្ខណសម្បត្តិគ្រប់គ្រាន់។

**មាត្រា៣៥.–**

សមាជិក **ម.ជ.ម.** ត្រូវបាត់បង់សមាជិកភាពរបស់ខ្លួន ក្នុងករណីណាមួយដូចខាងក្រោមនេះ ÷

- មិនបានបន្តចុះបញ្ជីជាមជ្ឈត្តករជាមួយ **ម.ជ.ម.** តាមការកំណត់
- ក្លាយជាអសមត្ថជនផ្នែករូបរាងកាយនិងសតិស្មារតី ដែលមិនអាចបំពេញមុខងាររបស់ខ្លួនបាន
- ត្រូវបានវិនិច្ឆ័យថា ក្ស័យធន ឬត្រូវដាក់ឱ្យជម្រះបញ្ជី
- សុំលាលែងជាលាយលក្ខណ៍អក្សរទៅកាន់ **ម.ជ.ម.**
- ត្រូវបានផ្តន្ទាទោសពីបទមជ្ឈិម ឬឧក្រិដ្ឋ
- បានរំលោភលើក្រមសីលធម៌របស់មជ្ឈត្តករនិងបទបញ្ជាផ្ទៃក្នុង
- ទទួលមរណភាព
- ខកខានមិនបានបង់ភាគទានតាមការកំណត់

ការបាត់បង់សមាជិកភាពនេះត្រូវសម្រេចដោយក្រុមប្រឹក្សាប្រតិបត្តិ។

**មាត្រា៣៦.–**

ការដកហូតសមាជិកភាពរបស់សមាជិកណាម្នាក់ អាចធ្វើទៅបាន លុះត្រាតែសមាជិកនោះ ត្រូវបានផ្តល់ឱកាសដើម្បីធ្វើការដោះសារជាលាយលក្ខណ៍អក្សរតែមិនបានដោះសារតាមពេលវេលាកំណត់។ ក្នុងករណីដែលក្រុមប្រឹក្សាប្រតិបត្តិសម្រេចដកហូតសមាជិកភាពពី **ម.ជ.ម.** ក្រុមប្រឹក្សាត្រូវផ្តល់ហេតុផលជាលាយលក្ខណ៍អក្សរ។ ក្នុងករណីដែលសាមីខ្លួនមិនសុខចិត្តនឹងសេចក្តីសម្រេចនេះ សមាជិកនោះមានសិទ្ធិប្តឹងទៅ[illegible]

**មាត្រា៣៧.-**

សមាជិក **ម.ជ.ម.** ត្រូវទទួលក្នុងរយៈពេល ២ (ពីរ) ឆ្នាំម្តងយ៉ាងតិចនូវការបណ្តុះបណ្តាលបន្ត ដែលរៀបចំដោយ **ម.ជ.ម.** ឬរៀបចំដោយស្ថាប័នជាតិ និងអន្តរជាតិដែលទទួលស្គាល់ដោយ **ម.ជ.ម.** ។

នៅក្នុងការចុះបញ្ជីបន្តជាមជ្ឈត្តករនៅ **ម.ជ.ម.** ក្រុមប្រឹក្សាប្រតិបត្តិអាចបដិសេធការចុះបញ្ជីរបស់សមាជិកណាម្នាក់បាន ក្នុងករណីដែលសមាជិកនោះខកខានមិនបានធ្វើការបណ្តុះបណ្តាលវិជ្ជាជីវៈបន្ត ។

**មាត្រា៣៨.-**

នៅក្នុងកាលៈទេសៈពិសេសដែលកំណត់ដោយក្រុមប្រឹក្សាប្រតិបត្តិ ក្រុមប្រឹក្សាប្រតិបត្តិ អាចចុះបញ្ជីបន្តសម្រាប់មជ្ឈត្តករណាម្នាក់បាន ទោះបីមជ្ឈត្តករនោះខកខានមិនបានបំពេញលក្ខខណ្ឌ ដូចមានចែងក្នុងមាត្រា ៣៧ ខាងលើ ។

## ផ្នែកទី៥

## សវនកម្ម

**មាត្រា៣៩.-**

ក្រុមហ៊ុនសវនកម្មដែលទទួលបានការអនុម័តយល់ព្រមពីមហាសន្និបាត ត្រូវបានជ្រើសតាំងជាសវនកររបស់ **ម.ជ.ម.** សម្រាប់រយៈពេល ១ (មួយ) ឆ្នាំ ហើយអាចត្រូវបានជ្រើសតាំងសារជាថ្មីទៀតបាន ។

**មាត្រា៤០.-**

សវនករមានតួនាទីនិងភារកិច្ច ដូចខាងក្រោម ÷

- ធ្វើសវនកម្មប្រចាំឆ្នាំ និងបង្ហាញរបាយការណ៍សវនកម្មរបស់ខ្លួន ក្នុងមហាសន្និបាតប្រចាំឆ្នាំ
- ធ្វើសវនកម្មតាមការស្នើសុំរបស់ប្រធាន **ម.ជ.ម.** សម្រាប់រយៈពេលណាមួយក៏បាន និងនៅគ្រប់ពេលវេលានៅក្នុងអំឡុងពេលនៃកិច្ចសន្យា ហើយត្រូវធ្វើរបាយការណ៍ជូនក្រុមប្រឹក្សាប្រតិបត្តិ ។

សមាជិកនិងបុគ្គលិកគ្រប់រូបរបស់ **ម.ជ.ម.** មានកាតព្វកិច្ចផ្តល់ព័ត៌មាន និងសេចក្តីពន្យល់នានាដែលតម្រូវដោយសវនករ ។

## ផ្នែកទី៦

## សាខារបស់ម.ជ.ម.

**មាត្រា៤១.-**

**ម.ជ.ម.** អាចបង្កើតសាខារបស់ខ្លួនបាននៅតាមខេត្តនានា នៅក្នុងព្រះរាជាណាចក្រកម្ពុជា ។ ការរៀបចំ និងការប្រព្រឹត្តទៅរបស់សាខានីមួយៗត្រូវកំណត់ដោយសេចក្តីសម្រេចរបស់ **ម.ជ.ម.** ។

## ជំពូកទី៤

## ប្រភពធនធាន

**មាត្រា៤២.-**

ប្រភពធនធានរបស់ **ម.ជ.ម.** បានមកពី ÷

- ភាគទានរបស់សមាជិក
- អំណោយនិងវិភាគទានពីប្រភពផ្សេងៗ
- កម្រៃសេវាផ្នែករដ្ឋបាលរបស់ **ម.ជ.ម.** ។

**មាត្រា៤៣.-**

សមាជិកត្រូវបង់ភាគទានប្រចាំឆ្នាំ តាមការកំណត់របស់មហាសន្និបាតដែលស្នើដោយក្រុមប្រឹក្សាប្រតិបត្តិ ។

ភាគទានប្រចាំឆ្នាំត្រូវបង់ជាមុន ក្នុងអំលុងខែទីមួយរៀងរាល់ឆ្នាំ។ ប្រសិនបើសមាជិកណាម្នាក់ មានភាពយឺតយ៉ាវក្នុងការបង់ភាគទានប្រចាំឆ្នាំ ឬវិភាគទានដទៃទៀត ហើយហេរញ្ញិកត្រូវក្រើនរំលឹកជាបន្ទាន់ដល់សមាជិកនោះ ។

ប្រសិនបើសមាជិកណាម្នាក់ មានការយឺតយ៉ាវក្នុងការបង់ភាគទានប្រចាំឆ្នាំ លើសពី ៣ (បី)ខែ ចាប់ពីខែទីពីរ សមាជិកនោះត្រូវបាត់បង់សមាជិកភាពរបស់ខ្លួន ដោយស្វ័យប្រវត្តិ ។

រាល់មូលនិធិបន្ថែមនានាដែលតម្រូវដោយ **ម.ជ.ម.** សម្រាប់គោលបំណងពិសេសណាមួយអាចប្រមូលពីបណ្ដាសមាជិកបាន លុះត្រាតែមានសំឡេងយល់ព្រមពីមហាសន្និបាតរបស់សមាជិកលើសពី៥០ (ហាសិប) ភាគរយ នៃសមាជិកដែលមានវត្តមានក្នុងមហាសន្និបាត ។

**មាត្រា៤៤.-**

បុគ្គលិករបស់ **ម.ជ.ម.** និងសមាជិករបស់ក្រុមប្រឹក្សាប្រតិបត្តិ ទទួលបានការធានារ៉ាប់រងពី **ម.ជ.ម.** ចំពោះរាល់ការបង់ថ្លៃចំណាយ និងការខាតបង់នានាក្នុងការបំពេញដ៏ត្រឹមត្រូវនូវភារកិច្ចរបស់ខ្លួន ។

## ជំពូកទី៥

## ការជ្រើសរើសមជ្ឈត្តករដំបូង

**មាត្រា៤៥.-**

ក្រសួងពាណិជ្ជកម្មត្រូវបង្កើតគណៈកម្មការរៀបចំ និងជ្រើសរើសមជ្ឈត្តករដំបូងមួយ ដែលមានសមាជិកមិនលើសពី ១២ (ដប់ពីរ)រូប ។

គណៈកម្មការនេះត្រូវដឹកនាំដោយតំណាងក្រសួងពាណិជ្ជកម្ម ដោយមានការចូលរួមពីតំណាងក្រសួង ស្ថាប័ន ដូចខាងក្រោម ÷

**មាត្រា៥០.–**

ការប្រជុំរបស់គណៈកម្មការអាចប្រព្រឹត្តទៅបាន លុះត្រាតែមានកូរ៉ុមលើសពី ៥០ (ហាសិប) ភាគរយ នៃចំនួនសមាជិក។ សេចក្តីសម្រេចរបស់គណៈកម្មការរៀបចំ និងជ្រើសរើសត្រូវធ្វើឡើងដោយសំឡេងភាគច្រើន នៃសមាជិកដែលមានវត្តមាន និងបោះឆ្នោតនៅក្នុងកិច្ចប្រជុំ។ ក្នុងករណីសំឡេងស្មើគ្នា សំឡេងខាងប្រធានមានឧត្តមានុភាព។

**មាត្រា៥១.–**

ឈ្មោះរបស់បុគ្គលដែលត្រូវបានជ្រើសរើសជាសមាជិកដំបូង ត្រូវបិទផ្សាយក្នុងរយៈពេល១៤ (ដប់បួន)ថ្ងៃ បន្ទាប់ពីថ្ងៃសម្រេចចុងក្រោយ ហើយបុគ្គលដែលជាប់ឈ្មោះទាំងនោះត្រូវឆ្លងកាត់វគ្គបណ្តុះបណ្តាលមជ្ឈត្តការផ្នែកពាណិជ្ជកម្ម ដែលរៀបចំដោយក្រសួងពាណិជ្ជកម្ម។

**មាត្រា៥២.–**

បុគ្គលដែលត្រូវបានជ្រើសរើសដំបូង មិនតិចជាង៥០ (ហាសិប) រូប ត្រូវដាក់ពាក្យសុំធ្វើជាមជ្ឈត្តករនៅ **ម.ជ.ម.** ក្រោយពីបានបញ្ចប់វគ្គបណ្តុះបណ្តាលមជ្ឈត្តការផ្នែកពាណិជ្ជកម្ម។

**មាត្រា៥៣.–**

ក្រសួងពាណិជ្ជកម្មត្រូវទទួលខុសត្រូវ ក្នុងការរៀបចំបង្កើតការិយាល័យចុះបញ្ជីមជ្ឈត្តករជាលើកដំបូង និងត្រូវគ្រប់គ្រងការិយាល័យនេះរហូតដល់ពេលដែល **ម.ជ.ម.** ដំណើរការងារដំបូងរបស់ខ្លួន ហើយមានការបោះឆ្នោតជ្រើសតាំងក្រុមប្រឹក្សាប្រតិបត្តិ។

## ជំពូកទី៦

## អន្តរប្បញ្ញត្តិ

**មាត្រា៥៤.–**

ក្រោយពីសមាជិក **ម.ជ.ម.** ត្រូវបានជ្រើសរើសនិងក្រុមប្រឹក្សាប្រតិបត្តិ ត្រូវបានបោះឆ្នោតរួចមក ក្រសួងពាណិជ្ជកម្មត្រូវសហការជាមួយ **ម.ជ.ម.** ក្នុងការផ្ទេរបញ្ជីឈ្មោះមជ្ឈត្តករទៅឱ្យអ្នកកាន់បញ្ជីរបស់ **ម.ជ.ម.** រួមទាំងមូលនិធិ និងទ្រព្យនានា ដែលជាកម្មសិទ្ធិ ឬក្លាយជាកម្មសិទ្ធិរបស់ **ម.ជ.ម.**។

ភារកិច្ចគណៈកម្មការត្រូវបញ្ចប់ នៅពេលក្រុមប្រឹក្សាប្រតិបត្តិ **ម.ជ.ម.** ចូលកាន់ការងារ។

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងយុត្តិធម៌
- សហព័ន្ធនិយោជក
- សភាពាណិជ្ជកម្មកម្ពុជា
- គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា
- សភាពាណិជ្ជកម្មអន្តរជាតិនៃកម្ពុជា
- សមាគមរោងចក្រកាត់ដេរកម្ពុជា
- សភាមុខរបរនិងមីក្រូសហគ្រាស
- បុគ្គលដទៃទៀតដែលក្រសួងពាណិជ្ជកម្ម និងក្រសួងយុត្តិធម៌យល់ថា សមស្រប ។

**មាត្រា៤៦.-**

ក្រសួងពាណិជ្ជកម្មត្រូវចេញប្រកាសតែងតាំងសមាសភាពគណៈកម្មការរៀបចំនិងជ្រើសរើសមជ្ឈតករដំបូង ។ សមាជិកម្នាក់ៗត្រូវចូលរួមដោយផ្ទាល់ ក្នុងរាល់ការប្រជុំរបស់គណៈកម្មការតាមការអញ្ជើញរបស់ប្រធាន ។

**មាត្រា៤៧.-**

គណៈកម្មការរៀបចំ និងជ្រើសរើសនោះត្រូវរៀបចំធ្វើការជ្រើសរើសចេញពីពាក្យស្នើសុំរបស់បេក្ខជនដំបូង ដែលមានចំនួនមិនលើសពី ៦០ ( ហុកសិប ) រូប ដើម្បីឱ្យចុះឈ្មោះជាមជ្ឈត្តករដំបូងនៃ **ម.ជ.ម.** ។

**មាត្រា៤៨.-**

សេចក្តីជូនដំណឹងផ្សេងៗរបស់គណៈកម្មការត្រូវធ្វើឡើងតាមរយៈបណ្តាញសារព័ត៌មាន និងផ្ញើជូន អង្គការ ក្រសួង ស្ថាប័នទាំងអស់ និងបុគ្គលពាក់ព័ន្ធនានាដោយផ្ទាល់ ។

**មាត្រា៤៩.-**

អ្នកដាក់ពាក្យទាំងអស់ត្រូវផ្តល់ព័ត៌មានលម្អិតផ្ទាល់ខ្លួន និងព័ត៌មានអំពីលក្ខណសម្បត្តិរបស់ខ្លួនដូចបានកំណត់នៅក្នុងអនុក្រឹត្យនេះ និងតាមការកំណត់របស់គណៈកម្មការរៀបចំ និងជ្រើសរើសមជ្ឈត្តករដំបូង ។

គណៈកម្មការត្រូវធ្វើការប្រជុំតាមការចាំបាច់ ដើម្បីធ្វើការពិនិត្យលើពាក្យសុំ និងកំណត់ពីបេក្ខជន ដែលត្រូវជ្រើសរើសមិនតិចជាង ៥០ ( ហាសិប ) រូប ។

## ជំពូកទី៧

## អវសានប្បញ្ញត្តិ

**មាត្រា៥៥.–**

បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា៥៦.–**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែសីហា ឆ្នាំ២០០៩

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

**កន្លែងទទួល** :

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា៥៦
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

# ឧបសម្ព័ន្ធទី៣
# វិធានស្ដីពីមជ្ឈត្តការ របស់ម.ជ.ម

## ជំពូកទី ៥

# ដំណើរការមជ្ឈត្តការ

## ប្រការ ៣១. ទីកន្លែងធ្វើមជ្ឈត្តការ

លើកលែងតែគូភាគីវិវាទបានព្រមព្រៀងផ្សេងពីនេះ ឬដោយសារកាលៈទេសៈនានានៃសំណុំរឿងដែលវេទិកាមជ្ឈត្តកម្មសម្រេចថាទីកន្លែងធ្វើមជ្ឈត្តការផ្សេងទៀតមានលក្ខណៈសមស្របជាង ទីកន្លែងធ្វើមជ្ឈត្តការនៃមជ្ឈត្តកម្មទាំងអស់ដែលធ្វើឡើងក្រោមវិធាននេះ គឺរាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា។ ដូចមានចែងនៅក្នុងប្រការ ៣៩.៣ *(ទីកន្លែងសម្រាប់ប្រជុំ និងសវនាការ)* ទីកន្លែងធ្វើមជ្ឈត្តការមិនកំណត់អំពីទីកន្លែងដែលវេទិកាមជ្ឈត្តកម្មអាចជួបប្រជុំ និងធ្វើសវនាការនោះទេ។

## ប្រការ ៣២. ច្បាប់អនុវត្ត និងសមធម៌

### *៣២.១.ច្បាប់អនុវត្ត*

គូភាគីវិវាទ មានសេរីភាពក្នុងការព្រមព្រៀងយកច្បាប់ ឬបទប្បញ្ញត្តិគតិយុត្តិណាមួយ ដែលវេទិកាមជ្ឈត្តកម្មត្រូវយកមកអនុវត្តចំពោះខ្លឹមសារនៃវិវាទ។ ក្នុងករណីដែលមិនមានការព្រមព្រៀងគ្នា វេទិកាមជ្ឈត្តកម្មត្រូវកំណត់យកច្បាប់ ឬបទប្បញ្ញត្តិគតិយុត្តិណាមួយ ដែលវេទិកាមជ្ឈត្តកម្មយល់ថាសមស្របមកអនុវត្ត។

### *៣២.២.សមធម៌ និងការសម្រុះសម្រួល*

វេទិកាមជ្ឈត្តកម្មត្រូវធ្វើមជ្ឈត្តវិនិច្ឆ័យតាមសមធម៌ ឬតាមការសម្រុះសម្រួល តែក្នុងករណី និងក្នុងកម្រិត ដែលគូភាគីវិវាទបានអនុញ្ញាតយ៉ាងច្បាស់លាស់ឱ្យវេទិកាមជ្ឈត្តកម្មធ្វើដូច្នោះតែប៉ុណ្ណោះ។

*៣២.៣.បញ្ញត្តិក្នុងកិច្ចសន្យា និងទម្លាប់ពាណិជ្ជកម្ម*

នៅគ្រប់ករណីទាំងអស់ វេទិកាមជ្ឈត្តកម្មត្រូវយកមកពិចារណានូវបញ្ញត្តិនានា ដែលមានចែងក្នុងកិច្ចសន្យា ប្រសិនបើមាន និងរួមទាំងទម្លាប់ពាណិជ្ជកម្មនានា ដែលពាក់ព័ន្ធ។

## ប្រការ ៣៣. ភាសា

*៣៣.១.ភាសានៃដំណើរការមជ្ឈត្តការ*

គូភាគីវិវាទមានសេរីភាពក្នុងការព្រមព្រៀងយកភាសាណាមួយ ឬច្រើនមកប្រើក្នុងដំណើរការមជ្ឈត្តការ។ ក្នុងករណីដែលគ្មានការព្រមព្រៀងគ្នា វេទិកាមជ្ឈត្តកម្មអាចសម្រេចយកភាសាណាមួយជាភាសាសម្រាប់ដំណើរការមជ្ឈត្តការ ដោយគិតពិចារណាលើកាលៈទេសៈនានាដែលពាក់ព័ន្ធទាំងអស់ រួមបញ្ចូលទាំងភាសានៃកិច្ចសន្យាផងដែរ។

*៣៣.២.ការបកប្រែ*

វេទិកាមជ្ឈត្តកម្មអាចបង្គាប់ឱ្យភាគីវិវាទណាមួយធ្វើការបកប្រែ ការទាក់ទងជាលាយលក្ខណ៍អក្សរ ឬដោយផ្ទាល់មាត់ណាមួយ ទៅជាភាសាណាមួយ និងក្នុងទម្រង់ណាមួយដែលវេទិកាមជ្ឈត្តកម្មយល់ថាសមស្រប។

*៣៣.៣.ភាសានៃមជ្ឈត្តវិនិច្ឆ័យ ឬសេចក្តីបង្គាប់*

ប្រសិនបើភាសានៃដំណើរការមជ្ឈត្តការ ទោះតាមរយៈការជ្រើសរើសរបស់គូភាគីវិវាទ ឬតាមការកំណត់របស់វេទិកាមជ្ឈត្តកម្ម ស្របតាមប្រការ ៣៣ *(ភាសា)* គឺជាភាសាផ្សេងក្រៅពីភាសាខ្មែរ ឬភាសាអង់គ្លេសក៏ដោយ ក៏ភាសានៃមជ្ឈត្តវិនិច្ឆ័យ ឬសេចក្តីបង្គាប់ ដែលចេញដោយវេទិកាមជ្ឈត្តកម្មត្រូវតែជាភាសាខ្មែរ ឬភាសាអង់គ្លេស បន្ទាប់ពីបានពិភាក្សាជាមួយគូភាគីវិវាទរួចហើយ។

## ប្រការ ៣៤. ទឡ្ហីករណ៍ចំពោះយុត្តាធិការរបស់វេទិកាមជ្ឈត្តកម្ម

*៣៤.១.ការកំណត់អំពីយុត្តាធិការរបស់ ម.ជ.ម. មុនពេលវេទិកាមជ្ឈត្តកម្មត្រូវបានបង្កើត*

មុនពេលដែលវេទិកាមជ្ឈត្តកម្មត្រូវបានបង្កើត ប្រសិនបើភាគីវិវាទបដិសេធចំពោះអត្ថិភាព ឬសុពលភាពនៃកិច្ចសន្យាមជ្ឈត្តកម្ម ឬចំពោះយុត្តាធិការរបស់ ម.ជ.ម. ក្នុងការចាត់ចែងធ្វើមជ្ឈត្តការលើសំណុំរឿង គណៈកម្មាធិការតែងតាំង និងនីតិវិធី ក្នុងអំឡុងពេល ១៥ (ដប់ប្រាំ) ថ្ងៃប្រតិទិន បន្ទាប់ពីបានទទួលសេចក្តីជូនដំណឹងអំពីការបដិសេធនោះ ត្រូវសម្រេចថាតើដោយផ្អែកលើសេចក្តីបញ្ជាក់ដំបូង មជ្ឈត្តការត្រូវមានដំណើរការទៅមុខដែរឬទេ។ មជ្ឈត្តការត្រូវតែបញ្ចប់ ប្រសិនបើគណៈកម្មាធិការតែងតាំង និងនីតិវិធី សម្រេចថា សេចក្តីបញ្ជាក់ដំបូងនោះមិនបាន

បំពេញលក្ខខណ្ឌដើម្បីឱ្យមជ្ឈត្តការអាចដំណើរការបាន។ រាល់សេចក្ដីសម្រេចរបស់គណៈកម្មាធិការតែងតាំង និងនីតិវិធី ដែលសម្រេចថាដំណើរការនីតិវិធីមជ្ឈត្តការត្រូវបន្ត មិនត្រូវប៉ះពាល់ដល់អំណាចរបស់វេទិកាមជ្ឈត្តកម្មក្នុងការចេញសេចក្ដីសម្រេចអំពីយុត្តាធិការរបស់ខ្លួនឡើយ។

### *៣៤.២.ការសម្រេចរបស់វេទិកាមជ្ឈត្តកម្មអំពីយុត្តាធិការរបស់ខ្លួន*

វេទិកាមជ្ឈត្តកម្មមានអំណាចក្នុងការសម្រេចយុត្តាធិការរបស់ខ្លួនរួមទាំងការជំទាស់នានាដែលពាក់ព័ន្ធនឹងអត្ថិភាព សុពលភាព ឬវិសាលភាពអនុវត្តនៃកិច្ចសន្យាមជ្ឈត្តកម្ម។

ប្រសិនបើវេទិកាមជ្ឈត្តកម្មសម្រេចថាខ្លួនមានយុត្តាធិការ ក្នុងអំឡុងពេល ៣០ (សាមសិប) ថ្ងៃប្រតិទិន បន្ទាប់ពីទទួលបានសេចក្ដីជូនដំណឹងអំពីការសម្រេចនោះ ភាគីវិវាទអាចស្នើឱ្យតុលាការមានសមត្ថកិច្ចធ្វើការសម្រេច ដែលការសម្រេចរបស់តុលាការអំពីបញ្ហានេះ គឺជាការសម្រេចដែលបិទផ្លូវតវ៉ា។ នៅពេលសំណើសុំការសម្រេចរបស់តុលាការ ចំពោះយុត្តាធិការរបស់វេទិកាមជ្ឈត្តកម្មនៅមិនទាន់ត្រូវបានសម្រេចនៅឡើយ វេទិកាមជ្ឈត្តកម្មអាចបន្តដំណើរការមជ្ឈត្តការ និងចេញមជ្ឈត្តវិនិច្ឆ័យបាន។

### *៣៤.៣.កិច្ចសន្យា និងខចែងស្ដីពីមជ្ឈត្តកម្ម*

សម្រាប់គោលបំណងនៃប្រការ ៣៤ *(ទទ្បីករណ៍ចំពោះយុត្តាធិការរបស់វេទិកាមជ្ឈត្តកម្ម)* ប្រសិនបើខចែងស្ដីពីមជ្ឈត្តកម្មជាផ្នែកមួយនៃកិច្ចសន្យា ខចែងស្ដីពីមជ្ឈត្តកម្មនោះ ត្រូវចាត់ទុកជាការព្រមព្រៀងដោយឡែក ដែលមិនទាក់ទងនឹងលក្ខខណ្ឌ និងខចែងផ្សេងទៀតនៃកិច្ចសន្យាឡើយ។ ការសម្រេចរបស់វេទិកាមជ្ឈត្តកម្មដែលចាត់ទុកកិច្ចសន្យាថាមោឃៈ និងអសារឥតការ មិននាំឱ្យខចែងស្ដីពីមជ្ឈត្តកម្មនោះបាត់សុពលភាពឡើយ។

### *៣៤.៤.ទទ្បីករណ៍បញ្ជាក់ថាវេទិកាមជ្ឈត្តកម្មពុំមានយុត្តាធិការ*

ទទ្បីករណ៍ដែលបញ្ជាក់ថា វេទិកាមជ្ឈត្តកម្មពុំមានយុត្តាធិការ ត្រូវលើកឡើងមុនពេលដាក់សេចក្ដីថ្លែងដោះសា សម្រាប់បញ្ហាយុត្តាធិការទាក់ទងនឹងការទាមទារ ឬមុនពេលដាក់សេចក្ដីថ្លែងដោះសាចំពោះបណ្ដឹងតប សម្រាប់បញ្ហាយុត្តាធិការទាក់ទងនឹងបណ្ដឹងតប។ វេទិកាមជ្ឈត្តកម្ម អាចទទួលយកទទ្បីករណ៍ចំពោះយុត្តាធិការរបស់វេទិកាមជ្ឈត្តកម្ម ដែលត្រូវបានលើកឡើងក្រោយពេលកំណត់ខាងលើបាន ប្រសិនបើវេទិកាមជ្ឈត្តកម្មយល់ថា ការយឺតយ៉ាវក្នុងការដាក់ទទ្បីករណ៍នោះមានមូលហេតុត្រឹមត្រូវ។

មិនត្រូវហាមឃាត់ភាគីវិវាទណាមួយមិនឱ្យលើកឡើងពីទទ្បីករណ៍ខាងលើ ដោយហេតុថាភាគីវិវាទនោះបានតែងតាំង ឬចូលរួមក្នុងការតែងតាំងមជ្ឈត្តករឡើយ។

### *៣៤.៥.ទឡ្ហីករណ៍បញ្ជាក់ថាវេទិកាមជ្ឈត្តកម្មធ្វើហួសក្របខណ្ឌសមត្ថកិច្ចរបស់ខ្លួន*

ទឡ្ហីករណ៍បញ្ជាក់ថា វេទិកាមជ្ឈត្តកម្មធ្វើហួសក្របខណ្ឌសមត្ថកិច្ចរបស់ខ្លួន ក្នុងពេលដំណើរការមជ្ឈត្តការត្រូវលើកឡើងភ្លាមៗ បន្ទាប់ពីកើតឡើងនូវបញ្ហាដែលត្រូវបានចោទថា ហួសក្របខណ្ឌសមត្ថកិច្ចរបស់វេទិកាមជ្ឈត្តកម្ម។ វេទិកាមជ្ឈត្តកម្មអាចទទួលយកទឡ្ហីករណ៍នោះក្រោយពេលកំណត់ខាងលើបាន ប្រសិនបើវេទិកាមជ្ឈត្តកម្មយល់ថាការយឺតយ៉ាវក្នុងការដាក់ទឡ្ហីករណ៍នោះមានមូលហេតុត្រឹមត្រូវ។

### *៣៤.៦.ការសម្រេចលើទឡ្ហីករណ៍ជាបញ្ហាបឋម ឬជាមជ្ឈត្តវិនិច្ឆ័យសម្រេចលើអង្គសេចក្តី*

វេទិកាមជ្ឈត្តកម្មអាចសម្រេចលើទឡ្ហីករណ៍ពាក់ព័ន្ធនឹងយុត្តាធិការរបស់ខ្លួន ដោយចាត់ទុកជាបញ្ហាបឋម ឬជាមជ្ឈត្តវិនិច្ឆ័យសម្រេចលើអង្គសេចក្តីរបស់ខ្លួន។

## ប្រការ ៣៥. បញ្ញត្តិទូទៅអំពីដំណើរការមជ្ឈត្តការ

### *៣៥.១.ដំណើរការមជ្ឈត្តការ សេចក្តីបង្គាប់ និងសេចក្តីណែនាំ*

បន្ទាប់ពីពិភាក្សាជាមួយគូភាគីវិវាទ ដោយផ្អែកលើភាពសាំញ៉ាំ និងតម្លៃនៃវិវាទ វេទិកាមជ្ឈត្តកម្មត្រូវអនុវត្តដំណើរការមជ្ឈត្តការក្នុងលក្ខណៈ ដែលវេទិកាមជ្ឈត្តកម្មយល់ថាសមស្រប ដើម្បីធានាភាពយុត្តិធម៌ ឆាប់រហ័ស ចំណាយអស់តិច និងផ្តល់ដំណោះស្រាយចុងក្រោយនៃវិវាទ។ នៅក្នុងគ្រប់ករណីទាំងអស់ វេទិកាមជ្ឈត្តកម្មត្រូវដំណើរការក្នុងលក្ខណៈ ដែលគូភាគីវិវាទត្រូវបានទទួលការយកចិត្តទុកដាក់ស្មើៗគ្នា និងភាគីវិវាទនីមួយៗត្រូវបានផ្តល់ឱកាសសមរម្យដើម្បីបង្ហាញរឿងរ៉ាវរបស់ខ្លួន។

វេទិកាមជ្ឈត្តកម្មអាចចេញសេចក្តីបង្គាប់ ឬសេចក្តីណែនាំ ដែលវេទិកាមជ្ឈត្តកម្មយល់ថាសមស្រប ដោយសេចក្តីបង្គាប់ និងសេចក្តីណែនាំនោះមិនត្រូវផ្ទុយនឹងវិធាននេះ ឬច្បាប់ដែលគ្រប់គ្រងមជ្ឈត្តការឡើយ។ ស្របតាមប្រការ ៤.១ *(ការទាក់ទងជាលាយលក្ខណ៍អក្សរ)* រាល់សេចក្តីបង្គាប់ និងសេចក្តីណែនាំទាំងអស់ត្រូវធ្វើជាលាយលក្ខណ៍អក្សរ។

លើកលែងតែវេទិកាមជ្ឈត្តកម្មបានកំណត់ផ្សេងពីនេះ គូភាគីវិវាទយល់ព្រមក្នុងការគោរពតាមសេចក្តីបង្គាប់ ឬសេចក្តីណែនាំដោយមិនបង្អង់។

### *៣៥.២.ការប្រជុំត្រៀម និងការប្រជុំបន្ថែមនានា*

ភ្លាមៗតាមដែលធ្វើទៅបាន វេទិកាមជ្ឈត្តកម្មអាចរៀបចំការប្រជុំត្រៀមជាមួយគូភាគីវិវាទដោយផ្ទាល់ ឬដោយមធ្យោបាយផ្សេងៗទៀត ដើម្បីរៀបចំ និងកំណត់កាលវិភាគនៃដំណើរការមជ្ឈត្តការបន្ទាប់ ឬ/និង ដើម្បីពិភាក្សាអំពីនីតិវិធីដែលមានភាពសមស្រប និងចំណាយអស់តិចបំផុតសម្រាប់សំណុំរឿង។

បន្ថែមលើការប្រជុំត្រៀម វេទិកាមជ្ឈត្តកម្មអាចរៀបចំឱ្យមានការប្រជុំបន្ថែម ឧទាហរណ៍ ដូចជាដើម្បីពិនិត្យទីតាំង វត្ថុ ឬឯកសារនានា ដូចមានចែងក្នុងប្រការ ៤០.២ *(ការសាកសួរ សេចក្តីបង្គាប់ និងការពិនិត្យកន្លែង)* ឬពិនិត្យលើភាពរីកចម្រើននៃដំណើរការមជ្ឈត្តការ។

ប្រការ ៣៩ *(សវនាការ និងការប្រជុំ)* ត្រូវអនុវត្តចំពោះការប្រជុំត្រៀម និងការប្រជុំបន្ថែមនានាដូចមានចែងក្នុងប្រការនេះ។

### *៣៥.៣.ការស្វែងរកដំណោះស្រាយដោយស្រុះស្រួលគ្នា*

មុនពេល ឬក្នុងអំឡុងពេលប្រជុំត្រៀម វេទិកាមជ្ឈត្តកម្មត្រូវពិភាក្សាជាមួយគូភាគីវិវាទ ដើម្បីស្វែងរកលទ្ធភាពក្នុងការដោះស្រាយវិវាទដោយស្រុះស្រួលគ្នា និងត្រូវជួយគូភាគីវិវាទក្នុងលក្ខណៈណាមួយដែលវេទិកាមជ្ឈត្តកម្មយល់ថាសមស្រប។

### *៣៥.៤.ការបំបែកដំណើរការមជ្ឈត្តការដាច់ៗពីគ្នា*

បន្ទាប់ពីបានពិភាក្សាជាមួយគូភាគីវិវាទ វេទិកាមជ្ឈត្តកម្ម តាមរយៈឆន្ទានុសិទ្ធិរបស់ខ្លួន អាចបំបែកដំណើរការមជ្ឈត្តការដាច់ៗពីគ្នា និងកំណត់ឱ្យគូភាគីវិវាទផ្តោតការបង្ហាញនានារបស់ពួកគេលើបញ្ហានានា ដែលសេចក្តីសម្រេចលើបញ្ហាទាំងនោះអាចបំបែកសំណុំរឿងទាំងមូល ឬជាផ្នែក។

### *៣៥.៥.ការចូលរួមពីតតិយជន*

វេទិកាមជ្ឈត្តកម្មមានអំណាចក្នុងការអនុញ្ញាតឱ្យតតិយជនចូលរួមជាភាគីវិវាទក្នុងដំណើរការមជ្ឈត្តការ ប្រសិនបើគូភាគីវិវាទ រួមទាំងតតិយជនបានព្រមព្រៀងចំពោះការចូលរួមនោះជាលាយលក្ខណ៍អក្សរ។ ក្នុងករណីនេះ វេទិកាមជ្ឈត្តកម្មអាចចេញជាមជ្ឈត្តវិនិច្ឆ័យស្ថាពរតែមួយ ឬមជ្ឈត្តវិនិច្ឆ័យដោយឡែក សម្រាប់ដោះស្រាយរាល់វិវាទរបស់គូភាគីវិវាទ។

## ប្រការ ៣៦. ការរួមបញ្ចូលមជ្ឈត្តការ

### *៣៦.១.លក្ខខណ្ឌសម្រាប់ការរួមបញ្ចូល*

តាមសំណើរបស់ភាគីវិវាទណាមួយ និងដោយមានការយល់ព្រមពីគូភាគីវិវាទ អគ្គលេខាធិការដ្ឋានអាចរួមបញ្ចូលមជ្ឈត្តការ ២ (ពីរ) ឬច្រើន ដែលត្រូវបានផ្តួចផ្តើមឡើងក្រោមវិធាននេះឱ្យទៅជាមជ្ឈត្តការតែមួយបាន។ អគ្គលេខាធិការ-ដ្ឋានអាចកែប្រែដោយដំឡើង ឬបន្ថយកម្រៃសេវារដ្ឋបាល និងកម្រៃសេវាវេទិកាមជ្ឈត្តកម្ម ផ្អែកតាមកាលៈទេសៈ ដំណាក់កាល និងផលប៉ះពាល់នៃការរួមបញ្ចូលនោះលើសេវាកម្មនានារបស់ ម.ជ.ម. និងរបស់វេទិកាមជ្ឈត្តកម្ម។

### *៣៦.២.កាលៈទេសៈពាក់ព័ន្ធ*

ដើម្បីសម្រេចលើការរួមបញ្ចូលមជ្ឈត្តការ អគ្គលេខាធិការដ្ឋានអាចពិចារណាកាលៈទេសៈផ្សេងៗជាច្រើន ដែលអគ្គលេខាធិការដ្ឋានយល់ថាពាក់ព័ន្ធ រួមបញ្ចូលទាំងកាលៈទេសៈដូចខាងក្រោម៖

(ក) តើការទាមទារទាំងអស់នៅក្នុងមជ្ឈត្តការនានាត្រូវបានធ្វើឡើងក្រោមកិច្ចសន្យាមជ្ឈត្តកម្មតែមួយដែរឬទេ

(ខ) ប្រសិនបើការទាមទារត្រូវបានធ្វើឡើងក្រោមកិច្ចសន្យាមជ្ឈត្តកម្មផ្សេងគ្នា ហើយមជ្ឈត្តការធ្វើឡើងរវាងភាគីវិវាទដូចគ្នា តើវិវាទនានានៅក្នុងមជ្ឈត្តការទាំងនោះ កើតឡើងពាក់ព័ន្ធនឹងទំនាក់ទំនងគតិយុត្តិដូចគ្នាតែមួយ និង កិច្ចសន្យាមជ្ឈត្តកម្មទាំងនោះត្រូវបានចាត់ទុកថាមិនផ្ទុយគ្នាដែរឬទេ និង

(គ) តើមជ្ឈត្តករត្រូវបានតែងតាំងសម្រាប់មជ្ឈត្តការលើសពីមួយដែរឬទេ និង ប្រសិនបើបានតែងតាំង តើមជ្ឈត្តករដែលត្រូវបានតែងតាំងនោះជាមជ្ឈត្តករតែមួយ ឬផ្សេងគ្នា។

### *៣៦.៣.ការរួមបញ្ចូលមជ្ឈត្តការនានាទៅក្នុងមជ្ឈត្តការដំបូងដែលបានទទួល និងចាប់ផ្ដើម*

លើកលែងតែគូភាគីវិវាទបានព្រមព្រៀងផ្សេងពីនេះ នៅពេលរួមបញ្ចូលគ្នានូវមជ្ឈត្តការនានា មជ្ឈត្តការទាំងនោះត្រូវរួមបញ្ចូលទៅក្នុងមជ្ឈត្តការមួយដែលអគ្គលេខាធិការដ្ឋានបានទទួលដំបូងគេបង្អស់នូវសេចក្ដីជូនដំណឹងអំពីមជ្ឈត្តការនោះ ប្រសិនបើមិនទាន់មានមជ្ឈត្តការណាមួយត្រូវបានចាប់ផ្ដើមដំណើរការនៅឡើយទេនោះ ឬទៅក្នុងមជ្ឈត្តការមួយដែលបានដំណើរការមុនគេ ប្រសិនបើមជ្ឈត្តការនៃសំណុំរឿងត្រូវបានចាប់ផ្ដើមហើយនោះ។

## ប្រការ ៣៧. ការដាក់សេចក្ដីថ្លែងដោយគូភាគីវិវាទ

### *៣៧.១.ការដាក់សេចក្ដីថ្លែង*

លើកលែងតែវេទិកាមជ្ឈត្តកម្មបានកំណត់ផ្សេងពីនេះ ក្រោយពីបានពិភាក្សាជាមួយគូភាគីវិវាទ ការដាក់សេចក្ដីថ្លែងត្រូវធ្វើឡើងស្របតាមប្រការ ៣៧ *(ការដាក់សេចក្ដីថ្លែងដោយគូភាគីវិវាទ)*។

### *៣៧.២.សេចក្ដីថ្លែងទាមទារ*

លើកលែងតែសេចក្ដីថ្លែងទាមទារត្រូវបានដាក់រួចហើយស្របតាមប្រការ ៧.៤ *(ការភ្ជាប់សេចក្ដីថ្លែងទាមទារ)* ភាគីប្ដឹងទាមទារ ក្នុងអំឡុងពេលដែលនឹងត្រូវកំណត់ដោយវេទិកាមជ្ឈត្តកម្ម ត្រូវដាក់សេចក្ដីថ្លែងទាមទារដែលមានបញ្ជាក់សេចក្ដីលម្អិតដូចខាងក្រោម៖

(ក) អង្គហេតុដែលគាំទ្រការទាមទារនោះ

(ខ) មូលដ្ឋានច្បាប់ ឬទឡ្ហីករណ៍តាមផ្លូវច្បាប់ដែលគាំទ្រការទាមទារនោះ និង

(គ) សំណងការខូចខាត ឬការសង្គ្រោះដែលទាមទារ ព្រមជាមួយចំនួនទឹកប្រាក់នៃការទាមទារដែលអាចកំណត់បានទាំងអស់។

### ៣៧.៣.សេចក្តីថ្លែងដោះសា និងបណ្តឹងតប

លើកលែងតែសេចក្តីថ្លែងដោះសាត្រូវបានប្រគល់រួចហើយស្របតាមប្រការ ៨.៤ *(ការភ្ជាប់សេចក្តីថ្លែងដោះសា និងទឡ្ហីករណ៍ចំពោះយុត្តាធិការរបស់វេទិកាមជ្ឈត្តកម្ម)* ភាគីឆ្លើយតប ក្នុងអំឡុងពេលដែលនឹងត្រូវកំណត់ដោយវេទិកាមជ្ឈត្តកម្ម ត្រូវដាក់សេចក្តីថ្លែងដោះសាដែលមានបញ្ជាក់សេចក្តីលម្អិតដូចខាងក្រោម៖

(ក) អង្គហេតុ និងអំណះអំណាងតាមផ្លូវច្បាប់ក្នុងសេចក្តីថ្លែងទាមទារដែលភាគីឆ្លើយតបទទួលស្គាល់

(ខ) អង្គហេតុ និងអំណះអំណាងតាមផ្លូវច្បាប់ក្នុងសេចក្តីថ្លែងទាមទារដែលភាគីឆ្លើយតបបដិសេធ និងមូលហេតុនៃការបដិសេធនោះ និង

(គ) អង្គហេតុ និងអំណះអំណាងតាមផ្លូវច្បាប់ផ្សេងទៀត ដែលភាគីឆ្លើយតបផ្អែកជាមូលដ្ឋាន។

សេចក្តីថ្លែងដោះសាអាចមានបញ្ចូលផងដែរនូវបណ្តឹងតប ឬការដោះសាតាមការកាត់កងល្មើកណាបណ្តឹងតប ឬការដោះសាតាមការកាត់កងនោះស្ថិតក្នុងយុត្តាធិការរបស់វេទិកាមជ្ឈត្តកម្ម ដែលត្រូវបំពេញតាមលក្ខខណ្ឌតម្រូវនានានៃប្រការ ៣៧.២ *(សេចក្តីថ្លែងទាមទារ)*។

### ៣៧.៤.សេចក្តីថ្លែងដោះសាចំពោះបណ្តឹងតប

ប្រសិនបើបណ្តឹងតបត្រូវបានធ្វើឡើង ភាគីប្តឹងទាមទារ ក្នុងកំឡុងពេល ៣០ (សាមសិប) ថ្ងៃប្រតិទិន បន្ទាប់ពីបានទទួលសេចក្តីថ្លែងដោះសា ត្រូវបញ្ជូនសេចក្តីថ្លែងដោះសាចំពោះបណ្តឹងតបនោះ ដោយសេចក្តីថ្លែងដោះសានោះត្រូវបំពេញតាមលក្ខខណ្ឌតម្រូវនានានៃប្រការ ៣៧.៣ *(សេចក្តីថ្លែងដោះសា និងបណ្តឹងតប)*។

### ៣៧.៥.ការដាក់សេចក្តីថ្លែងបន្ថែម

វេទិកាមជ្ឈត្តកម្មត្រូវសម្រេចថា តើសេចក្តីថ្លែងបន្ថែមណាមួយ ប្រសិនបើមានដែលត្រូវតម្រូវពីគូភាគីវិវាទ ឬដែលអាចបង្ហាញដោយគូភាគីវិវាទ។ វេទិកាមជ្ឈត្តកម្មត្រូវកំណត់រយៈពេលសម្រាប់ការដាក់សេចក្តីថ្លែងបន្ថែមទាំងនោះ។

### *៣៧.៦.ឯកសារយោង*

ការដាក់សេចក្តីថ្លែងដូចមានចែងក្នុងប្រការ ៣៧ *(ការដាក់សេចក្តីថ្លែងដោយគូភាគីវិវាទ)* ត្រូវអមដោយសំណៅចម្លងនៃឯកសារយោងទាំងអស់ដែលភាគីវិវាទណាមួយមិនទាន់បានដាក់ពីមុន។

### *៣៧.៧.ការបំពានកាតព្វកិច្ច និងការមិនគោរពតាមវិធាន*

ប្រសិនបើភាគីប្តឹងទាមទារខកខានក្នុងការដាក់សេចក្តីថ្លែងទាមទារដោយមិនបានបង្ហាញពីមូលហេតុគ្រប់គ្រាន់នៅក្នុងអំឡុងពេលកំណត់ និងប្រសិនបើសមស្រប វេទិកាមជ្ឈត្តកម្មត្រូវចេញសេចក្តីបង្គាប់ឱ្យបញ្ឈប់ដំណើរការមជ្ឈត្តការ បន្ទាប់ពីសម្រេចលើបញ្ហាផ្សេងទៀតដែលនៅសេសសល់ និងដែលត្រូវដោះស្រាយ។

នៅគ្រប់ករណីទាំងអស់ ដោយមិនបានបង្ហាញពីមូលហេតុគ្រប់គ្រាន់ ប្រសិនបើភាគីវិវាទណាមួយខកខាន ឬបដិសេធក្នុងការដាក់សេចក្តីថ្លែងនានាដែលតម្រូវក្នុងការចូលរួមក្នុងវេទិកាមជ្ឈត្តកម្ម ឬក្នុងការគោរពតាមវិធាននេះ ឬសេចក្តីបង្គាប់ សេចក្តីណែនាំ ឬមជ្ឈត្តវិនិច្ឆ័យរបស់វេទិកាមជ្ឈត្តកម្ម វេទិកាមជ្ឈត្តកម្ម តាមការសមស្រប អាចដំណើរការមជ្ឈត្តកម្ម និងចេញមជ្ឈត្តវិនិច្ឆ័យដោយផ្អែកតាមសេចក្តីថ្លែង និងភស្តុតាងដែលបានដាក់មកវេទិកាមជ្ឈត្តកម្ម។

## ប្រការ ៣៨. ការដកពាក្យបណ្តឹង ការកែប្រែ និងការដោះសា

### *៣៨.១.ការដកពាក្យបណ្តឹង*

បន្ទាប់ពីមានសេចក្តីជូនដំណឹងទៅវេទិកាមជ្ឈត្តកម្ម ភាគីប្តឹងទាមទារមានសិទ្ធិក្នុងការដកពាក្យបណ្តឹងរបស់ខ្លួន លើកលែងតែភាគីឆ្លើយតបជំទាស់ និងវេទិកាមជ្ឈត្តកម្មទទួលស្គាល់ផលប្រយោជន៍ស្របច្បាប់របស់ភាគីឆ្លើយតបក្នុងការទទួលបានសេចក្តីសម្រេចស្ថាពរលើវិវាទ។ ក្នុងករណីដែលមានការដកពាក្យបណ្តឹង វេទិកាមជ្ឈត្តកម្មត្រូវចេញសេចក្តីបង្គាប់បញ្ឈប់ដំណើរការមជ្ឈត្តការ។

### *៣៨.២.ការកែប្រែពាក្យបណ្តឹង និងការកែប្រែការដោះសា*

ក្នុងដំណើរការមជ្ឈត្តការ ភាគីវិវាទណាមួយអាចកែប្រែ ឬបន្ថែមការទាមទារ ការដោះសាបណ្តឹងតប ឬការដោះសាតាមការកាត់កង លើកលែងតែវេទិកាមជ្ឈត្តកម្មយល់ថាការកែប្រែ ឬការបន្ថែមនោះមិនសមស្របដោយសារការកែប្រែ ឬការបន្ថែមនោះនឹងពន្យារដំណើរការមជ្ឈត្តការ និងបង្កឱ្យមានសេចក្តីលំអៀងដល់ភាគីវិវាទម្ខាងទៀត ឬកាលៈទេសៈផ្សេងទៀត។ ទោះបីជាយ៉ាងណាក៏ដោយភាគីវិវាទមួយមិនអាចកែប្រែ ឬបន្ថែមលើពាក្យបណ្តឹង ឬការដោះសាបានឡើយ ប្រសិនបើការកែប្រែ ឬការបន្ថែមលើពាក្យបណ្តឹង ឬការដោះសានោះស្ថិតនៅក្រៅយុត្តាធិការរបស់វេទិកាមជ្ឈត្តកម្ម។

## ជំពូកទី ៦

# ការសម្រេច និងមជ្ឈត្តវិនិច្ឆ័យ

### ប្រការ ៤៧. ការសម្រេច

*៤៧.១.ការសម្រេចដោយសម្លេងភាគច្រើនដោយប្រៀប*

ក្នុងករណីវេទិកាមជ្ឈត្តកម្មនៃមជ្ឈត្តករច្រើនរូប មជ្ឈត្តវិនិច្ឆ័យ ឬសេចក្ដីសម្រេចផ្សេងៗ ត្រូវធ្វើឡើងដោយមតិភាគច្រើនដោយប្រៀបនៃមជ្ឈត្តករជាសមាជិកនៃវេទិកាមជ្ឈត្តកម្មទាំងអស់។

*៤៧.២.សេចក្ដីសម្រេចលើបញ្ហានីតិវិធី*

ដោយមានការយល់ព្រមជាមុនពីវេទិកាមជ្ឈត្តកម្ម ប្រធានវេទិកាមជ្ឈត្តកម្មអាចសម្រេចលើបញ្ហានីតិវិធីតែម្នាក់ឯងបាន។

### ប្រការ ៤៨. មជ្ឈត្តវិនិច្ឆ័យស្ថាពរ មជ្ឈត្តវិនិច្ឆ័យបណ្ដោះអាសន្ន និងមជ្ឈត្តវិនិច្ឆ័យដោយផ្នែក

បន្ថែមលើការចេញមជ្ឈត្តវិនិច្ឆ័យស្ថាពរដែលដោះស្រាយចំណុចវិវាទទាំងអស់ (ដែលនៅសេសសល់) វេទិកាមជ្ឈត្តកម្មមានសិទ្ធិក្នុងការចេញមជ្ឈត្តវិនិច្ឆ័យបណ្ដោះអាសន្ន ឬមជ្ឈត្តវិនិច្ឆ័យដោយផ្នែកលើចំណុចវិវាទផ្សេងក្នុងពេលវេលាផ្សេងៗគ្នា។

## ប្រការ ៤៩. ទម្រង់នៃមជ្ឈត្តវិនិច្ឆ័យ

### *៤៩.១.មជ្ឈត្តវិនិច្ឆ័យជាលាយលក្ខណ៍អក្សរ និងមានសំអាងហេតុ*

មជ្ឈត្តវិនិច្ឆ័យត្រូវធ្វើជាលាយលក្ខណ៍អក្សរ។ លើកលែងតែគូភាគីវិវាទបានព្រមព្រៀងផ្សេងពីនោះ និងស្របតាមប្រការ ៤៥ *(ការដោះស្រាយវិវាទដោយស្ម័គ្រចិត្ត)* មជ្ឈត្តវិនិច្ឆ័យត្រូវមានសំអាងហេតុដែលជាមូលដ្ឋាននៃការសម្រេច។

### *៤៩.២.ទីកន្លែង និងកាលបរិច្ឆេទ*

មជ្ឈត្តវិនិច្ឆ័យត្រូវមានចុះកាលបរិច្ឆេទ និងទីកន្លែងដែលមជ្ឈត្តវិនិច្ឆ័យនោះត្រូវបានចេញ។

### *៤៩.៣.ហត្ថលេខា*

មជ្ឈត្តវិនិច្ឆ័យត្រូវចុះហត្ថលេខាដោយមជ្ឈត្តករទាំងអស់។ ចំពោះវេទិកាមជ្ឈត្តកម្មនៃមជ្ឈត្តករច្រើនរូប ហត្ថលេខារបស់សមាជិកភាគច្រើននៃវេទិកាមជ្ឈត្តកម្មត្រូវចាត់ទុកថាគ្រប់គ្រាន់ ល្គឹកណាមានការបញ្ជាក់ពីមូលហេតុដែលមជ្ឈត្តករដទៃទៀតមិនបានចុះហត្ថលេខា។

### *៤៩.៤.ការសហការក្នុងការរៀបចំធ្វើមជ្ឈត្តវិនិច្ឆ័យ*

ប្រសិនបើបន្ទាប់ពីបានទទួលឱកាសគ្រប់គ្រាន់ក្នុងការសហការហើយ មជ្ឈត្តករណាម្នាក់ខកខានមិនបានសហការក្នុងការរៀបចំធ្វើមជ្ឈត្តវិនិច្ឆ័យ មជ្ឈត្តករផ្សេងៗទៀតត្រូវរៀបចំធ្វើមជ្ឈត្តវិនិច្ឆ័យដោយគ្មានវត្តមានមជ្ឈត្តកររូបនោះ។

### *៤៩.៥.ការឯកភាពលើទម្រង់របស់មជ្ឈត្តវិនិច្ឆ័យ*

វេទិកាមជ្ឈត្តកម្មមិនត្រូវចេញមជ្ឈត្តវិនិច្ឆ័យណាមួយឡើយ ប្រសិនបើទម្រង់របស់មជ្ឈត្តវិនិច្ឆ័យនោះមិនទាន់ត្រូវបានពិនិត្យពិច័យ និងឯកភាពដោយអគ្គលេខាធិការដ្ឋាន។

## ប្រការ ៥០. ការពិនិត្យពិច័យលើទម្រង់របស់មជ្ឈត្តវិនិច្ឆ័យ

### *៥០.១.ការបញ្ជូនសេចក្តីព្រាងមជ្ឈត្តវិនិច្ឆ័យសម្រាប់ការពិនិត្យពិច័យលើទម្រង់*

(ក) នៅមុនពេលចេញមជ្ឈត្តវិនិច្ឆ័យ វេទិកាមជ្ឈត្តកម្មត្រូវបញ្ជូនសេចក្តីព្រាងមជ្ឈត្តវិនិច្ឆ័យទៅអគ្គលេខាធិការដ្ឋាន ដើម្បីឱ្យអគ្គលេខាធិការដ្ឋានពិនិត្យពិច័យលើទម្រង់របស់មជ្ឈត្តវិនិច្ឆ័យ។ លើកលែងតែអគ្គលេខាធិការដ្ឋានពន្យារវេលាកំណត់ស្របតាមសំណើរបស់វេទិកាមជ្ឈត្តកម្ម ឬគូភាគីវិវាទបានព្រមព្រៀងផ្សេងពីនេះ វេទិកាមជ្ឈត្តកម្មត្រូវបញ្ជូនសេចក្តីព្រាងមជ្ឈត្ត-វិនិច្ឆ័យទៅអគ្គលេខាធិការដ្ឋានក្នុងអំឡុងពេល ៤៥ (សែសិបប្រាំ) ថ្ងៃប្រតិទិន ចាប់ពីកាលបរិច្ឆេទដែលវេទិកាមជ្ឈត្តកម្មបានប្រកាសបិទដំណើរការមជ្ឈត្តកម្ម។

ក្នុងអំឡុងពេល ៣០ (សាមសិប) ថ្ងៃប្រតិទិន ចាប់ពីបានទទួលសេចក្តីព្រាងមជ្ឈត្តវិនិច្ឆ័យ អគ្គលេខាធិការដ្ឋានអាចស្នើកែប្រែលើទម្រង់របស់មជ្ឈត្តវិនិច្ឆ័យ និងដោយមិនប៉ះពាល់ដល់សេរីភាពក្នុងការសម្រេចរបស់វេទិកាមជ្ឈត្តកម្ម អាចស្នើឱ្យវេទិកាមជ្ឈត្តកម្មយកចិត្តទុកដាក់លើចំណុចសារធាតុនានានៃមជ្ឈត្តវិនិច្ឆ័យ។

(ខ) ប្រការ ៥០.១(ក) មិនអនុវត្តចំពោះមជ្ឈត្តវិនិច្ឆ័យដែលចេញពាក់ព័ន្ធនឹងវិធានការបណ្តោះអាសន្នដូចមានចែងក្នុងប្រការ ៤៣ *(វិធានការបណ្តោះអាសន្ន)* ឬមជ្ឈត្តវិនិច្ឆ័យតាមការព្រមព្រៀងដូចមានចែងក្នុងប្រការ ៤៥ *(ការដោះស្រាយវិវាទដោយស្ម័គ្រចិត្ត)* ឡើយ។

### *៥០.២. ការបញ្ជូនសេចក្តីព្រាងមជ្ឈត្តវិនិច្ឆ័យសម្រាប់ការកែតម្រូវ ការបំភ្លឺលម្អិត ការបកស្រាយ ឬមជ្ឈត្តវិនិច្ឆ័យបន្ថែមសម្រាប់ការពិនិត្យពិច័យលើទម្រង់*

មុនពេលចេញមជ្ឈត្តវិនិច្ឆ័យសម្រាប់ការកែតម្រូវ ការបំភ្លឺលម្អិត ការបកស្រាយ ឬមជ្ឈត្តវិនិច្ឆ័យបន្ថែមដូចមានចែងក្នុង ប្រការ ៥៣ *(ការកែតម្រូវ ការបំភ្លឺលម្អិត និងការបកស្រាយមជ្ឈត្តវិនិច្ឆ័យ និងមជ្ឈត្តវិនិច្ឆ័យបន្ថែម)* វេទិកាមជ្ឈត្តកម្មត្រូវបញ្ជូនសេចក្តីព្រាងមជ្ឈត្តវិនិច្ឆ័យនោះទៅអគ្គលេខាធិការដ្ឋានសម្រាប់ការពិនិត្យពិច័យលើទម្រង់។

ក្នុងអំឡុងពេល ១៥ (ដប់ប្រាំ) ថ្ងៃប្រតិទិន នៃការទទួលបានសេចក្តីព្រាងមជ្ឈត្តវិនិច្ឆ័យសម្រាប់ការកែតម្រូវ ការបំភ្លឺលម្អិត ការបកស្រាយ ឬសេចក្តីព្រាងមជ្ឈត្តវិនិច្ឆ័យបន្ថែម អគ្គលេខាធិការដ្ឋានអាចស្នើកែប្រែលើទម្រង់របស់មជ្ឈត្តវិនិច្ឆ័យ និងដោយមិនប៉ះពាល់ដល់សេរីភាពក្នុងការសម្រេចរបស់វេទិកាមជ្ឈត្តកម្ម អាចស្នើឱ្យវេទិកាមជ្ឈត្តកម្មយកចិត្តទុកដាក់លើចំណុចសារធាតុនានានៃមជ្ឈត្តវិនិច្ឆ័យ។

## ប្រការ ៥១. ការចេញមជ្ឈត្តវិនិច្ឆ័យ

នៅពេលវេទិកាមជ្ឈត្តកម្មបានចេញមជ្ឈត្តវិនិច្ឆ័យស្របតាមប្រការ ៤៩ *(ទម្រង់នៃមជ្ឈត្តវិនិច្ឆ័យ)* រួចហើយ អគ្គលេខាធិការដ្ឋានត្រូវបោះត្រា ម.ជ.ម. លើមជ្ឈត្តវិនិច្ឆ័យដោយមិនបង្អង់ និងបញ្ជូនមជ្ឈត្តវិនិច្ឆ័យនោះទៅភាគីវិវាទទាំងអស់ ប្រសិនបើការបង់ប្រាក់ជាមុនដែលតម្រូវត្រូវបានបង់ទៅ ម.ជ.ម. ស្របតាមប្រការ ៦៤ *(ប្រាក់បង់ជាមុន)* ឬប្រសិនបើកម្រៃសេវាទាំងអស់លើមជ្ឈត្តការត្រូវបានបង់គ្រប់ចំនួនទៅ ម.ជ.ម. សម្រាប់ករណីមជ្ឈត្តវិនិច្ឆ័យស្ថាពរ។

## ប្រការ ៥២. អានុភាព និងការអនុវត្តមជ្ឈត្តវិនិច្ឆ័យ

ស្របតាមប្រការ ៥៣ *(ការកែតម្រូវ ការបំភ្លឺលម្អិត និងការបកស្រាយមជ្ឈត្តវិនិច្ឆ័យ និងមជ្ឈត្តវិនិច្ឆ័យបន្ថែម)* មជ្ឈត្តវិនិច្ឆ័យនឹងក្លាយជាមជ្ឈត្តវិនិច្ឆ័យស្ថាពរ និងមាន

ជំពូកទី ៧

# កម្រៃសេវា

## ប្រការ ៥៦. កម្រៃសេវាមជ្ឈត្តកម្ម

*៥៦.១. កម្រៃសេវាមជ្ឈត្តកម្ម និងតារាងកម្រៃសេវារបស់ ម.ជ.ម.*

កម្រៃសេវាមជ្ឈត្តកម្ម រួមមាន៖

(ក) កម្រៃសេវាចុះបញ្ជីសំណុំរឿង និងកម្រៃសេវាលើពាក្យសុំនានា

(ខ) កម្រៃសេវារដ្ឋបាល

(គ) កម្រៃសេវាតែងតាំងមជ្ឈត្តករ

(ឃ) កម្រៃសេវាវេទិកាមជ្ឈត្តកម្ម

(ង) កម្រៃសេវានានាសម្រាប់នីតិវិធីមជ្ឈត្តករបន្ទាន់ និង

(ច) កម្រៃចំណាយផ្សេងៗរបស់មជ្ឈត្តករបន្ទាន់ វេទិកាមជ្ឈត្តកម្ម និង ម.ជ.ម.

ដូចមានកំណត់ចាប់ពីប្រការ ៥៦ *(កម្រៃសេវាមជ្ឈត្តកម្ម)* ដល់ប្រការ ៦២ *(ការចំណាយផ្សេងៗ របស់មជ្ឈត្តករបន្ទាន់ វេទិកាមជ្ឈត្តកម្ម និង ម.ជ.ម.)*។

អគ្គលេខាធិការដ្ឋានត្រូវកំណត់កម្រៃសេវាមជ្ឈត្តកម្មដោយអនុលោមតាមជំពូកនេះ និងតារាងកម្រៃសេវារបស់ ម.ជ.ម. ដែលត្រូវបានអនុម័តដោយ ម.ជ.ម. ស្របតាមបទបញ្ជាផ្ទៃក្នុងរបស់ ម.ជ.ម.។ ការកំណត់កម្រៃសេវាមជ្ឈត្តកម្មរបស់អគ្គលេខាធិការដ្ឋានជាការកំណត់ស្ថាពរ។ ក្នុងករណីដែលមជ្ឈត្តកម្មត្រូវបានដោះស្រាយដោយស្ម័គ្រចិត្ត ឬត្រូវបានបញ្ចប់ដោយមិនមានការធ្វើសវនាការអគ្គលេខាធិការដ្ឋានត្រូវកំណត់កម្រៃសេវាជាស្ថាពរសម្រាប់មជ្ឈត្តកម្មនៃករណីនោះ។ អគ្គលេខាធិការដ្ឋានត្រូវកំណត់កម្រៃសេវាមជ្ឈត្តកម្មនៃករណីនេះដោយពិចារណារាល់កាលៈទេសៈនៃ

សំណុំរឿងរាប់បញ្ចូលទាំងដំណាក់កាលនៃដំណើរការមជ្ឈត្តការដែលមជ្ឈត្តកម្មត្រូវបានដោះស្រាយដោយស្ម័គ្រចិត្ត ឬត្រូវបានបញ្ចប់។ ក្នុងករណីដែលកម្រៃសេវាមជ្ឈត្តកម្មដែលកំណត់មានតំលៃទាបជាងប្រាក់បង់ជាមុន ម.ជ.ម. ត្រូវបង្វិលសងទៅគូភាគីវិវាទវិញនូវទឹកប្រាក់ទៅតាមសមាមាត្រដែលគូភាគីវិវាទបានព្រមព្រៀងគ្នា ឬតាមសមាមាត្រដូចគ្នានឹងសមាមាត្រដែលប្រាក់បង់ជាមុនត្រូវបានបង់ ប្រសិនបើមិនមានការព្រមព្រៀងរវាងគូភាគីវិវាទទេនោះ។

### *៥៦.២.ការកែប្រែ និងការអនុវត្តតារាងកម្រៃសេវារបស់ ម.ជ.ម.*

ក្រុមប្រឹក្សាប្រតិបត្តិរបស់ ម.ជ.ម. អាចធ្វើកែប្រែតារាងកម្រៃសេវារបស់ខ្លួននៅពេលណាមួយដែលក្រុមប្រឹក្សាប្រតិបត្តិយល់ថាសមស្រប។ តារាងកម្រៃសេវារបស់ ម.ជ.ម. ដែលត្រូវអនុវត្ត គឺតារាងកម្រៃសេវាដែលមានសុពលភាពជាធរមាននៅកាលបរិច្ឆេទដែលអគ្គលេខាធិការដ្ឋានបានទទួលសេចក្ដីជូនដំណឹងអំពីមជ្ឈត្តកម្មពេញលេញស្របតាមប្រការ ៧.១ *(សេចក្ដីជូនដំណឹងអំពីមជ្ឈត្តកម្ម)*។

### *៥៦.៣.ការបែងចែកកម្រៃសេវាមជ្ឈត្តកម្ម*

វេទិកាមជ្ឈត្តកម្មត្រូវកំណត់ឱ្យបានច្បាស់លាស់នូវកម្រៃសេវាសរុបសម្រាប់មជ្ឈត្តកម្មនៅក្នុងមជ្ឈត្តវិនិច្ឆ័យរបស់ខ្លួន។ លើកលែងតែគូភាគីវិវាទបានព្រមព្រៀងផ្សេងពីនេះ វេទិកាមជ្ឈត្តកម្មត្រូវកំណត់ឱ្យជាក់លាក់អំពីការបែងចែកកម្រៃសេវាសម្រាប់មជ្ឈត្តកម្មរវាងគូភាគីវិវាទនៅក្នុងមជ្ឈត្តវិនិច្ឆ័យ។

អនុលោមតាមបញ្ញត្តិខាងលើ វេទិកាមជ្ឈត្តកម្មត្រូវកំណត់ចំនួនទឹកប្រាក់ដែលភាគីវិវាទម្ខាងត្រូវបង់ទៅភាគីវិវាទម្ខាងទៀត។ សម្រាប់ការកំណត់នេះ វេទិកាមជ្ឈត្តកម្មត្រូវយកមកពិចារណានូវចំនួនទឹកប្រាក់បង់ជាមុន ដែលគូភាគីវិវាទបានបង់ទៅ ម.ជ.ម. ដូចមានកំណត់ក្នុងប្រការ ៦៤ *(ប្រាក់បង់ជាមុន)*។

### *៥៦.៤.ការទទួលខុសត្រូវរួមគ្នា និងដោយឡែកពីគ្នា*

គូភាគីវិវាទត្រូវទទួលខុសត្រូវរួមគ្នា និងដោយឡែកពីគ្នាក្នុងការបង់កម្រៃសេវាសរុបសម្រាប់មជ្ឈត្តកម្មទៅ ម.ជ.ម.។

## កម្រៃសេវារដ្ឋបាល (គិតជាដុល្លារអាមេរិក)

| កម្លៃកម្មវត្ថុនៃវិវាទ | | | | | កម្រៃសេវារដ្ឋបាល | | | | |
|---|---|---|---|---|---|---|---|---|---|
| រហូត | ៥០.០០០ | | | = | ៧៥០ | | | | |
| ចាប់ពី | ៥០.០០១ | ដល់ | ១០០.០០០ | = | ១.៥០០ | + | 0,៨0% | នៃចំនួនដែលលើសពី | ៥០.០០០ |
| ចាប់ពី | ១០០.០០១ | ដល់ | ៥០០.០០០ | = | ១.៩០០ | + | 0,៧0% | នៃចំនួនដែលលើសពី | ១០០.០០០ |
| ចាប់ពី | ៥០០.០០១ | ដល់ | ១.០០០.០០០ | = | ៤.៧០០ | + | 0,៥0 % | នៃចំនួនដែលលើសពី | ៥០០.០០០ |
| ចាប់ពី | ១.០០០.០០១ | ដល់ | ៣.០០០.០០០ | = | ៧.២០០ | + | 0,២0% | នៃចំនួនដែលលើសពី | ១.០០០.០០០ |
| ចាប់ពី | ៣.០០០.០០១ | ដល់ | ៥.០០០.០០០ | = | ១១.២០០ | + | 0,១២% | នៃចំនួនដែលលើសពី | ៣.០០០.០០០ |
| ចាប់ពី | ៥.០០០.០០១ | ដល់ | ១០.០០០.០០០ | = | ១៣.៦០០ | + | 0,0៨% | នៃចំនួនដែលលើសពី | ៥.០០០.០០០ |
| ចាប់ពី | ១០.០០០.០០១ | ដល់ | ៥០.០០០.០០០ | = | ១៧.៦០០ | + | 0,0៤% | នៃចំនួនដែលលើសពី | ១០.០០០.០០០ |
| លើសពី | ៥០.០០០.០០០ | | | = | ៣៣.៦០០ | | | | |

## កម្រៃសេវាមេធិការមជ្ឈត្តកម្ម (គិតជាដុល្លារអាមេរិក)

| តម្លៃកម្មវត្ថុនៃវិវាទ | | | | កម្រៃសេវាមេធិការមជ្ឈត្តកម្ម ( សម្រាប់មជ្ឈត្តករមួយរូប ) | | | | | |
|---|---|---|---|---|---|---|---|---|---|
| រហូត | ៥០.០០០ | | | = | ១.០០០ | | | | |
| ចាប់ពី | ៥០.០០១ | ដល់ | ១០០.០០០ | = | ២.៧៥០ | + | ២% | នៃចំនួនដែលលើសពី | ៥០.០០០ |
| ចាប់ពី | ១០០.០០១ | ដល់ | ៥០០.០០០ | = | ៣.៧៥០ | + | ១,៧០% | នៃចំនួនដែលលើសពី | ១០០.០០០ |
| ចាប់ពី | ៥០០.០០១ | ដល់ | ១.០០០.០០០ | = | ១០.៥៥០ | + | ១,៥០% | នៃចំនួនដែលលើសពី | ៥០០.០០០ |
| ចាប់ពី | ១.០០០.០០១ | ដល់ | ៣.០០០.០០០ | = | ១៨.០៥០ | + | ០,៧៥% | នៃចំនួនដែលលើសពី | ១.០០០.០០០ |
| ចាប់ពី | ៣.០០០.០០១ | ដល់ | ៥.០០០.០០០ | = | ៣៣.០៥០ | + | ០,៥០% | នៃចំនួនដែលលើសពី | ៣.០០០.០០០ |
| ចាប់ពី | ៥.០០០.០០១ | ដល់ | ១០.០០០.០០០ | = | ៤៣.០៥០ | + | ០,៣០% | នៃចំនួនដែលលើសពី | ៥.០០០.០០០ |
| ចាប់ពី | ១០.០០០.០០១ | ដល់ | ៥០.០០០.០០០ | = | ៥៨.០៥០ | + | ០,១៥% | នៃចំនួនដែលលើសពី | ១០.០០០.០០០ |
| លើសពី | ៥០.០០០.០០០ | | | = | ១១៨.០៥០ | | ០,០៧៥% | នៃចំនួនដែលលើសពី | ៥០.០០០.០០០ |

# ឧបសម្ព័ន្ធទី៤
# ដំណោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ ប្រទេសកម្ពុជា ដោយ លោក ស្ទីវិន អ៊ែម អូរស្មើរមីឡឺរ៍ ឆ្នាំ ២០១៩

## D. Alternative Dispute Resolution

ADR offers alternatives to these problem-solving options. Today, ADR has become an important part of the legal landscape in Cambodia and elsewhere because of the perceived problems with the traditional court system. Those problems include:

